**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ដីកាដំណោះស្រាយ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ លោក **ប៊ិន រតនា**
លោក **ឌិន គឹមហេង**

ណែនាំដោយ

លោកជំទាវ **ចាំង ស៊ីណាត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំបាទទាំងពីរឈ្មោះ **ម៉ិន រតនា** និងឈ្មោះ **ជិន គឹមហេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៤ ក្នុងឆ្នាំសិក្សា ២០២០-២០២៤ នៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមសម្តែងនូវភាពកត្តញ្ញូតាធម៌ និងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតមិនអាចកាត់ថ្លៃបាន **លោកអ្នកមានគុណរបស់យើងខ្ញុំបាទទាំងពីរ** ដែលបានផ្តល់កំណើតលះបង់នូវកម្លាំងកាយចិត្តពុះពារគ្រប់ឧបសគ្គដល់យើងខ្ញុំបាទ និងចិញ្ចឹមបីបាច់ថែរក្សាព្រមទាំងបានផ្គត់ផ្គង់ចំពោះការស្នាក់នៅការរៀនសូត្រតាំងពីថ្នាក់មត្តេយ្យសិក្សារហូតដល់កម្រិតបរិញ្ញាបត្រ និងបានចូលរួមចំណែកយ៉ាងពេញទំហឹងនូវការផ្តល់កម្លាំងកាយចិត្ត ការអប់រំ ការទូន្មានប្រៀនប្រដៅព្រមទាំងផ្តល់នូវព្រហ្មវិហារធម៌ពីសំណាក់បុព្វញាតិ និងសាខាញាតិ។ សេចក្តីដឹងគុណទាំងអស់នេះពុំអាចកាត់ថ្លៃបាន និងមិនអាចរៀបរាប់ឱ្យអស់សេចក្តីនៅក្នុងសេចក្តីអំណរគុណនេះបានឡើយ។

យើងខ្ញុំបាទទាំងពីរក៏សូមថ្លែងអំណរគុណដល់ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ជាទីកន្លែងដែលបានបណ្តុះបណ្តាលចំណេះដឹង ក៏ដូចជាការស្រាវជ្រាវក្នុងផ្នែកនីតិសាស្ត្រនេះ តាំងពីឆ្នាំទីមួយរហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រប្រកបដោយភាពជោគជ័យ និងចំណេះដឹងផ្នែកច្បាប់យ៉ាងល្អ។

យើងខ្ញុំបាទទាំងពីរក៏សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និងលោក-លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោក-លោកស្រីសាស្ត្រាចារ្យ បានផ្តល់នូវពុទ្ធិ ការអប់រំ និងសីលធម៌យ៉ាងល្អថ្លៃថ្លា មកដល់យើងខ្ញុំបាទទាំងពីរក្នុងរយៈពេល ៤ ឆ្នាំកន្លងមកនេះ។

បន្ថែមពីលើនេះទៅទៀត យើងខ្ញុំបាទទាំងពីរសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **ញឹក ឌុទ្ធី** ជាប្រធានការិយាល័យស្រាវជ្រាវដែលបានអនុញ្ញាតឱ្យយើងខ្ញុំបាទទាំងពីរធ្វើការស្រាវជ្រាវប្រធានបទនេះ បើទោះបីជាមានសិស្សច្បងជំនាន់មុនក៏ដូចជាមិត្តនិស្សិតរួមជំនាន់ជ្រើសរើសប្រធានបទនេះ ឬ ស្រដៀងនេះក៏ដោយក៏លោកតែងតែអនុគ្រោះ ព្រោះការស្រាវជ្រាវអត្ថបទ និងការឡើងការពារសារណានេះ មានសណ្ឋាន បច្ចេកទេសបកស្រាយខុសប្លែកពីគ្នា។

ជាពិសេសយើងខ្ញុំបាទទាំងពីរ សូមថ្លែងអំណរគុណចំពោះលោកជំទាវ **ចាំង ស៊ីណាត** ជាគ្រូដែលណែនាំ និងដឹកនាំក្នុងការសរសេរសារណារបស់យើងខ្ញុំបាទ ដោយលោកបានខិតខំទាំងកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការផ្តល់នូវដំបូន្មាន គំនិត ពុទ្ធិ យោបល់ ការលើកទឹកចិត្ត និង

ការបង្ហាញផ្លូវដល់យើងខ្ញុំបាទទាំងពីរ ចាប់ពីថ្ងៃចាប់ផ្ដើមសរសេរសារណាបញ្ចប់ការសិក្សានេះ រហូតដល់ថ្ងៃទទួលបានស្នាដៃមួយនេះជាស្ថាពរ ដែលគុណទាំងនេះ គឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់ថ្លៃបានឡើយមកលើយើងខ្ញុំបាទទាំងពីរ។

ជាកិច្ចបញ្ចប់នេះ យើងខ្ញុំបាទទាំងពីរសូមបួងសួងដល់បារមីនៃវត្ថុស័ក្តសិទ្ធិទាំងពួងនៅលើលោកនេះ មេត្តាថែរក្សាអ្នកមានគុណទាំងពីរ ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសលោកជំទាវ **ចាំង ស៊ីណាត** សូមឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា។

# **អារម្ភកថា**

យើងខ្ញុំបាទទាំងពីរជានិស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី**២៤** កំពុងនឹងបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ តាមការសិក្សារយៈពេលកន្លងមក ការសិក្សាផ្នែកនីតិសាស្ត្រនេះ ពិតជាបានផ្ដល់នូវសារៈសំខាន់សម្រាប់យើងខ្ញុំបាទ ក្នុងនាមជាយុវជនជំនាន់ក្រោយ កាលៈទេសៈខ្លះយើងខ្ញុំបានជួបប្រទះនូវឧបសគ្គ និងការលំបាកយ៉ាងណាក៏យើងខ្ញុំនូវតែព្យាយាមតស៊ូក្រេបចំណេះដឹងដោយមិនព្រមបោះបង់ចោលនូវក្នុងគោលបំណងធំ ដើម្បីសម្រេចនូវការសិក្សាផ្នែកនីតិសាស្ត្រជោគជ័យជាស្ថាពរ។ ទន្ទឹមនឹងនេះ ការបញ្ចប់បរិញ្ញាបត្រដោយជោគជ័យ យើងខ្ញុំក៏មានគោលបំណងក្នុងការសរសេរសារណាផងដែរ និងជាស្នាដៃ ក្នុងការរំលឹកសម្រាប់យើងខ្ញុំបាទផ្ទាល់ បន្ទាប់ពីបញ្ចប់ការសិក្សាអស់រយៈពេល ៤ ឆ្នាំកន្លងមកនេះ។

ជាកត្តាចំណង ដោយមានការសិក្សាពីមុខវិជ្ជាសំខាន់ៗកន្លងមក បានធ្វើឱ្យយើងខ្ញុំទាំងពីរមានចំណាប់អារម្មណ៍ជាខ្លាំងលើក្រមនីតិវិធីព្រហ្មទណ្ឌជាមុខវិជ្ជាមួយដែលបានរួមចំណែកក្នុងការគ្រប់គ្រងសង្គមជាតិឱ្យកាន់តែរីកចម្រើន។ លើសពីនេះទៅទៀត យើងខ្ញុំបាទទាំងពីរបានសិក្សាអំពីនីតិវិធី និងដំណាក់កាលក្នុងរឿងក្ដីព្រហ្មទណ្ឌ ដើម្បីសិក្សាឱ្យកាន់តែលម្អិតបន្ថែមអំពីចំណាត់ការនៅក្នុងតុលាការ ទើបយើងខ្ញុំបាទទាំងពីរបានសម្រេចធ្វើការស្រាវជ្រាវប្រធានបទមួយមានចំណងជើងថា"**ដីកាដំណោះស្រាយ**"។

គោលបំណងដ៏ធំជាកត្តាជម្រុញឱ្យក្រុមយើងខ្ញុំបាទ សម្រេចចិត្តជ្រើសរើសយកប្រធានបទនេះឡើងមក ដើម្បីជាពុទ្ធិក្នុងការស្វែងយល់បន្ថែមទៅលើការអនុវត្តន៍ជាក់ស្ដែង ទទួលបានបទពិសោធន៍ និងអាចដឹងកាន់តែស៊ីជម្រៅទៅលើដំណើរការរឿងក្ដីព្រហ្មទណ្ឌនៃសាលាដំបូងតាមរាជធានី ខេត្ត នានា។

ជាការពិតនៃការសរសេរសារណានេះ ស្រាវជ្រាវក្នុងន័យចែករំលែកជាបទពិសោធន៍ គន្លឹះការស្វ័យសិក្សាក្នុងការបញ្ចប់ឆ្នាំរបស់ក្រុមយើងខ្ញុំ កត្តាចម្បងទាំងនេះហើយ ទើបយើងខ្ញុំបានស្រវ៉ាស្រទេញខិតខំ ប្រឹងប្រែង រិះរក និងមានគំនិតផ្ដួចផ្ដើមធ្វើការចងក្រងសារណាមួយនេះឡើង ដើម្បីផ្ដល់ភាពងាយស្រួលដល់រាមច្បង ឬ បញ្ញវន្តជំនាន់ក្រោយៗ យកមកធ្វើការស្រាវជ្រាវបន្ថែមទៀត ឱ្យលោកបានយល់កាន់តែលម្អិតអំពីដីកាដំណោះស្រាយនៃដំណើរការនីតិវិធីរឿងក្ដីព្រហ្មទណ្ឌ ក្នុងដំណាក់កាលប្រតិបត្តិកិច្ចការរបស់ខ្លួនតែប៉ុណ្ណោះ។

ជាចុងបញ្ចប់ យើងខ្ញុំបាទទាំងពីរសង្ឃឹមយ៉ាងមុះមុតថា សារណានេះអាចផ្ដល់នូវគុណប្រយោជន៍ទៅកាន់រៀមច្បង និស្សិតជំនាន់ក្រោយ អ្នកប្រកបវិជ្ជាជីវៈច្បាប់ និងមន្ត្រីរាជការ ដែលលោកមានការយក

ចិត្តទុកដាក់ស្វែងយល់ពីក្រមនីតិវិធីព្រហ្មទណ្ឌ។ ទន្ទឹមនឹងនេះ គុណសម្បត្តិដ៏មានតម្លៃនៃសារណានេះ ប្រាកដ និងមានគុណវិបត្តិខ្លះៗជាក់ជាមិនខានដែលមិនអាចជៀសវាងផុត ហេតុនេះហើយ ប្រសិនបើ មានការខុសឆ្គង ឬ ខ្វះចន្លោះនូវអត្ថន័យ ឬ ខ្លឹមសារ ឬ ពាក្យពេចន៍ណាមួយនៅក្នុងអត្ថបទខាងលើនេះ ដោយប្រការណាមួយនោះក្រុមខ្ញុំបាទសូមការអភ័យទោសទុកជាមុន ព្រមទាំងសូមថ្លែងអំណរគុណ និង អបអរយ៉ាងជ្រាលជ្រៅ នៅពេលទទួលសេចក្តីអត្ថាធិប្បាយ ផ្តល់មតិយោបល់កែលម្អរក្នុងន័យស្ថាបនា ពីលោកអ្នកអានទាំងអស់។

*សូមអរព្រះគុណ និងសូមអរគុណ!*

ថ្ងៃសៅរ៍ ៦ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

**ប៊ិន រតនា ជិន គឹមហេង**

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី ១
## ប្រភេទនៃដីកាដំណោះស្រាយ

**១.១ ដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ** ........................................ ៣

១.១.១ ការសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ........................................ ៣

១.១.២ ការចេញដីកាបញ្ជូនឱ្យសម្រេចរឹបអូសវត្ថុតាង ........................................ ១២

**១.២ ការលើកលែងការចោទប្រកាន់** ........................................ ១៣

១.២.១ អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ លហុ ........................................ ១៤

១.២.១.១ បទឧក្រិដ្ឋ ........................................ ១៦

១.២.១.២ បទមជ្ឈិម ........................................ ១៦

១.២.១.៣ បទលហុ ........................................ ១៧

១.២.២ ជនដែលប្រព្រឹត្តអំពើនោះជាអញ្ញាតជន ........................................ ១៧

១.២.៣ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ ........................................ ១៩

១.២.៤ ករណីដែលបណ្តឹងអាជ្ញារលត់ ........................................ ២១

១.២.៤.១ មរណភាពនៃជនល្មើស ........................................ ២២

១.២.៤.២ ការផុតអាជ្ញាយុកាល ........................................ ២២

១.២.៤.៣ ការលើកលែងទោសជាទូទៅ ........................................ ២៣

១.២.៤.៤ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ........................................ ២៤

១.២.៤.៥ អាជ្ញាអស់ជំនុំ ........................................ ២៥

១.២.៤.៦ ការសម្របសម្រួល ........................................ ២៦

១.២.៤.៧ ការបង់ប្រាក់ពិន័យសរុប ឬ ការបង់ប្រាក់ពិន័យសម្របសម្រួល....២៦
១.២.៤.៨ ការដកពាក្យប្តឹង ....២៦

## ជំពូកទី ២
## នីតិវិធីនៃការចេញដីកាដំណោះស្រាយ

**២.១ អ្នកមានសមត្ថកិច្ចចេញដីកាដំណោះស្រាយ** ....២៨
**២.២ លំហូរនីតិវិធីនៃការចេញដីកាដំណោះស្រាយ** ....២៨
២.២.១ ការបើកការស៊ើបសួរ ....២៨
២.២.២ ការបិទការស៊ើបសួរ .... ៣៥
២.២.២.១ ការជូនដំណឹងស្តីអំពីការបិទស៊ើបសួរទៅតំណាងអយ្យការ និងជនដែលជាប់ទាក់ទិន.. ៣៦
២.២.២.២ ការបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ .... ៣៧
២.២.២.៣ ដីកាសន្និដ្ឋានស្ពាពរ.... ៣៧
២.២.២.៤ ការចេញដីកាដំណោះស្រាយ .... ៣៨

## ជំពូកទី ៣
## បណ្តឹងចំពោះដីកាដំណោះស្រាយ

**៣.១ បណ្តឹងចំពោះដីកាដំណោះស្រាយដោយតំណាងអយ្យការ** .... ៤១
**៣.២ បណ្តឹងចំពោះដីកាដំណោះស្រាយដោយដើមបណ្តឹងរដ្ឋប្បវេណី**.... ៥០
**សេចក្តីសន្និដ្ឋាន** ....៥៣
**អនុសាសន៍** .... ៥៥

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

នៅតាមបណ្ដាប្រទេសនានានៃសាកលលោក គឺមានការបែងចែកអំណាចជាបីប្រភេទធំៗរួមមាន អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ក្នុងនោះអំណាចតុលាការត្រូវបានតែងតាំងដោយព្រះមហាក្សត្រជាប្រធានក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈព្រះរាជក្រឹត្យ និងជាអំណាចឯករាជ្យធានាក្នុងការស្វែងរកយុត្តិធម៌ និងការពារសិទ្ធិសេរីភាពជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន។ អំណាចតុលាការត្រូវបានប្រគល់ឱ្យតាមរយៈសាលាដំបូងរាជធានី ខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូលដើម្បីស្វែងរកយុត្តិធម៌ដោយធ្វើការជំនុំជម្រះក្ដីតាមនីតិវិធីច្បាប់ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្នុងន័យជាគុណប្រយោជន៍ជូនដល់សង្គមជាតិទាំងមូលតាមរយៈចៅក្រមមានករណីកិច្ចគោរពច្បាប់ឱ្យបានម៉ឺងម៉ាត់ឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។

ជាបឋមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនីតិវិធីព្រហ្មទណ្ឌនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ។ ម្យ៉ាងវិញទៀតក្រមនីតិវិធីព្រហ្មទណ្ឌមានបទប្បញ្ញត្តិចំនួន ១១ គន្ថី និងមានចំនួន ៦១២ មាត្រា ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មចំនួនមួយលើកទៅលើមាត្រា **២៤៧** មាត្រា **៣៦៨** មាត្រា **៣៧២** មាត្រា **៣៨២** ដែលប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣។

ជាគោលការណ៍ក្រមនីតិវិធីព្រហ្មទណ្ឌជាលំហូរនីតិវិធីសម្រាប់អនុវត្ត ឬ ដំណើរការនៃរឿងក្ដីព្រហ្មទណ្ឌដែលជាគោលការណ៍មូលដ្ឋានប្រសិនបើនីតិវិធីពុំមានច្បាប់ចែង នោះក៏ពុំមានដំណើរការនៃនីតិវិធីផងដែរ។ មួយវិញទៀតនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់នូវការអនុវត្តច្បាប់ដោយយុត្តិធម៌ទៅដល់ភាគីក្នុងរឿងក្ដីព្រហ្មទណ្ឌ។ ជាគោលការណ៍នីត្យានុកូលភាពនៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់នូវនីតិវិធីចំនួនបួនដំណាក់កាល គឺទី១ជាដំណាក់ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ក្រោមការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាដើម្បីធ្វើការស៊ើបសួរអង្កេតបឋម និងករណីបទល្មើសជាក់ស្ដែង។ ទី២ ជាដំណាក់កាលនៃការចោទប្រកាន់ ឬ អនុវត្តដោយព្រះរាជអាជ្ញាដើម្បីពិនិត្យទៅលើអង្គហេតុថាមានបទល្មើស ឬ ពុំមានបទល្មើស ប្រសិនបើតំណាងអយ្យការពិនិត្យទៅឃើញថាមានបទល្មើស នោះតំណាងអយ្យការនឹងបើកធ្វើការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ តាមនីតិវិធីបង្គាប់ឱ្យចូលខ្លួនភ្លាម ប៉ុន្តែបើតំណាងអយ្យការបានពិនិត្យ និងវាយតម្លៃទៅលើអង្គហេតុនោះពុំមានបទល្មើសទេតំណាងអយ្យការនឹងតម្កល់រឿងទុកឥតចាត់ការ។ ទី៣ គឺដំណាក់កាលស៊ើបសួរ និងទី៤

ជាដំណាក់កាលជំនុំជម្រះ។ ក៏ប៉ុន្តែក្នុងករណីនេះសូមធ្វើការលើកយកមកនូវដំណាក់កាលទី៣ ការស៊ើបសួរ ដែលធ្វើដោយយុត្តាធិការស៊ើបសួរ។ យុត្តាធិការស៊ើបសួរ គឺនៅថ្នាក់សាលាដំបូងរាជធានី ខេត្ត ក្រុង ដែលធ្វើឡើងដោយមន្ទីរស៊ើបសួរដោយមានចៅក្រមស៊ើបសួរមួយ ឬ ច្រើនទៅតាមការចាំបាច់។ គួរបញ្ជាក់ផងដែរ សមត្ថកិច្ចចម្បងចៅក្រមស៊ើបសួរ គឺជាគោលការណ៍ការស៊ើបសួរត្រូវបើកជាចាំបាច់ដែលមានកាតព្វកិច្ចជាបទឧក្រិដ្ឋ ហើយចំពោះបទមជ្ឈិមការស៊ើបសួរអាចបើកឡើងក្នុងករណីមានសភាពស្មុកស្មាញ ឬ ភស្តុតាងមិនគ្រប់គ្រាន់។ ហេតុនេះ ចៅក្រមស៊ើបសួរត្រូវស្វែងរកការពិត និងស្វែងរកទាំងភស្តុតាងដាក់បន្ទុក ឬ ដោះបន្ទុក។ ជាមូលដ្ឋានច្បាប់នៃការស៊ើបសួរនេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញានេះ គឺជាការបង្កើតចាប់ផ្តើមនូវដំណាក់កាលនៃការស៊ើបសួរដើម្បីផ្តល់មូលដ្ឋាន និងសិទ្ធិអំណាចដោយស្របច្បាប់ឱ្យទៅចៅក្រមស៊ើបសួរឱ្យប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីស្វែងរកការពិតដោយអនុលោមទៅតាមច្បាប់។ ហើយនៅក្នុងក្របខ័ណ្ឌនៃការស៊ើបសួរនេះចៅក្រមស៊ើបសួរត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់សិទ្ធិអំណាចជាច្រើន។ នៅពេលដែលចៅក្រមស៊ើបសួរបានប្រើប្រាស់សិទ្ធិអំណាចច្បាប់ផ្តល់ឱ្យដើម្បីធ្វើកិច្ចស៊ើបសួរទៅលើសំណុំរឿងព្រហ្មទណ្ឌចប់សព្វគ្រប់អស់ ហើយថាមានបទល្មើសកើតឡើងពិតប្រាកដមែន នោះចៅក្រមស៊ើបសួរត្រូវសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះដោយដីកាដំណោះស្រាយ។ ហេតុនេះ ដើម្បីជ្រាបឱ្យកាន់តែច្បាស់ទៅលើដីកាដំណោះស្រាយក្រុមយើងខ្ញុំបានបែងចែកជាបីជំពូកសំខាន់ៗ **ប្រភេទនៃដីកាដំណោះស្រាយ (ជំពូកទី១) នីតិវិធីនៃការចេញដីកាដំណោះស្រាយ (ជំពូកទី២) និងបណ្តឹងចំពោះដីកាដំណោះស្រាយ (ជំពូកទី៣)។**

# ជំពូកទី ១
# ប្រភេទនៃដីកាដំណោះស្រាយ

# ជំពូកទី ១
# ប្រភេទនៃដីកាដំណោះស្រាយ

ជាការពិតណាស់ នៅពេលដែលចៅក្រមស៊ើបសួរបានបំពេញកិច្ចស៊ើបសួរចប់សព្វគ្រប់អស់ហើយ ចៅក្រមស៊ើបសួរត្រូវបិទការស៊ើបសួរដោយត្រូវបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញា។ បន្ទាប់មក ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅឱ្យចៅក្រមស៊ើបសួរដោយភ្ជាប់នូវដីកាសន្និដ្ឋានស្ថាពរ។ តាមរយៈដីកាសន្និដ្ឋានស្ថាពរ ព្រះរាជអាជ្ញាអាចប្តឹងឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនជននោះទៅជំនុំជម្រះសាលាវិនិច្ឆ័យ ឬ លើកលែងការចោទប្រកាន់។ នៅពេលដែលចៅក្រមបិទការស៊ើបសួរគាត់ និងអនុវត្តតាមរយៈ ដីកាដំណោះស្រាយ"។ នៅក្នុងដំណាក់កាល នៃនីតិវិធីការចេញដីកាដំណោះស្រាយដោយត្រូវបានបែងចែកជាពីរប្រភេទ **ដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ** (១.១) **និងដីកាសម្រេចលើកលែងការចោទប្រកាន់** (១.២)។

## ១.១ ដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ

ជាក់ស្តែង ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបញ្ជូនទៅជំនុំជម្រះបាន ប្រសិនបើចៅក្រមស៊ើបសួរស្វែងរកភស្តុតាងមួយចំនួននៃអង្គហេតុទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។ គ្រប់ដីកាទាំងអស់របស់ចៅក្រមស៊ើបសួរត្រូវធ្វើជាលាយល័ក្ខអក្សរចុះកាលបរិច្ឆេទ និងហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងអបដោយក្រឡាបញ្ជី។ ក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឱ្យដីកាទាំងនេះចែងនូវធាតុផ្សេងៗដែលអនុញ្ញាតឱ្យកំណត់អត្តសញ្ញាណជនត្រូវចោទមានដូចជា នាម គោត្តនាម ទីកន្លែង និងថ្ងៃខែឆ្នាំកំណើត លំនៅដ្ឋាន និងមុខងាររបស់បុគ្គលនោះ។ ដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ ត្រូវចង្អុលបង្ហាញអំពីឈ្មោះបទល្មើស ដែលច្បាប់បានកំណត់ និងដែលដាក់បន្ទុកទៅលើជនត្រូវចោទព្រមជាមួយនឹងមូលហេតុដែលមាន ឬ គ្មានបន្ទុកគ្រប់គ្រាន់ប្រឆាំងបុគ្គលនោះ។ ប្រសិនបើមិនបានកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ទេ ដីកានេះនឹងចាត់ទុកជាមោឃៈ។ ក្នុងនោះផងដែរ ចំពោះការសម្រេចបញ្ជូនទៅជំនុំជំម្រះដោយចៅក្រមស៊ើបសួរលើ **ការសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ** (១.១.១) **និងការចេញដីកាបញ្ជូនឱ្យសម្រេចរឹបអូសវត្ថុតាង** (១.១.២)។

### ១.១.១ ការសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ

ផ្សារភ្ជាប់ទៅហ្នឹងការសម្រេចបញ្ជូនទៅជំនុំជម្រះដែលមានជនត្រូវចោទនៅក្នុងឃុំបណ្តោះអាសន្ន គម្បីគួរបញ្ជាក់នូវចំណុចមួយចំនួនទាក់ទងនឹងការឃុំខ្លួនជាបណ្តោះអាសន្ន។ ក្រោយពីជនត្រូវចោទត្រូវបានចៅក្រមស៊ើបសួរដាក់ស្ថិតក្រោមការពិនិត្យពីបទល្មើសណាមួយហើយនោះ ចៅក្រមស៊ើបសួរត្រូវ

ពិចារណាទៅលើបញ្ហាឃុំខ្លួនជននេះបណ្ដោះអាសន្ន ឬ យ៉ាងណា។ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ បាន លើកឡើងពីគោលការណ៍នៃសេរីភាពរបស់ជនត្រូវចោទ មានន័យថា ការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នត្រូវតែជាករណីពិសេស។[1] ប្រសិនបើចៅក្រមស៊ើបសួរយល់ថា ត្រូវឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន។ ចៅក្រមស៊ើបសួរត្រូវចេញដីកាចំនួនពីរគឺ ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន និងដីកាបង្គាប់ឱ្យឃុំខ្លួន។ ដូចដែលបានលើកឡើងខាងលើថា សេរីភាពជនត្រូវចោទជាគោលការណ៍ ហេតុនេះការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នត្រូវតែជាករណីលើកលែង។ ដូចនេះ ការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើទៅបានលុះត្រាតែគោរពទៅតាមលក្ខខណ្ឌ និងមូលហេតុដូចកំណត់ក្នុងក្រមពោលគឺ៖

**ទីមួយ** ជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១ ឆ្នាំ។[2] ជាក់ស្ដែងបទល្មើសដែលមានអតិបរមានៃទោសតិចជាង ១ឆ្នាំ រួមមានដូចជា៖

- បទគំរាមកំហែង ទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៦ ខែ និងពិន័យជាប្រាក់ពី ១ សែនរៀល ទៅ ១ លានរៀល។[3]

**ទីពីរ** មានមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ដូចមានចែងនៅក្នុង**មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ដោយមានមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នមានចំនួន ៦ គឺ៖

១-ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី (**ឧទាហរណ៍** បុគ្គលម្នាក់ធ្លាប់បានប្រព្រឹត្តបទល្មើសច្រើនដងមកហើយ ដូច្នេះការឃុំខ្លួនបុគ្គលម្នាក់នោះ មានគោលដៅដើម្បីបង្ការកុំឱ្យបុគ្គលនោះទៅប្រព្រឹត្តបទល្មើសជាថ្មីទៀត)។

២-ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត (**ឧទាហរណ៍** មានភស្តុតាងបញ្ជាក់ថា មានអ្នកសមគំនិតដែល

[1] មាត្រា ២០៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[2] មាត្រា ២០៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[3] មាត្រា ២៣១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

កំពុងតែរត់គេចមិនទាន់ចាប់ខ្លួនបាននៅឡើយ។ ដូច្នេះ មូលហេតុទីពីរនេះ អាចជាមូលហេតុសម្រាប់ឱ្យមានការឃុំខ្លួនបណ្តោះអាសន្នបាន)។

៣-ដើម្បីធានារក្សាភស្តុតាង និងតម្រុយជាសម្ភារៈ (**ឧទាហរណ៍** នៅក្នុងសំណុំរឿងនៃបទឃាតកម្មកាំភ្លើងដែលជនត្រូវចោទបានប្រើប្រាស់ដើម្បីសម្លាប់ជនរងគ្រោះមិនទាន់បានរកឃើញនៅឡើយ ហើយជនត្រូវចោទក៏ពុំព្រមប្រាប់ពីទីកន្លែងលាក់កាំភ្លើងនេះដែរ)។

៤-ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី (**ឧទាហរណ៍** ជនត្រូវចោទពុំមានទីលំនៅច្បាស់លាស់ ឬ ពិតប្រាកដ។ ដូច្នេះ ប្រសិនបើមិនឃុំខ្លួនបណ្តោះអាសន្នទេ មានការលំបាកនឹងតាមរកជនត្រូវចោទឱ្យមកបង្ហាញខ្លួនចំពោះមុខតុលាការសម្រាប់ពេលសវនាការនៅពេលក្រោយទៀត)។

៥-ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ (**ឧទាហរណ៍** ជនត្រូវចោទបានប្រព្រឹត្តបទលួច ត្រូវបានប្រជាពលរដ្ឋចាប់ ហើយដែលបានបណ្តាលឱ្យអ្នកស្នាក់នៅម្តុំទីកន្លែងកើតហេតុមានការខឹងសម្បារយ៉ាងខ្លាំង រហូតដល់ស្ទើរតែកើតជាអំពើហិង្សាទៅលើជនត្រូវចោទទៀតផង។ ដូច្នេះ ប្រសិនបើមិនឃុំខ្លួនជនត្រូវចោទទេ ប្រហែលជាប្រជាពលរដ្ឋនឹងប្រើអំពើហិង្សាលើជនត្រូវចោទជាមិនខាន)។

៦-ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។ (**ឧទាហរណ៍** ជនត្រូវចោទបានប្រព្រឹត្តបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបានប្រើប្រាស់អាវុធបណ្តាលឱ្យមានការភ្ញាក់ផ្អើលដល់មនុស្សជាច្រើននាក់។ ដូច្នេះ ការឃុំខ្លួនជនត្រូវចោទរូបនេះ អាចមានគោលដៅដើម្បីធានាកុំឱ្យមានការច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ)។

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចថាឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ការឃុំខ្លួនជាបណ្តោះអាសន្ននេះត្រូវស្ថិតក្នុងចិរវេលាដែលកំណត់ដោយច្បាប់។ ចិរវេលានេះ ប្រែប្រួលទៅតាមប្រភេទនៃបទល្មើសចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទត្រូវឃុំខ្លួន។ ប៉ុន្តែប្រសិនបើ ជនត្រូវចោទពីបទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬ បទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនមិនអាចលើសពី ១ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យាការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ១ឆ្នាំ ដោយដីកាត្រូវមានសំអាងហេតុ ហើយការពន្យាពេលនេះអាចធ្វើបានតែពីរដងគត់។[4]

[4] មាត្រា ២១០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**-ប្រសិនបើជាប់ចោទពីបទឧក្រិដ្ឋផ្សេងទៀត៖**

- ជនត្រូវចោទជានីតិជន រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន គឺ៦ខែ ហើយអាចពន្យាពេលបាន ៦ខែ ទៀត ចំនួនពីរដង។[5]
- ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៤ខែ បានទេ។[6]
- ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៦ខែ បានទេ។[7]

**-ប្រសិនបើជាប់ចោទពីបទមជ្ឈិម៖**

- ជនត្រូវចោទជានីតិជន រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន គឺ៤ខែ ហើយអាចពន្យាពេលបាន ២ខែ ទៀត តែម្ដងគត់ ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។[8] ឧទាហរណ៍ ជនត្រូវចោទជាប់ចោទពីបទចោរកម្ម ដែលតាមច្បាប់ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ដល់ ៥ឆ្នាំ។ ហេតុនេះ អប្បបរមានៃទោស គឺ៦ខែ។ ពាក់កណ្ដាលនៃអប្បបរមា គឺ៣ខែ។ ហេតុនេះមានន័យថា ការឃុំខ្លួនជាបណ្ដោះអាសន្ន មិនត្រូវឱ្យលើសពី ៣ខែទេ។ ចំណែកឯបទល្មើសឆបោកវិញត្រូវបានច្បាប់កំណត់ទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ ហេតុនេះពាក់កណ្ដាលនៃអប្បបរមានៃទោស គឺ៦ខែ។ ដូច្នេះមានន័យថា ការឃុំខ្លួនជាបណ្ដោះអាសន្ន គឺ៤ខែ ហើយចៅក្រមស៊ើបសួរអាចពន្យាពេលបានបន្ថែម ២ខែទៀត តែម្ដងគត់។

---

[5] មាត្រា ២០៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[6] មាត្រា ២១៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[7] មាត្រា ២១៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[8] មាត្រា ២០៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

- ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ២ខែ បានទេ ហើយទោះជាយ៉ាងណារយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។[9]
- ជនត្រូវចោទជាអនីតិជនអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ពុំអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។

ដោយឡែកនៅពេលដែលចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនជនត្រូវចោទរួចហើយ ចៅក្រមស៊ើបសួរនឹងត្រូវបំពេញកិច្ចដោយកិច្ចស៊ើបសួរទៅតាមនីតិវិធី។ ក្រោយពីចៅក្រមស៊ើបសួរបានបំពេញកិច្ចស៊ើបសួរចប់សព្វគ្រប់ហើយ នោះចៅក្រមស៊ើបសួរនឹងចេញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះដើម្បីឱ្យទៅបង្ហាញខ្លួនចំពោះមុខចៅក្រមជំនុំជម្រះ។ ម៉្យាងវិញទៀត ការសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះក៏ជាប្រយោជន៍របស់ជនត្រូវចោទផងដែរ ពីព្រោះថាការសម្រេចនេះ ក៏ជានីតិវិធីមួយដែលបញ្ចប់នូវការឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទផងដែរ។

ម៉្យាងវិញទៀត ការសម្រេចបញ្ជូនទៅជំនុំជម្រះដែលមានជននៅក្រៅឃុំ ដោយតុលាការបានសម្រេចមិនឃុំខ្លួន គម្បីគួរបញ្ជាក់នូវចំណុចមួយចំនួនទាក់ទងនឹងការដាក់ស្ថិតក្រោមត្រួតពិនិត្យតាមផ្លូវតុលាការ។ ក្នុងករណីដែលជនត្រូវចោទជាប់ឃុំខ្លួនបណ្ដោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិពីការដោះលែងឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្នវិញបានតាមវិធីបីយ៉ាងគឺ៖

-**តាមគំនិតផ្ដួចផ្ដើមរបស់ចៅក្រមស៊ើបសួរ** ក្នុងករណីបែបនេះចៅក្រមស៊ើបសួរចេញនូវដីកាបញ្ជូនឱ្យឆ្លើយដើម្បីសុំយោបល់កព្រះរាជអាជ្ញាទាក់ទិននឹងបំណងរបស់ចៅក្រមស៊ើបសួរក្នុងការដោះលែងជនត្រូវចោទឱ្យមានសេរីភាពវិញ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងមកខ្លួន។ ជាធម្មតាចៅក្រមស៊ើបសួរត្រូវរង់ចាំយោបល់ពីព្រះរាជអាជ្ញាសិន មុននឹងសម្រេចថាដោះលែងភ្លាម ដោយចង្អុលប្រាប់ពីមូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន។[10] ចៅក្រម

[9] មាត្រា ២១៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[10] មាត្រា ២១៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ស៊ើបសួរចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ។ មូលហេតុ មិនអាចរង់ចាំបានយោងទៅលើស្ថានភាពជម្ងឺធ្ងន់ធ្ងររបស់ជនត្រូវចោទ។

-**តាមគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា** ព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានសុំឱ្យដោះលែងជនត្រូវចោទ។[11] ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ថ្ងៃ ថាយល់ព្រមដោះលែងឱ្យនៅក្រៅឃុំ ឬ មិនព្រមដោះលែងឱ្យនៅក្រៅឃុំ។ ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេលកំណត់នេះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួស។ ចៅក្រមស៊ើបសួរអាចចេញ ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ។

-**តាមពាក្យសុំឱ្យដោះលែងនៅក្រៅឃុំរបស់ជនត្រូវចោទ ឬ មេធាវីជនត្រូវចោទ** ក្នុងករណីដែលទទួលបានពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនេះទៅព្រះរាជអាជ្ញាភ្លាម ដើម្បីសុំយោបល់ និងបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។[12] ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត បន្ទាប់មកចៅក្រមស៊ើបសួរត្រូវសម្រេចថា ដោះលែង ឬ មិនដោះលែងក្នុងរយៈពេល ៥ ថ្ងៃនេះ ជនត្រូវចោទអាចប្តឹងទៅសភាស៊ើបសួរឱ្យសម្រេចជំនួសបាន។ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ។ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរចេញដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំម្តងហើយនោះ ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងសាជាថ្មីម្តងទៀត ក្នុងរយៈពេល ១ខែ បន្ទាប់ពីមានសេចក្តីសម្រេចមុន។

នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ។[13] ទោះបីជាមានសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរឱ្យដោះលែងក៏ដោយ ក៏ជនត្រូវចោទមិនអាចត្រូវបានដោះលែងភ្លាមបានដែរ ដោយត្រូវរក្សាជនត្រូវចោទទុកនៅពន្ធនាគារ រហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ៥ថ្ងៃ

[11] មាត្រា ២១៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[12] មាត្រា ២១៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[13] មាត្រា ២១៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

លើកលែងតែព្រះរាជអាជ្ញាបានយល់ព្រមជាលាយលក្ខណ៍អក្សរថាឱ្យដោះលែងជនត្រូវចោទភ្លាម។[14] ប្រសិនបើព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍ពីដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ជនត្រូវចោទត្រូវរក្សាទុកក្នុងពន្ធនាគាររហូតដល់មានសេចក្ដីសម្រេចសភាស៊ើបសួរលើបណ្ដឹងឧទ្ធរណ៍នេះ។

ក្នុងរឿងឃុំខ្លួនបណ្ដោះអាសន្ន សភាស៊ើបសួរត្រូវសម្រេចចេញសាលដីការបស់ខ្លួនក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យនៃសភាស៊ើបសួរ។[15] បើផុតរយៈពេលនេះ ជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំ លើកលែងតែក្នុងករណីដែលមានចេញបង្គាប់ឱ្យធ្វើការផ្ទៀងផ្ទាត់ ឬ ក្នុងករណីកាលៈទេសៈដែលមិនអាចមើលឃើញជាមុន ឬ មិនអាចជន្នះបានបង្កជាឧបសគ្គមិនឱ្យប្រកាសសាលដីកាបាននៅក្នុងរយៈពេលនេះ។ កាលណាសភាស៊ើបសួរសម្រេចឱ្យឃុំខ្លួនជាបណ្ដោះអាសន្ន សភាស៊ើបសួរត្រូវមានសំអាងហេតុនៅក្នុងសាលដីការបស់ខ្លួន នោះប្រធានសភាស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួន។

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ឬ សម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរអាចដាក់ជននេះឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតម្រូវឱ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចមួយ ឬ ច្រើនដែលមានបញ្ញត្តិនៅ**មាត្រា ២២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ**។ ដោយកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលមានចែងនៅ**មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** មានចំនួន ១២ គឺៈ

១-មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។

២-មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤-ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

[14] មាត្រា ២៧៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[15] មាត្រា ២៧៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

៦-ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី គ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧-មិនត្រូវបើកបររថយន្ត។

៨-មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩-ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០-មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

១១-ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត (ឧ.មេឃុំ ចៅសង្កាត់) ឬ សកម្មភាពខាងសហជីពបានទេ។

ក្រៅពីកាតព្វកិច្ចកំណត់នៅក្នុងមាត្រានេះ ចៅក្រមស៊ើបសួរពុំអាចបង្គាប់ឱ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចណាផ្សេងទៀតបានឡើយ។ ដីកាសម្រេចនេះមិនអាចធ្វើចំពោះអនីតិជន អាយុក្រោម ១៤ ឆ្នាំឡើយ។[16]

ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរចេញដីកាសម្រេចនេះបាន។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ។ ចៅក្រមស៊ើបសួរចេញដីកាសម្រេចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ ដីកាសម្រេចបដិសេធការសុំឱ្យដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរឱ្យសម្រេចជំនួសបាន។[17]

ក្រោយពីចេញដីកាសម្រេចនេះរួច អាចកែប្រែ ឬ បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយៈ

[16] មាត្រា ២២៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[17] មាត្រា ២២៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-**គំនិតផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរខ្លួនឯង** ចៅក្រមស៊ើបសួរចេញដីកាសម្រេចដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។[18]

-**បណ្តឹងសុំកែប្រែ ឬ លើកលែងពីព្រះរាជអាជ្ញា** ចៅក្រមស៊ើបសួរត្រូវសម្រេចពីបណ្តឹង នេះក្នុងរយៈពេល ៥ ថ្ងៃ។[19] ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរឱ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ ដីកាសម្រេចដែលមិនព្រមធ្វើតាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញាត្រូវតែមានសំអាងហេតុ។

ប្រសិនបើជនត្រូវចោទដែលត្រូវបានដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជនត្រូវចោទនេះជាប់កាតព្វកិច្ចដែលកំណត់ដោយចៅក្រមស៊ើបសួរ។ ហេតុនេះការគេចវេសពីកាតព្វកិច្ចដោយចេតនាអាចនឹងត្រូវដាក់ទណ្ឌកម្ម។ ក្នុងករណីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យចៅក្រមស៊ើបសួរឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នបាន ទោះបីជាទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទបានជាប់ឃុំបណ្តោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងនៅក្នុងក្រមនីតិវិធីនេះក៏ដោយ។[20] ប៉ុន្តែរយៈពេលឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ គឺ៤ខែ យ៉ាងយូរសម្រាប់នីតិជន និង២ខែយ៉ាងយូរសម្រាប់អនីតិជន ដោយពុំមានការបែងចែកប្រភេទនៃបទល្មើសចោទប្រកាន់ទេ (មាត្រា ២៣០ កថាខ័ណ្ឌចុងក្រោយនៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ **ឧទាហរណ៍៖** បុរស ក អាយុ ១៩ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ពីបទលួចតាមបញ្ញត្តិ (រយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន គឺ៣ខែ)។[21]

ក្រោយពីចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរួច ចៅក្រមស៊ើបសួរនឹងត្រូវបំពេញកិច្ចដោយកិច្ចស៊ើបសួរទៅតាមនីតិវិធី។ ក្រោយពីចៅក្រមស៊ើបសួរបានបំពេញកិច្ចស៊ើបសួរចាប់សព្វគ្រប់ហើយ និងមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ នោះចៅក្រមស៊ើបសួរនឹងចេញ

[18] មាត្រា ២២៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[19] មាត្រា ២២៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[20] មាត្រា ២៣០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[21] មាត្រា ៣៥៣ និងមាត្រា ៣៥៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ដោយរក្សាជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនូវកាតព្វកិច្ចដូចដែលមានបញ្ញត្តិដោយមានចំនួន ១២ ដើម្បីធានានូវការបង្ហាញខ្លួនចំពោះមុខចៅក្រមជំនុំជម្រះ។[22]

## ១.១.២ ការចេញដីកាបញ្ជូនឱ្យសម្រេចរឹបអូសវត្ថុតាង

ជាទូទៅ នៅពេលដែលចៅក្រមស៊ើបសួរចេញនូវដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះក្នុងនោះចៅក្រមស៊ើបសួរមិនត្រឹមតែបញ្ជូនជនត្រូវចោទប៉ុណ្ណោះទេ។ ប៉ុន្តែចៅក្រមស៊ើបសួរក៏បញ្ជូននូវវត្ថុតាងដែលបានរឹបអូស ឬ បានចាប់យកទៅកាន់ចៅក្រមជំនុំជម្រះផងដែរ។ ផ្ទុយទៅវិញ ក្នុងករណីដែលតំណាងអយ្យការបានប្ដឹងមកចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានរឿងឱ្យស៊ើបសួរដែលមានជនត្រូវចោទជាអញ្ញាតជន ហើយចៅក្រមស៊ើបសួរបានធ្វើការស្វែងរកអត្តសញ្ញាណរបស់ជននេះពុំឃើញនោះទេ ហេតុនេះចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុថាអញ្ញាតជននេះ ទោះបីជាបានស្រាវជ្រាវយ៉ាងណាក្ដីនៅក្នុងដំណាក់កាលស៊ើបសួរនេះក៏នៅតែពុំមានលទ្ធផលដែលអាចកំណត់អំពីអត្តសញ្ញាណរបស់ជនត្រូវចោទ ឬ ក្នុងករណីដែលជនត្រូវចោទទទួលមរណភាព។ ដូច្នេះ ចៅក្រមស៊ើបសួរអាចប្ដឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យ សម្រេចរឹបអូសឧបករណ៍សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធប្រសិនបើមាន។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។ ម្យ៉ាងវិញទៀត បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬ អះអាងថា ខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬ មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ហើយបែបបទ និងនីតិវិធីនៃការប្ដឹងឧទ្ធរណ៍នេះ។

[22] មាត្រា ២២៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**ឧទាហរណ៍៖** ក្នុងបទល្មើសព្រៃឈើដែលមានជនត្រូវចោទបានប្រព្រឹត្តនូវអំពើកាប់ព្រៃឈើធម្មជាតិ។ ដោយឡែកនៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញាចុះទៅបង្ក្រាបនៅទីកន្លែងកើតហេតុនោះ ជនត្រូវចោទបានរត់បាត់ដែលជាអញ្ញាតជន ដោយបន្សល់នូវតែឧបករណ៍កាប់ឈើ ឬ សម្ភារៈផ្សេងៗ ដែលទាក់ទងនឹងបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញាបានចាប់យកមកដើម្បីធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មកចៅក្រមស៊ើបសួរ។ ក្នុងករណីនេះ ប្រសិនបើចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវនូវអត្តសញ្ញាណរបស់ជនត្រូវចោទពុំគ្រប់គ្រាន់ និងច្បាស់លាស់ទេ។ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជូនឱ្យសម្រេចរឹបអូសវត្ថុតាងដែលជាឧបករណ៍ និងសម្ភារៈដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសនោះ ដើម្បីប្តឹងសុំទៅតុលាការព្រហ្មទណ្ឌចេញសាលក្រមរឹបអូសជាសម្បត្តិរដ្ឋ ឬ ក៏កម្ទេចចោល។

**ឧទាហរណ៍៖** ក្នុងករណីមានការជួញដូរគ្រឿងញៀនមួយកន្លែងត្រូវបានសមត្ថកិច្ចចុះទៅបង្ក្រាបស្រាប់តែចាប់បាននូវវត្ថុតាងជាគ្រឿងញៀន ម៉ូតូ និងឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនរបស់ជនល្មើសដោយជនល្មើសបានរត់គេចខ្លួនបាត់ទៅ។ សមត្ថកិច្ចបានចាប់យកវត្ថុតាងទាំងនោះមកប្រគល់ជូនព្រះរាជអាជ្ញាដើម្បីធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅលើបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀនមកចៅក្រមស៊ើបសួរ។ បន្ទាប់មកចៅក្រមស៊ើបសួរនឹងស្រាវជ្រាវរកអញ្ញាតជននោះ ដោយឡែកប្រសិនបើនៅតែពុំរកឃើញនូវអត្តញ្ញាណរបស់ជនត្រូវចោទនោះច្បាស់លាស់ទេ។ ចៅក្រមស៊ើបសួរចេញដីកាបញ្ជូនឱ្យសម្រេចរឹបអូសវត្ថុតាងដែលជាគ្រឿងញៀន ម៉ូតូ និងឧបករណ៍សម្រាប់ប្រើប្រាស់គ្រឿងញៀនដែលជាកម្មវត្ថុប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសនោះ ដើម្បីប្តឹងសុំទៅតុលាការព្រហ្មទណ្ឌចេញសាលក្រមរឹបអូសជាសម្បត្តិរដ្ឋ ឬ ក៏កម្ទេចចោលនូវគ្រឿងញៀង និងឧបករណ៍ប្រើប្រាស់គ្រឿងញៀនដោយផ្អែកតាម។[23]

## ១.២ ការលើកលែងការចោទប្រកាន់

ចៅក្រមស៊ើបសួរ ក្រោយពីបានពិនិត្យទៅលើអង្គហេតុចប់សព្វគ្រប់ និងអង្គច្បាប់ដោយស្វែងរកនូវភស្តុតាងមួយចំនួនទាក់ទងទៅនឹងអង្គហេតុដែលតំណាងអយ្យការធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមកចៅក្រមស៊ើបសួរនោះ។ បន្ទាប់មកចៅក្រមស៊ើបសួរបានធ្វើការវាយតម្លៃថា **ពុំមានអំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ ឬ មជ្ឈិម ឬ លហុ(១.២.១) ជនដែលប្រព្រឹត្តអំពើនោះនៅ**

[23] មាត្រា ២៤៧ថ្មី ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។

**តែគេមិនស្គាល់(១.២.២) គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ(១.២.៣) និងករណីដែលបណ្តឹងអាជ្ញារលត់(១.២.៤)។**

### ១.២.១ អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ លហុ

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិនូវគោលការណ៍នីត្យានុកូលភាពដែលជាគោលការណ៍សារវន្តមួយនៃនីតិរដ្ឋ ដែលកំណត់យកច្បាប់ជាគោលដ៏សំខាន់នៃការធ្វើសកម្មភាពនីមួយៗ។ ច្បាប់ព្រហ្មទណ្ឌត្រូវបានបង្កើតឡើង ក្នុងគោលបំណងការពារសិទ្ធិសេរីភាពរបស់បុគ្គលឯកជនផង និងធានារក្សាឱ្យបាននូវសណ្តាប់ធ្នាប់សាធារណៈដែលអាចប៉ះពាល់ដោយបទល្មើសណាមួយផង។ ម៉្យាងទៀត ក្នុងវិស័យព្រហ្មទណ្ឌការដាក់ទណ្ឌកម្មមានលក្ខណៈធ្ងន់ធ្ងរ ហេតុនេះហើយ អ្នកនីតិប្បញ្ញត្តិរមែងមានការប្រយ័ត្នប្រយែងក្នុងការកំណត់ថា អំពើណាមួយជាបទល្មើសព្រហ្មទណ្ឌ ដើម្បីធានាឱ្យបាននូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

ក្រមព្រហ្មទណ្ឌក៏បានចាត់ទុកគោលការណ៍នីត្យានុកូលភាពថា ជាគោលការណ៍ទូទៅមួយ ហើយបានបញ្ញត្តិថា មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន។[24]

ម៉្យាងទៀត គោលការណ៍នីត្យានុកូលភាពក៏ត្រូវបានទទួលស្គាល់ដោយលិខិតតុបករណ៍អន្តរជាតិ **គឺមាត្រា ១៥ កថាខណ្ឌទី២ នៃកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ។[25] បញ្ញត្តិនេះ មានខ្លឹមសារថា គ្មានជនណាម្នាក់ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយចំពោះអំពើ ឬ ធ្វេសប្រហែសណាដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌមាននៅក្រោមច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិនៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត។

អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលត្រូវបានទទួលស្គាល់ដោយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ។ បញ្ញត្តិនេះមានខ្លឹមសារថា គ្មានជនណាម្នាក់ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើ ឬ ការធ្វេសប្រហែសណាមួយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌមាននៅក្រោមច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិនៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត។

---

[24] មាត្រា ៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[25] មាត្រា ៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលចូលជាធរមានថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

យោងតាមបញ្ញត្តិខាងលើនេះ យើងអាចយល់អត្ថន័យនៃគោលការណ៍នីត្យានុកូលភាពជារួមថា ច្បាប់ជាអ្នកកំណត់ថា អំពើណាមួយជាបទល្មើស ឬ មិនមែនជាបទល្មើស ហើយច្បាប់ក៏ជាអ្នកកំណត់ទោសដែលត្រូវបានផ្តន្ទាលើបទល្មើសនោះដែរ។ ហេតុនេះនត្ថិភាពនៃច្បាប់ គឺជាឧបសគ្គសម្រាប់តុលាការក្នុងការប្រកាសថា អំពើមួយជាបទល្មើស និងដាក់ទោសលើជនប្រព្រឹត្តអំពើនោះ។ និយាយមួយបែបទៀតថារាល់ការចោទប្រកាន់ និងការផ្តន្ទាទោសទាំងអស់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់។

ច្បាប់ដែលកើតឡើងខាងលើនេះ គឺជាច្បាប់ក្នុងន័យទូលាយដោយរួមបញ្ចូលទាំងបទដ្ឋានគតិយុត្តចេញដោយអង្គការនីតិប្រតិបត្តិដែរ។ ជាក់ស្តែងក្រមព្រហ្មទណ្ឌ បានអនុញ្ញាតឱ្យអង្គការនីតិប្រតិបត្តិចេញបទដ្ឋានគតិយុត្តកំណត់ពីបទលហុ ក្នុងករណីចាំបាច់ ប៉ុន្តែក្នុងលក្ខខណ្ឌដែលបទលហុនោះត្រូវផ្តន្ទាទោសត្រឹមពិន័យជាប្រាក់ប៉ុណ្ណោះ។[26]

នៅក្នុងនីតិវិជ្ជមានកម្ពុជាបច្ចុប្បន្ន ការអនុវត្តគោលការណ៍នីត្យានុកូលភាពត្រូវបានមើលឃើញយ៉ាងទូលំទូលាយ។ ជាក់ស្តែង ការធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃដោយចេតនា គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងចាប់ពី។[27] ក៏ប៉ុន្តែ ការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃដោយអចេតនា មិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ដោយមូលហេតុថា មិនមានបញ្ញត្តិច្បាប់ចែងទុកជាបទល្មើស លើកលែងតែការធ្វើឱ្យខូចខាតដោយអចេតនា ដោយសារអានុភាពនៃគ្រឿងផ្ទុះ ឬ អគ្គិភ័យ។

ដោយឡែកពាក់ព័ន្ធនឹងទោសវិញ គោលការណ៍នីត្យានុកូលភាពហាមឃាត់ការប្រកាសទោសទាំងឡាយ ដែលច្បាប់មិនបានចែងសម្រាប់បទល្មើសនោះ។ ដូច្នេះ តុលាការមិនអាចប្រកាសទោសពិន័យជាប្រាក់សម្រាប់បទឃាតកម្មបានឡើយ ដោយមូលហេតុថា បញ្ញត្តិនេះមិនបានចែងពីការផ្តន្ទាទោសពិន័យជាប្រាក់។[28] ជាមួយគ្នានេះ ចំពោះបទទ្វេពន្ធភាព តុលាការមិនអាចប្រកាសផ្តន្ទាទោសបន្ថែមណាមួយទៅលើជនល្មើសឡើយ ពីព្រោះថា មិនមានបញ្ញត្តិច្បាប់ដែលចែងពីទោសបន្ថែមសម្រាប់បទល្មើសនេះឡើយ។

---

[26] មាត្រា ១ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[27] មាត្រា ៤១០ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[28] មាត្រា ១៩៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ជាក់ស្តែងបទល្មើសត្រូវបានបែងចែកជាបីចំណាត់ថ្នាក់ ស្របទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើសនីមួយៗ។ ក្នុងន័យនេះ បទល្មើសត្រូវចាត់ថ្នាក់ជា**បទឧក្រិដ្ឋ**( ១.២.១.១ ) **បទមជ្ឈិម**( ១.២.១.២ ) **និង បទលហុ**( ១.២.១.៣ ) ទៅតាមទម្ងន់នៃបទល្មើស។[29]

### ១.២.១.១ បទឧក្រិដ្ឋ

យោងតាមមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និយមន័យនៃបទឧក្រិដ្ឋ ចែងថា បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវទទួលរងៈ

១-ជាទោសដាក់ពន្ធនាគារអស់មួយជីវិត។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ឆ្នាំ និងក្រោម ឬ ស្មើនឹង ៣០ឆ្នាំ។

ទោសដាក់ពន្ធនាគារ អាចត្រូវបានបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

**ឧទាហរណ៍ៈ**

- បទឃាតកម្មគិតទុកជាមុន មានបញ្ញត្តិនៅមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថាៈ
  - ឃាតកម្មគិតទុកជាមុន គឺជាអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬ ដោយការពួនស្ទាក់។
  - ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀនទៅលើបុគ្គលនៃជនរងគ្រោះ។
  - ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។
  - ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

### ១.២.១.២ បទមជ្ឈិម

យោងតាមមាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថាៈ បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ ថ្ងៃ និង ក្រោម ឬ ស្មើនឹង ៥ ឆ្នាំ។ ទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

[29] មាត្រា ២ វាក្យខណ្ឌទី២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

**ឧទាហរណ៍៖**

- អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។[30]

**១.២.១.៣ បទលហុ**

នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬ ស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ដោយទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ មួយវិញទៀត បទល្មើស គឺជាបទលហុ កាលបើបទល្មើសនោះត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

**ឧទាហរណ៍៖**

- បទហិង្សាស្រាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល។[31]

ដូច្នេះ ផ្អែកគោលការណ៍នីតិនុកូលភាព ចៅក្រមស៊ើបសួរត្រូវតែពិនិត្យ និងស្រាវជ្រាវឱ្យបានច្បាស់នូវអង្គហេតុថាតើមានបទល្មើស ហើយថាតើបទល្មើសនោះមានស្ថិតក្នុងចំណាត់ថ្នាក់បទល្មើសទាំងបីនោះដែរ ឬ ទេ? ប្រសិនបើពិនិត្យពុំមានបទល្មើសដែលបានប្រព្រឹត្ត និងស្ថិតក្នុងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចលើកលែងការចោទប្រកាន់ទៅលើជនត្រូវចោទត្រូវដោះលែងឱ្យមានសេរីភាពវិញ ដោយមូលហេតុពុំមានបទល្មើស។

### ១.២.២ ជនដែលប្រព្រឹត្តអំពើនោះជាអញ្ញាតជន

ជាងនេះទៅទៀត នៅក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬ ក្នុងករណីដែលជនត្រូវចោទបានទទួលមរណភាព ចៅក្រមស៊ើបសួរអាចដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីឱ្យតុលាការព្រហ្មទណ្ឌ សម្រេចរឹបអូសឧបករណ៍ មូលនិធិ សម្ភារៈ ផលទុន ឬ ទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសស្រប។[32] **ឧទាហរណ៍៖** អញ្ញាតជន

---

[30] មាត្រា ៣៥៣ និងមាត្រា ៣៥៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[31] មាត្រា ២២៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[32] មាត្រា ២៤៧ថ្មី ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។

(ជនមិនស្គាល់) ត្រូវបានចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ ក៏ប៉ុន្តែ ក្រោយពីបានស្រាវជ្រាវរួចមក ចៅក្រមស៊ើបសួរមិនអាចស្វែងរកអត្តសញ្ញាណរបស់ជនត្រូវចោទបានឡើយ។ ហេតុដូច្នេះ ជាធម្មតាចៅក្រមស៊ើបសួរនឹងចេញដីកាសម្រេចលើកលែងចោទប្រកាន់លើអញ្ញាតជននោះ។ ប្រសិនបើពុំមានអត្តសញ្ញាណគ្រប់គ្រាន់ដើម្បីអាចបញ្ជូនទៅជំនុំជម្រះបានទេ ចៅក្រមស៊ើបសួរអាចលើកលែងការចោទប្រកាន់ ដោយផ្អែកតាមមាត្រា ២៤៧ ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជាក់ស្តែងក្នុងករណីដែលមានអញ្ញាតជនបែបនេះ ចៅក្រមស៊ើបសួរគប្បីត្រូវប្រើប្រាស់នូវវិធានការស្រាវជ្រាវរបស់ខ្លួនដែលជាការចាត់ឱ្យស៊ើបសួរជំនួស ដើម្បីស្រាវជ្រាវបំពេញនូវអត្តសញ្ញាណរបស់ជនត្រូវចោទ។

នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមស៊ើបសួរអាចជួបប្រទះនឹងឧបសគ្គផ្សេងៗដែលនាំឱ្យចៅក្រមស៊ើបសួរពុំអាចបំពេញភារកិច្ចដោយខ្លួនឯងបាន ដែលជាហេតុនាំឱ្យចៅក្រមស៊ើបសួរប្រគល់សិទ្ធិឱ្យអ្នកផ្សេងបំពេញកិច្ចស៊ើបសួរជំនួសខ្លួនបាន។ អនុលោមតាមមាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឱ្យចៅក្រមស៊ើបសួរប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬ ដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបញ្ជាក់ពីកិច្ចដែលត្រូវធ្វើដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងបទល្មើសដែលចោទប្រកាន់ និងត្រូវណែនាំឱ្យបានច្បាស់លាស់ ពោលគឺមិនត្រូវជាការប្រគល់សិទ្ធិជាលក្ខណៈទូទៅទេ ហើយថែមទាំងកំណត់ចិរវេលាដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសទៀតផង។ ចៅក្រមស៊ើបសួរអាចដកហូតដីកានេះបានគ្រប់ពេលវេលា។

ជាទូទៅ រាល់កិច្ចស៊ើបសួរទាំងអស់អាចជាកម្មវត្ថុនៃដីកាចាត់ឱ្យស៊ើបសួរជំនួស។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានដាក់កម្រិតខ្លះ សម្រាប់ការប្រគល់សិទ្ធិឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ចៅក្រមស៊ើបសួរមិនអាចប្រគល់សិទ្ធិឱ្យទៅមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបសួរជំនួសខ្លួនទាក់ទិននឹង៖

- ការសួរចម្លើយជនត្រូវចោទ។
- ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។[33]

នៅក្នុងការបំពេញកិច្ចស៊ើបសួរជំនួសចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌ដែលស្តាប់ចម្លើយសាក្សី ត្រូវឱ្យសាក្សីនោះស្បថជាមុនសិន មុននឹងស្តាប់ចម្លើយ។ ប្រសិនបើមានការឃាត់ខ្លួនក្នុងក្របខ័ណ្ឌ

[33] មាត្រា ១៨០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

នៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ អំណាចដែលប្រគល់ឱ្យព្រះរាជអាជ្ញាត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរ។[34] ហេតុនេះ ប្រសិនបើអញ្ញាតជននៅតែពុំស្គាល់នូវអត្តសញ្ញាណពិតប្រាកដ ឬ ពុំគ្រប់គ្រាន់ដោយសារគ្មានឈ្មោះពិតប្រាកដ និងអត្តសញ្ញាណច្បាស់លាស់ ហើយតំណាងអយ្យការក៏បានស្នើសុំឱ្យចៅក្រមស៊ើបសួរលើកលែងការចោទប្រកាន់លើជនត្រូវចោទរូបនេះ ដោយមូលហេតុគ្មានសាវតាជាតិគ្រប់គ្រាន់ នោះចៅក្រមស៊ើបសួរចេញនូវដីកាសម្រេចលើកលែងការចោទប្រកាន់។[35]

### ១.២.៣ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ

នៅក្នុងដំណើរការនីតិវិធីរបស់ចៅក្រមស៊ើបសួរ នៅពេលដែលតំណាងអយ្យការធ្វើចោទប្រកាន់នូវបទល្មើសណាមួយ ឬ ច្រើនតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវធ្វើការពិនិត្យទៅលើអង្គហេតុ ភស្តុតាងដើម្បីស្វែងរកនូវភស្តុតាងដាក់បន្ទុក និងដោះបន្ទុកទៅលើជនត្រូវចោទ ហេតុនេះចៅក្រមស៊ើបសួរត្រូវធ្វើកោសលវិច័យទៅលើវត្ថុចាប់យកនោះដើម្បីឱ្យបានឃើញនូវការពិតព្រមទាំងវាយតម្លៃថាមានបទល្មើស ឬ មិនមានបទល្មើសកើតឡើង។

ក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬ តាមពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ដោយចេញដីកាចាត់តាំងអ្នកជំនាញ បញ្ជាក់ពីបេសកកម្មរបស់អ្នកជំនាញ និងរយៈពេលដែលត្រូវបំពេញបេសកកម្មនេះ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ តែអ្នកជំនាញអាចអនុញ្ញាតឱ្យពន្យារពេលបាន។[36] ក្នុងករណីដែលត្រូវប្រគល់វត្ថុចាប់យកជូនអ្នកជំនាញ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់វត្ថុចាប់យក។ អ្នកជំនាញបំពេញបេសកកម្មរបស់ខ្លួនក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវចាត់តាំងអ្នកជំនាញដែលមានក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញដែលរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[37] អ្នកជំនាញត្រូវស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញ។ ហើយចៅក្រមស៊ើបសួរអាចចាត់តាំង

[34] មាត្រា ១៨២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[35] មាត្រា ២៤៧ថ្មី ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។

[36] មាត្រា ១៦៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[37] មាត្រា ១៦៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

អ្នកជំនាញដែលមិនមានឈ្មោះក្នុងបញ្ជីអ្នកជំនាញបាន តាមដីកាដោយមានសំអាងហេតុជាពិសេសតែត្រូវឱ្យអ្នកជំនាញនោះស្បថសិន មុននឹងបំពេញបេសកកម្ម។ **ឧទាហរណ៍** មានតែអ្នកជំនាញប៉ុណ្ណោះដែលអាចកំណត់បានថា៖

- លោហធាតុពណ៌លឿង គឺជាមាស ឬ មិនមែន (**អ្នកជំនាញ ៖ ជាងទង**)
- ម្សៅក្រាមពណ៌ស មានវត្តមានសារធាតុញៀន (**អ្នកជំនាញ ៖ វិស្វករគីមី**)
- តើជនរងគ្រោះស្លាប់ ដោយសារមូលហេតុអ្វីឱ្យប្រាកដ? (**អ្នកជំនាញ ៖ វេជ្ជបណ្ឌិត**)។

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន អ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទ ហើយបុគ្គលនោះមិនបាច់ស្បថទេ។ ប៉ុន្តែប្រសិនបើយល់ឃើញថាចាំបាច់ត្រូវស្តាប់ចម្លើយជនត្រូវចោទ អ្នកជំនាញត្រូវសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ជនត្រូវចោទអាចសុំឱ្យអ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួនចំពោះមុខមេធាវី ប៉ុន្តែបើជាការពិនិត្យវេជ្ជសាស្ត្រ ឬ ចិត្តសាស្ត្រត្រូវធ្វើដោយគ្មានវត្តមានរបស់មេធាវីបាន។ ក្រោយពីការបំពេញបេសកកម្មរបស់ខ្លួនរួចហើយ អ្នកជំនាញត្រូវធ្វើរបាយការណ៍។[38] ក្រោយពីទទួលបានរបាយការណ៍កោសលវិច័យ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ហើយកោះហៅជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃលទ្ធផលកោសលវិច័យនេះ។ ក្រោយពីបានដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យរួចហើយ ព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យ ក្នុងរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ តែរយៈពេលនេះមិនអាចតិចជាង ១០ ថ្ងៃទេ។ ប្រសិនបើមានពាក្យសុំយ៉ាងដូច្នេះ ហើយប្រសិនបើចៅក្រមស៊ើបសួរពុំព្រមធ្វើតាមពាក្យសុំទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុក្នុងរយៈពេល ៥ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និងរយៈពេល ១ខែ ប្រសិនបើពាក្យសុំចេញពីជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ ដោយឡែកប្រសិនបើការធ្វើកោសលវិច័យរួចហើយជាលទ្ធផលអវិជ្ជមាននោះ ដោយគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចលើកលែងការចោទប្រកាន់ដោយដោះលែងជនត្រូវចោទឱ្យមានសេរីភាពឡើងវិញដោយអនុលោមតាម។[39]

[38] មាត្រា ១៦៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[39] មាត្រា ២៤៧ថ្មី ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។

**ឧទាហរណ៍៖** ក្នុងបទល្មើសរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ដែលមានទម្ងន់ ១,១០ ក្រាម ត្រូវបានតំណាងអយ្យការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមកចៅក្រមស៊ើបសួរ។ នៅក្នុងករណីនេះចៅក្រមស៊ើបសួរនឹងប្រើប្រាស់នូវវិធានការស្រាវជ្រាវដើម្បីស្វែងរកការពិតថាពិតជាមានបទល្មើសនេះប្រាកដដែរ ឬ ទេ។ ហេតុនេះ ចៅក្រមស៊ើបសួរពុំអាចវាយតម្លៃបានថាគ្រឿងញៀននោះពិតជាមានសារធាតុញៀនបានទេ។ គប្បីចៅក្រមស៊ើបសួរត្រូវចាត់តាំងអ្នកជំនាញ(វិស្វករគីមី) ដើម្បីធ្វើកោសលវិច័យទៅលើគ្រឿងញៀនថា មានភាគសុទ្ធដែរ ឬ ទេ។ ជាលទ្ធផលពុំមានសារធាតុញៀននោះទេ ដូច្នេះពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើបទល្មើសរក្សាទុកដោយខុសច្បាប់នូវសារធាតុ ចៅក្រមត្រូវចេញដីកាសម្រេចលើកលែងការចោទប្រកាន់ផ្អែកតាមមាត្រា ២៤៧ ថ្មី នៃក្រមនីតីវិធីព្រហ្មទណ្ឌ។

### ១.២.៤ ករណីដែលបណ្ដឹងអាជ្ញារលត់

បណ្ដឹងអាជ្ញា គឺជាបណ្ដឹងដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនត្រូវចោទ និងផ្ដន្ទាទោសជននេះតាមច្បាប់កំណត់។[40] មូលហេតុនៃការរំលត់បណ្ដឹងអាជ្ញា។[41] ហេតុនេះស្របតាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ញត្តិអំពីការរលត់នៃបណ្ដឹងអាជ្ញា ដែលបានចែងថា មូលហេតុនៃការរលត់បណ្ដឹងអាជ្ញាមានដូចជា **មរណភាពនៃជនល្មើស**( ១.២.៤.១ ) **ការផុតអាជ្ញាយុកាល**( ១.២.៤.២ ) **ការលើកលែងទោសជាទូទៅ**( ១.២.៤.៣ ) **និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ**( ១.២.៤.៤ ) និង**អាជ្ញាអស់ជំនុំ**( ១.២.៤.៥ )។ កាលណាបណ្ដឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្ដើមទៀតទេ ឬ ត្រូវតែបញ្ឈប់។ ដោយឡែកមាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ញត្តិអំពីមូលហេតុផ្សេងទៀតនៃការរលត់បណ្ដឹងអាជ្ញា ដែលបានចែងថា កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្ដឹងអាជ្ញាក៏អាចផុតរលត់បានដែរ **ដោយការសម្របសម្រួលជាមួយរដ្ឋ**( ១.២.៤.៦ ) **ដោយការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល** ( ១.២.៤.៧ ) នៅក្នុងករណីដែលពាក្យប្ដឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ និង**ដោយការដកពាក្យបណ្ដឹង** ( ១.២.៤.៨ )។

---

[40] មាត្រា ២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[41] មាត្រា ៧ និងមាត្រា ៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**១.២.៤.១ មរណភាពនៃជនល្មើស**

ប្រសិនបើជនត្រូវចោទទទួលមរណភាពមុនពេលមានបណ្តឹងអាជ្ញា ឬ ស្លាប់មុនពេលមានសេចក្តីសម្រេចស្ថាពរផ្តន្ទាទោសជនល្មើស បណ្តឹងអាជ្ញាត្រូវរលត់។ ប៉ុន្តែ បណ្តឹងរដ្ឋប្បវេណីនៅតែអាចបន្តទៀតបានជាមួយនឹងសន្តតិជនរបស់ជនត្រូវចោទ។ បញ្ជាក់ថា ប្រសិនបើជនត្រូវចោទទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌ ទោះបីជា បណ្តឹងអាជ្ញារលត់ក៏ដោយ ក៏តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តរបស់ជនត្រូវចោទបានដែរ។[42] នៅក្នុងករណីនេះ មានន័យថា ទោះបីជាជនត្រូវចោទបានរួចផុតពីការចោទប្រកាន់ដោយសារតែមរណភាពនៃជនត្រូវចោទក៏ដោយ ក៏មិនមានន័យថាជនត្រូវចោទបានរួចផុតពីសំណងរដ្ឋប្បវេណីបានឡើយ។

**១.២.៤.២ ការផុតអាជ្ញាយុកាល**

ជាទូទៅ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានរលត់ដោយសារហួសអាជ្ញាយុកាល គេនៅតែអាចទាមទារសំណងជម្ងឺចិត្តបានដដែល។[43] តាមច្បាប់ព្រហ្មទណ្ឌអន្តរកាល អាជ្ញាយុកាលនៃបទល្មើស គឺ ៣ (បី) ឆ្នាំ សម្រាប់បទមជ្ឈិម និង ១០ (ដប់) ឆ្នាំ សម្រាប់បទឧក្រិដ្ឋ។[44]

យោងតាមមាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ញត្តិអំពីអាជ្ញាយុកាលនៃបទល្មើស ដែលបានចែងថា លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះចេញ ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម និង ១ (មួយ) ឆ្នាំ ចំពោះបទលហុ។

យោងតាមមាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ញត្តិអំពីឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់ ដែលចែងថា បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចផុតអាជ្ញាយុកាលបានទេ។

[42] មាត្រា ២៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[43] មាត្រា ៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[44] មាត្រា ៣០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ចំណែកឯក្នុងរឿងទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល អាជ្ញាយុកាលមានរយៈពេល ៣ (បី) ឆ្នាំ និង ១០ (ដប់) ឆ្នាំ។[45] ការកំណត់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលចំនួន ៥ (ប្រាំ) ឆ្នាំ។[46] ប្រសិនបើអាជ្ញាយុកាលផ្នែករដ្ឋប្បវេណីកំណត់ដោយច្បាប់មានរយៈពេលវែងជាងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ការផុតអាជ្ញាយុកាលនៃបទល្មើសពុំអាចជាឧបសគ្គរាំងដល់ជនរងគ្រោះប្តឹងផ្តល់ទៅតុលាការរដ្ឋប្បវេណីដើម្បីទាមទារសំណងការខូចខាតនោះទេ។

ការរាប់រយៈពេលអាជ្ញាយុកាលមានភាពខុសប្លែកគ្នាទៅតាមថាជាបទល្មើសភ្លាមៗ ឬ ជាបទល្មើសអូសបន្លាយ។ ជាគោលការណ៍ ចិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស (មាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ប៉ុន្តែមានករណីលើកលែងខ្លះចំពោះបទល្មើសអូសបន្លាយ ឬ បន្តរៀងហូរហែរ។

ម្យ៉ាងវិញទៀត អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ។[47] ការបញ្ចប់កិច្ចចោទប្រកាន់ ឬ កិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្តើមគិតចិរវេលានៃអាជ្ញាយុកាល។ ចិរវេលាថ្មីនេះអាចយកទៅជំទាស់បានចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ។

**១.២.៤.៣ ការលើកលែងទោសជាទូទៅ**

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានសម្លេងគាំទ្រអនុម័តចំនួន ២ ភាគ ៣ ។[48] ការលើកលែងទោសជាទូទៅ ជាវិធានការនីតិកម្មដែលមានគោលដៅលុបចោលនូវលក្ខណៈជាបទល្មើសរបស់អំពើមួយចំនួន។ ការលើកលែងទោសជាទូទៅ ស្ថិតក្នុងអំណាចរបស់អង្គការនីតិបញ្ញត្តិ។[49] ច្បាប់លើកលែងទោសជាទូទៅអាចអនុម័តបានដោយមានមូលហេតុច្រើនយ៉ាងដូចជា កុំឱ្យមានទណ្ឌិតក្នុងពន្ធនាគារច្រើនពេក។ ច្បាប់លើកលែងទោសជាទូទៅអាចពាក់ព័ន្ធទាំងទណ្ឌកម្មព្រហ្មទណ្ឌ និងទណ្ឌកម្មរដ្ឋបាល។ ច្បាប់លើកលែងទោសជាទូទៅកំណត់ច្បាស់លាស់ដោយខ្លួនឯងពីកាលបរិច្ឆេទដែលក្នុងនោះការប្រព្រឹត្តបទល្មើសត្រូវលើកលែង

[45] មាត្រា ៧៦៥ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[46] មាត្រា ៤៨២ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

[47] មាត្រា ១១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[48] មាត្រា ៩០ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[49] មាត្រា ៩០ថ្មី រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។

ឬ ពីប្រភេទនៃបទល្មើសដែលត្រូវលើកលែង ឬ ពីទោសប្រកាសដែលត្រូវលើកលែង (ឧ.ទណ្ឌិតដែលត្រូវផ្តន្ទាទោសដោយតុលាការពី ៣ ខែ ដល់ ៣ ឆ្នាំ ត្រូវលើកលែង) ឬ ក៏ពីគុណសម្បត្តិរបស់ចារីបទល្មើសដែលត្រូវលើកលែងទោស (ឧ.ចារីដែលមានអាយុក្រោម ២៥ ឆ្នាំ)។ល។ ជាទូទៅ ក្នុងករណីខាងក្រោយនេះ ច្បាប់លើកលែងទោសជាទូទៅតម្រូវឱ្យទណ្ឌិតដែលមានអាយុក្រោម ២៥ឆ្នាំ ធ្វើពាក្យស្នើសុំថ្វាយព្រះមហាក្សត្រក្នុងរយៈពេលណាមួយជាកំណត់ ហើយព្រះរាជក្រឹត្យនឹងធ្វើការលើកលែងទោសបន្ទាប់ពីមានការសិក្សាទៅលើករណីនីមួយៗ។ ការលើកលែងទោសដែលកំណត់ដោយច្បាប់ក៏អាចមានលក្ខខណ្ឌផងដែរ។ ឧទាហរណ៍ៈត្រូវបង់ប្រាក់ពិន័យឱ្យអស់ជាដើម។ ច្បាប់ស្តីពីការលើកលែងទោសជាទូទៅអាចកំណត់ថា បទល្មើសមួយចំនួនមិនទទួលផលលើកលែងទោសជាទូទៅ គឺភេរវកម្ម។ ច្បាប់ស្តីពីការលើកលែងទោសជាទូទៅកំណត់ពីទោសបន្ថែមទាំងឡាយដែលច្បាប់ធ្វើការលើកលែង។

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅមានអានុភាពលុបចោលដោយប្រតិសកម្មនូវការផ្តន្ទាទោសអំពើល្មើស។ អំពើល្មើសដែលទទួលបាននូវការលើកលែងទោស ត្រូវបានគេចាត់ថា មិនមែនជាបទល្មើសឡើយ។ ដូចនេះ ការលើកលែងទោសជាទូទៅមានអានុភាពដូចខាងក្រោមៈ

- អំពើល្មើសដែលទទួលបាននូវការលើកលែងទោសមិនទាន់ត្រូវបានវិនិច្ឆ័យដោយតុលាការនៅឡើយៈ បណ្តឹងអាជ្ញាត្រូវរលត់ ចៅក្រមមិនអាចផ្តន្ទាទោសចារីបានឡើយ។ ប្រសិនបើការលើកលែងទោសធ្វើឡើងដោយអនុលោមទៅតាមអត្រាទោសដែលប្រកាស គឺចៅក្រមត្រូវប្រកាសទោសជាមុនសិន ទើបអាចដឹងថាចូលទៅក្នុងអត្រាដែលត្រូវលើកលែងទោស ឬ អត់។
- ប្រសិនបើមានការផ្តន្ទាទោសជាស្ថាពរ ការផ្តន្ទាទោសនោះត្រូវទុកជាឥតបានការ។

ច្បាប់លើកលែងទោសជាទូទៅលុបចោលនូវការផ្តន្ទាទោស ហេតុនេះគេត្រូវលុបការផ្តន្ទាទោសចេញពីបញ្ជីថ្កោលទោស។ បើជនជាប់ទោសកំពុងតែរងទោសពន្ធនាគារ នោះត្រូវដោះលែងភ្លាម។ ប៉ុន្តែប្រសិនបើជនជាប់ទោសបានបង់ប្រាក់ពិន័យរួចហើយ ជនជាប់ទោសពុំអាចទារសងវិញបានឡើយ។ ការលើកលែងទោសជាទូទៅមិនមែនជាឧបសគ្គក្នុងការទាមទារសំណងជម្ងឺចិត្តចំពោះជនរងគ្រោះទេ។

### ១.២.៤.៤ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

ប្រសិនបើច្បាប់ព្រហ្មទណ្ឌចាស់ដែលកំណត់បទល្មើសណាមួយ ត្រូវបាននិរាករណ៍ដោយច្បាប់ថ្មីដែលលុបចោលបទល្មើសនោះ បណ្តឹងអាជ្ញាទាក់ទិននឹងបទល្មើសដែលបានប្រព្រឹត្តក្នុងអំឡុងពេល

ដែលច្បាប់ចាស់នៅជាធរមានត្រូវរលត់។[50] **ឧទាហរណ៍** ៖ ប្រសិនបើបទល្មើសបួន់មានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលថា ជាបទល្មើស ស្រាប់តែក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចូលជាធរមានចែងថា បទបួន់លែងជាបទល្មើសនោះ ជនជាប់ចោទ ឬ ទណ្ឌិតដែលកំពុងជាប់នៅពន្ធនាគារត្រូវបានដោះលែងវិញ ពីព្រោះបទបួន់ត្រូវបាននិរាករណ៍។

**១.២.៤.៥ អាជ្ញាអស់ជំនុំ**

ប្រសិនបើក្នុងរឿងព្រហ្មទណ្ឌ តុលាការបានសម្រេចសេចក្តីដាក់ជនត្រូវចោទនោះ គឺបានសម្រេចសេចក្តីថា ជនត្រូវចោទមានកំហុស ហេតុដូច្នេះ បណ្តឹងរដ្ឋប្បវេណីនឹងទទួលបានជោគជ័យដោយស្វ័យប្រវត្តិ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការសម្រេចឱ្យជនត្រូវចោទរួចផុតពីបទចោទប្រកាន់ ជនរងគ្រោះក៏ពុំអាចទទួលបាននូវសំណងការខូចខាតពីជនត្រូវចោទដែរ។ ប៉ុន្តែ ក្នុងករណីខ្លះ ទោះបីជាតុលាការឱ្យជនត្រូវចោទរួចផុតពីបទចោទប្រកាន់ក៏ដោយ ក៏ជនរងគ្រោះនៅតែអាចទទួលសំណងដែរ ពីព្រោះថាអំពើរបស់ជនត្រូវចោទពុំមែនជាបទល្មើស តែជាអំពើល្មើសផ្នែករដ្ឋប្បវេណី។ ក្នុងករណីដែលជនត្រូវចោទម្នាក់ត្រូវបានតុលាការរួចផុតពីការចោទប្រកាន់ពីបទហិង្សាដោយចេតនា ហេតុនេះទោះបីជាជនត្រូវចោទត្រូវបានរួចផុតអំពីការចោទប្រកាន់យ៉ាងណាក្តី ជនត្រូវចោទនោះ ក៏ត្រូវសងសំណងការខូចខាតដល់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ជាគោលការណ៍មិនអាចជំនុំជម្រះពីរដងលើរឿងតែមួយនាំឱ្យមានផលវិបាកដូចតទៅ បណ្តឹងអាជ្ញាពុំអាចធ្វើទៀតបានទេ ប្រសិនបើមានសាលក្រមតុលាការសម្រេចដោះលែងជនត្រូវចោទ ចំពោះអំពើដដែលនេះ ទោះបីជាក្រោយពេលមានសាលក្រមស្ថាពរហើយ គេរកឃើញភស្តុតាងដាក់បន្ទុកថ្មីក៏ដោយ។

ជាក់ស្តែងនៅពេលដែលតុលាការបានចេញសាលក្រម ឬ សាលដីកាសម្រេចដោះលែងជនត្រូវចោទរួចជាស្រេចហើយ ទោះបីជាពេលក្រោយមកតុលាការបានរកឃើញនូវភស្តុតាងដាក់បន្ទុកថ្មីដែល**គោលការណ៍មិនអាចជំនុំជម្រះពីរដងលើរឿងក្តីតែមួយបានទេ**។ ផ្អែកតាម**មាត្រា ១២** នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "**ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតទេចំពោះអំពើដដែលទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ**"។ ករណីនេះមានន័យថា នៅពេលដែលតុលាការបានចេញសាលក្រមសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយស្រាប់តែតុលាការបានរកភស្តុតាងដែលអាចដាក់បន្ទុកចោទប្រកាន់ជននោះ

[50] មាត្រា ៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ពីបទល្មើសថ្មីមួយទៀតក៏ដោយ ក៏តុលាការមិនអាចធ្វើការចោទប្រកាន់បានឡើយ ដោយផ្អែកលើគោលការណ៍មិនអាចជំនុំជម្រះពីរដងលើរឿងក្តីតែមួយ។

**១.២.៤.៦ ការសម្របសម្រួល**

ជាគោលការណ៍ ការសម្រុះសម្រួលមិនអាចធ្វើទៅបានឡើយ ចំពោះបទល្មើសព្រហ្មទណ្ឌ។ ប៉ុន្តែច្បាប់ពិសេសអាចអនុញ្ញាតឱ្យរំលត់បណ្តឹងអាជ្ញាបានផងដែរ។ ប្រសិនបើការសម្របសម្រួលនាំឱ្យមានការរំលត់បណ្តឹងអាជ្ញា នោះការសម្របសម្រួលនោះក៏ទាក់ទិននឹងបណ្តឹងរដ្ឋប្បវេណីដែរ។ ហេតុនេះ ជាធម្មតាមិនចោទជាបញ្ហាអំពីបញ្ហាបណ្តឹងរដ្ឋប្បវេណីឡើយ។ ប៉ុន្តែ ការរលត់បណ្តឹងអាជ្ញាតាមរូបភាពសម្របសម្រួលនេះ ពុំមែនជាមូលហេតុនៃការរលត់បណ្តឹងរដ្ឋប្បវេណីទេ មានន័យថា ជនរងគ្រោះនៅតែអាចដាក់ពាក្យប្តឹងក្នុងរឿងរដ្ឋប្បវេណីបាន។

**១.២.៤.៧ ការបង់ប្រាក់ពិន័យសរុប ឬ ការបង់ប្រាក់ពិន័យសម្របសម្រួល**

ពាក់ព័ន្ធនឹងការពិន័យអន្តរកាល ឧទាហរណ៍ការពិន័យពេលដែលមានការបំពានកាតព្វកិច្ចពេលបើកបរតាមដងផ្លូវដោយការមិនគោរពភ្លើងចរាចរណ៍ ឬ មិនពាក់មួកសុវត្ថិភាព ឬ មិនពាក់ខ្សែក្រវ៉ាត់អំឡុងពេលបើកបរដែលមានចែងនៅច្បាប់ចរាចរណ៍ផ្លូវគោក នោះត្រូវពិន័យត្រឹមការពិន័យអន្តរកាលប៉ុណ្ណោះ។

**១.២.៤.៨ ការដកពាក្យប្តឹង**

ការដកពាក្យប្តឹងដោយជនរងគ្រោះពុំអាចធ្វើឱ្យអាជ្ញាយុកាលនៃបណ្តឹងអាជ្ញារលត់ទេ។ ប៉ុន្តែចំពោះបទល្មើសមួយចំនួន ការដកបណ្តឹងរបស់អ្នកទទួលការខូចខាតនាំឱ្យរលត់បណ្តឹងអាជ្ញាដែរ។ ចំពោះការចាត់ទុកការដកពាក្យប្តឹងជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញា ក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ។[51] ចាត់ទុកដូចជា ការដកពាក្យបណ្តឹងដោយជនរងគ្រោះដែរ ករណីដែលថា ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជន ដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬ បទលហុ។[52] ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញានោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះ

[51] មាត្រា ៨ ចំណុចទី២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[52] មាត្រា ៣៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥។

ម្តងទៀតក៏ដោយ។ បណ្តឹងរដ្ឋប្បវេណីក៏ត្រូវរលត់ដែរ ប្រសិនបើមានមូលហេតុផ្សេងទៀតដែលនាំឱ្យរលត់កាតព្វកិច្ច យោងតាមច្បាប់រដ្ឋប្បវេណី។ ហេតុនេះ ប្រសិនបើមានករណីដោយបណ្តឹងអាជ្ញាត្រូវបានរលត់ ចៅក្រមស៊ើបសួរ និងធ្វើការលើកលែងចោទប្រកាន់តាមរយៈដីកាសម្រេចលើកលែងការចោទប្រកាន់។[53]

[53] មាត្រា ២៤៧ថ្មី ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។

# ជំពូកទី ២
# នីតិវិធីនៃការចេញដីកាដំណោះស្រាយ

# ជំពូកទី ២
# នីតិវិធីនៃការចេញដីកាដំណោះស្រាយ

កាលបើការបំពេញកិច្ចស៊ើបសួរត្រូវបានបញ្ចប់ ដំណើរការនីតិវិធីនៃដីកាដំណោះស្រាយដើម្បីចេញនូវដីកាដំណោះស្រាយ និងអត្ថន័យនៃដីកាដំណោះស្រាយដែលត្រូវបកស្រាយឱ្យបានលម្អិតឱ្យបានច្បាស់លាស់នូវចំណុច**អ្នកមានសមត្ថកិច្ចចេញដីកាដំណោះស្រាយ** (២.១) **និងលំហូរនីតិវិធីនៃការចេញដីកាដំណោះស្រាយ** (២.២)។

## ២.១ អ្នកមានសមត្ថកិច្ចចេញដីកាដំណោះស្រាយ

ដីកាដំណោះស្រាយជាដីកាដែលបិទការស៊ើបសួរ ជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ ហេតុនេះដីកាដំណោះស្រាយសម្រេចពីការប្រគល់សងទៅឱ្យម្ចាស់ដើមវិញនូវវត្ថុចាប់យក (ក្នុងករណីដែលជាដីកាលើកលែងចោទប្រកាន់)។ ដីកាដំណោះស្រាយនាំឱ្យបិទការស៊ើបសួរដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។ ហេតុនេះ ដីកានេះនាំឱ្យសេចក្តីសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្ន ឬ ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវបញ្ចប់។ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ ឬ រក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។[54]

## ២.២ លំហូរនីតិវិធីនៃការចេញដីកាដំណោះស្រាយ

នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា នីតិវិធីនៃការចេញដីកាដំណោះស្រាយ គឺត្រូវមានការបើកការស៊ើបសួរ និងបិទការស៊ើបសួររួចរាល់ ហើយត្រូវបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញាពិនិត្យដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ(RD) រួចទើបចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយត្រូវមាន**ការបើកការស៊ើបសួរ**(**២.២.១**) **និងការបិទការស៊ើបសួរ**(**២.២.២**)។

### ២.២.១ ការបើកការស៊ើបសួរ

ចៅក្រមស៊ើបសួរ គឺជាចៅក្រមដែលមានតួនាទីស្វែងរកការពិតដោយធ្វើការស៊ើបសួរទាំងដោះបន្ទុក និងដាក់បន្ទុកលើជនត្រូវចោទ។ ជាធម្មតា ការស៊ើបសួរ គឺជាកិច្ចនីតិវិធីព្រហ្មទណ្ឌដែលធ្វើឡើងបន្ទាប់ពីតំណាងអយ្យការសម្រេចធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរដោយចេញដីកាសន្និដ្ឋានបញ្ជូន

[54] មាត្រា ២៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

រឿងឱ្យស៊ើបសួរ។ នៅក្នុងការកំណត់អត្តិភាពនៃបទល្មើសដែលត្រូវបានចោទប្រកាន់ ចៅក្រមស៊ើបសួរប្រើប្រាស់វិធានការសំខាន់ៗចំនួនពីរគឺ**វិធានការស្រាវជ្រាវ**(២.២.១.១) **និងវិធានការនិរន្តរាយ**(២.២.១.២)។

### ២.២.១.១ វិធានការស្រាវជ្រាវ

ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួននៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូងដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ដូចជាការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង។ ក្រៅពីការចុះទៅដល់ទីកន្លែង ចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវតាមរយៈកិច្ចស៊ើបសួរដូចជាការសួរចម្លើយជនត្រូវចោទ។ ប៉ុន្តែ មុននឹងសួរចម្លើយ ចៅក្រមស៊ើបសួរត្រូវដាក់ជននេះឱ្យស្ថិតនៅក្រោមការពិនិត្យនីតិវិធី។[55] វិធានការស្រាវជ្រាវមានដូចជា ការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ការឆែកឆេរ និងការចាប់យកវត្ថុតាង កោសលវិច័យ ការស្តាប់ទូរស័ព្ទ ការចាត់ឱ្យស៊ើបសួរជំនួស។

- **ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ**

ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ បន្ថែមពីនេះ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។ ការដាក់ឱ្យស្ថិតក្រោមការពិនិត្យធ្វើក្រោមការពិនិត្យធ្វើនៅពេលចូលបង្ហាញខ្លួនលើកដំបូង ដោយចៅក្រមស៊ើបសួរត្រូវអនុវត្ត។[56]

- **ការសួរចម្លើយជនត្រូវចោទ**

ការសួរចម្លើយជនត្រូវចោទអាចធ្វើនៅចំពោះមុខមេធាវីរបស់ជនត្រូវចោទ។ ប៉ុន្តែប្រសិនបើមេធាវីត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាច

[55] មាត្រា ១២៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[56] មាត្រា ១៤៣ និងមាត្រា ១៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

សួរចម្លើយ ជនត្រូវចោទដោយគ្មានវត្តមានមេធាវីបាន។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនចាំបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះ ត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង។ នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកសំណួរបានដែរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។[57] ក្នុងករណីមិនអនុញ្ញាត ករណីនោះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់សិទ្ធិឱ្យជនត្រូវចោទស្នើសុំឱ្យចៅក្រមសួរស៊ើបសួរចម្លើយខ្លួន ឬ តទល់ កាលណាចិរវេលា ៤ខែបានកន្លងផុតទៅចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមកោះហៅក្នុងចិរវេលា ១ (មួយ) ខែ បន្ទាប់ពីការស្នើសុំជនត្រូវចោទអាចប្តឹងទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯង។ កំណត់ហេតុសួរចម្លើយនេះត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។

- **ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី**

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលមកបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានរបស់មេធាវី។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានដោយមិនបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបោះចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចស្តាប់ស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយមិនចាំបាច់កោះហៅមេធាវីបាន។ ភាពបន្ទាន់នេះ ត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬ បណ្តាលមកពីខ្លាចបាត់បង់តម្រុយភស្តុតាង។ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសម្តែងឱ្យឃើញការពិត។ ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សី ក្រោយពីសាក្សីស្បថរួច លើកលែងតែករណីដែលសាក្សីដែលអនុញ្ញាតឱ្យរួចផុតពីសម្បថ។[58] ចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយក្នុងឋានៈ ជាសាក្សីនូវបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ។[59]

---

[57] មាត្រា ១៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[58] មាត្រា ១៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[59] មាត្រា ១៥៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ក្នុងករណីនេះ ចៅក្រមត្រូវប្តូរនីតិវិធីទៅជាការដាក់សាក្សីដែលមានតម្រុយពិរុទ្ធភាពឱ្យស្ថិតក្រោមការពិនិត្យ។[60]

- **ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន ការឆែកឆេរត្រូវអនុលោមទៅតាមនីតិវិធី។[61] ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ត្រូវធ្វើនៅចំពោះមុខសាក្សីចំនួនពីរនាក់ដែលចៅក្រមស៊ើបសួរបានចាត់ចែង។ សាក្សីនេះ មិនអាចជានគរបាល ឬ កងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។ ការឆែកឆេរមិនអាចចាប់ផ្តើមមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ៦ ល្ងាចលើកលែងតែៈ

- ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហរដល់សាធារណជន។
- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន។

ប្រសិនបើជាការឆែកឆេរនៅការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវី។ ចៅក្រមស៊ើបសួរត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការឆែកឆេរ។ ក្រៅពីនេះ ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាងបាន តែត្រូវបិទស្លាកបោះត្រាលើវត្ថុតាង ហើយត្រូវធ្វើកំណត់ហេតុពីការចាប់យក រួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក ក្រោយពីបានបង្ហាញវត្ថុចាប់យកដល់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីចំនួនពីរនាក់។

- **កោសលវិច័យ**

ក្នុងករណីដែលមានបញ្ហាបច្ចេកទេសកើតឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬ តាមពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរសម្រេចតាមដីកាសម្រេចដោយមានសំអាងហេតុ។ ម្យ៉ាងវិញទៀត ចៅក្រមត្រូវចេញដីកាចាត់តាំងអ្នកជំនាញ ដោយ

[60] មាត្រា ១៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[61] មាត្រា ១៥៩ និងមាត្រា ១៦០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

បញ្ជាក់ពីបេសសកម្មរបស់អ្នកជំនាញ និងរយៈពេលដែលត្រូវបំពេញបេសសកម្មនោះ តែអ្នកជំនាញអាចអនុញ្ញាតឱ្យពន្យាពេលបាន។ អ្នកជំនាញបំពេញបេសសកម្មរបស់ខ្លួនក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ។ ក្រោយពីបំពេញបេសកកម្មរបស់ខ្លួនរួចហើយ អ្នកជំនាញត្រូវធ្វើរបាយការណ៍។[62] ក្រោយពីទទួលបានរបាយការណ៍កោសលវិច័យ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ហើយកោះហៅជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យនេះ។ ក្រោយពីបានដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យរួចហើយ ព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យសុំធ្វើកោលសវិច័យបន្ថែម ឬ ប្រតិកោលសវិច័យក្នុងរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរ តែរយៈពេលនេះមិនអាចតិចជាង១០ថ្ងៃទេ។ ប្រសិនបើមានពាក្យសុំយ៉ាងដូច្នេះ ចៅក្រមស៊ើបសួរពុំព្រមធ្វើតាមពាក្យសុំចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុក្នុងរយៈពេល៥ថ្ងៃ ប្រសិនបើពាក្យសុំមកពីព្រះរាជអាជ្ញា និងរយៈពេល១ខែប្រសិនបើពាក្យសុំចេញពីជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។

- **ការស្តាប់ទូរស័ព្ទ**

ការស្តាប់ទូរស័ព្ទ គឺជាវិធានការមួយដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិបុគ្គលឯកជន ដែលធានាដោយរដ្ឋធម្មនុញ្ញ ទាក់ទិននឹងការរក្សាការសម្ងាត់នៃការឆ្លងឆ្លើយគ្នា។ ហេតុនេះ ទើបក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យតែចៅក្រមស៊ើបសួរប៉ុណ្ណោះដែលមានសិទ្ធិអំណាចបង្គាប់ឱ្យស្តាប់ទូរស័ព្ទបាន។ ការផ្តល់សិទ្ធិឱ្យចៅក្រមស៊ើបសួរក្នុងការបង្គាប់ឱ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ បង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លងឆ្លើយគ្នាតាមមធ្យោបាយទូរគមនាគមន៍ផ្សេងទៀតដូចជាសារតាមទូរសារតាមអ៊ិនធឺណេត។[63] ចៅក្រមស៊ើបសួរចេញដីកាសម្រេចដើម្បីអង្គភាពសាធារណៈ ឬ មន្ត្រីសាធារណៈ ឬ មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថតដោយបញ្ជាក់ពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ថត និងរយៈពេលនៃបេសកកម្មនេះផង។ ក្រោយពីបញ្ចប់បេសកកម្មនេះ អង្គភាពនេះ អង្គភាពសាធារណៈ ឬ មន្ត្រីរាជការត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសម្លេងដែលថតបានហើយប្រគល់ឯកសារនេះ និងសម្លេងថតបានឱ្យទៅចៅក្រមស៊ើបសួរ។

[62] មាត្រា ១៦៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[63] មាត្រា ១៧២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

- **ការចាត់ឱ្យស៊ើបសួរជំនួស**

នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមស៊ើបសួរអាចជួបប្រទះនឹងឧបសគ្គផ្សេងៗដែលនាំឱ្យចៅក្រមស៊ើបសួរពុំអាចបំពេញភារកិច្ចដោយខ្លួនឯងបាន ដែលជាមូលហេតុនាំឱ្យចៅក្រមស៊ើបសួរប្រគល់សិទ្ធិឱ្យអ្នកផ្សេងបំពេញកិច្ចស៊ើបសួរជំនួសខ្លួន។ ម្យ៉ាងវិញទៀតក៏បានអនុញ្ញាតឱ្យចៅក្រមស៊ើបសួរប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬ ដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។[64] ក្នុងករណីនេះ ចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបញ្ជាក់ពីកិច្ចដែលត្រូវធ្វើឱ្យបានច្បាស់លាស់ ពោលគឺមិនត្រូវជាការប្រគល់សិទ្ធិជាលក្ខណៈទូទៅនោះទេ ហើយថែមទាំងកំណត់ថិរវេលាដែលត្រូវអនុវត្តទៀតផង។ ដីកានេះអាចត្រូវបានដកហូតគ្រប់ពេលដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរមិនអាចប្រគល់សិទ្ធិឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបសួរជំនួសខ្លួនទាក់ទិននឹងការសួរចម្លើយជនត្រូវចោទ ឬ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ក្នុងកិច្ចនៃការស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ដែលស្តាប់ចម្លើយសាក្សីត្រូវឱ្យសាក្សីនោះស្បថជាមុនសិនមុននឹងស្តាប់ចម្លើយ។ ប្រសិនបើមានការឃាត់ខ្លួនក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស អំណាចដែលប្រគល់ឱ្យព្រះរាជអាជ្ញាត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរ។

**២.២.១.២ វិធានការនិរន្តរាយ**

វិធានការនិរន្តរាយ គឺជាវិធានការចេញដោយចៅក្រមស៊ើបសួរដើម្បីឱ្យកិច្ចស៊ើបសួរ ប្រព្រឹត្តទៅដោយរលូន និងមានឧបសគ្គ ឬ និយាយម្យ៉ាងទៀតថាវិធានការនិរន្តរាយ ជាវិធានការចេញដោយចៅក្រមស៊ើបសួរដើម្បីទប់ស្កាត់កុំឱ្យមានការអន្តរាយក្នុងការស៊ើបសួរ។ វិធានការនិរន្តរាយមានចំនួន ០៤ គឺ**ការបង្គាប់ឱ្យចូលខ្លួន ការបង្គាប់ឱ្យនាំខ្លួន ការបង្គាប់ឱ្យចាប់ខ្លួន ការឃុំខ្លួនបណ្តោះអាសន្ន**។

- **ការបង្គាប់ឱ្យចូលខ្លួន**

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាការបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួន គឺជាការបង្គាប់ឱ្យចូលខ្លួនជនត្រូវចោទ ឬ បង្គាប់

[64] មាត្រា ១៧៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ឱ្យចូលខ្លួនចំពោះបុគ្គលណាដែលមានតម្រុយពិរុទ្ធភាព។ [65] ការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួនត្រូវឱ្យដំណឹងដល់បុគ្គលដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ ដោយអាជ្ញាសាលា។ សាមីខ្លួនចុះហត្ថលេខាលើដើមដីកាដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។

- **ការបង្គាប់ឱ្យនាំខ្លួន**

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់នៅចំពោះមុខចៅក្រមស៊ើបសួរ។ លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចូលខ្លួន គឺជាការបង្គាប់ឱ្យនាំខ្លួន គឺជាការបង្គាប់ឱ្យនាំខ្លួនជនត្រូវចោទ ឬ បង្គាប់ឱ្យនាំខ្លួនបុគ្គលណាដែលមានតម្រុយពិរុទ្ធភាព។[66] ចំពោះការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ ដីកានេះត្រូវផ្សាយដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយដើម្បីនាំខ្លួនបុគ្គលពាក់ព័ន្ធ មន្ត្រីនគរបាលយុត្តិធម៌អាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលនេះបានដោយមិនចាំបាច់មានដីកាសម្រេចឱ្យឆែកឆេរឡើយ។ ក៏ប៉ុន្តែ ការចូលលំនៅឋានរបស់បុគ្គលពាក់ព័ន្ធដើម្បីអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនមិនអាចធ្វើបាននៅមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាចបានទេ។

- **ការបង្គាប់ឱ្យចាប់ខ្លួន**

ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាការបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួន។ លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន មានដូចជា បង្គាប់ឱ្យចាប់ខ្លួនជនត្រូវចោទ ឬ បុគ្គលណាដែលមានតម្រុយពិរុទ្ធភាព បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬ មជ្ឈិមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ហើយបុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬ ស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងចៅក្រមស៊ើបសួរបានទទួលយោបល់ព្រះរាជអាជ្ញាលើការចាប់ខ្លួននោះ។ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ ដីកានេះត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬ កងរាជាវុធហត្ថតាមគ្រប់មធ្យោបាយ។ យ៉ាងណាវិញ ក្នុងករណីចាំបាច់ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការដែលមានប្រសិទ្ធិភាព។ ដើម្បីនាំខ្លួនបុគ្គលពាក់ព័ន្ធ

[65] មាត្រា ១៨៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[66] មាត្រា ១៩០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

មន្ត្រីនគរបាលយុត្តិធម៌អាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលនេះបានដោយមិនចាំបាច់មានដីកាសម្រេចឱ្យឆែកឆេរឡើយ។ ក៏ប៉ុន្តែ ការចូលលំនៅឋានរបស់បុគ្គលពាក់ព័ន្ធដើម្បីអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនមិនអាចធ្វើបាននៅមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាចបានទេ។ បុគ្គលដែលពាក់ព័ន្ធត្រូវនាំខ្លួនយកទៅបង្ហាញខ្លួននៅចៅក្រមស៊ើបសួរ ឬ អ្នកជំនួសក្នុងរយៈពេលយ៉ាងខ្លីបំផុតប្រសិនបើស្ថិតនៅដំណាក់កាលចៅក្រមស៊ើបសួរនៅឡើយ។ ប្រសិនបើមិនអាចត្រូវបាននាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន បុគ្គលនេះត្រូវបានព្រះរាជអាជ្ញានាំទីកន្លែងឃុំខ្លួនស្តាប់ចម្លើយ។ បន្ថែមពីនេះ ប្រសិនបើការនាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ តម្រូវឱ្យមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារមួយផ្សេងទៀត។[67]

- **ការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន**

ក្រោយពីជនត្រូវចោទ ត្រូវបានចៅក្រមស៊ើបសួរដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ពីបទល្មើសណាមួយចៅក្រមស៊ើបសួរត្រូវពិចារណាទៅលើបញ្ហាឃុំខ្លួនជនត្រូវចោទ ឬ មិនឃុំខ្លួន។ ក្រមនីតិវិធីព្រហ្មទណ្ឌបានលើកឡើងពីគោលការណ៍សេរីភាពរបស់ជនត្រូវចោទមានន័យថាការឃុំខ្លួនជនត្រូវចោទតែក្នុងករណីពិសេសប៉ុណ្ណោះ។[68] ចៅក្រមស៊ើបសួរមានជម្រើសពីរយ៉ាងទាក់ទិននឹងបញ្ហានេះ គឺការសម្រេចមិនឃុំខ្លួនជនត្រូវចោទ និងការសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន។

### ២.២.២ ការបិទការស៊ើបសួរ

ក្រោយពី ចៅក្រមស៊ើបសួរបានប្រើប្រាស់នូវវិធានការទាំងពីរ គឺវិធានការស្រាវជ្រាវ និងវិធានការនិរន្តរាយចប់ហើយ ចៅក្រមស៊ើបសួរយល់ឃើញថាត្រូវបញ្ចប់នូវការស៊ើបសួរនេះ។ ការបន្តនៃនីតិវិធីទៀតនោះ គឺឈានដល់ការបិទការស៊ើបសួរដើម្បីបញ្ជូនទៅជំនុំជម្រះដែលត្រូវចេញនូវ **ការជូនដំណឹងស្តីអំពីការបិទស៊ើបសួរទៅតំណាងអយ្យការ និងជនដែលជាប់ទាក់ទិន (២.២.២.១) ការបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ (២.២.២.២) ដីកាសន្និដ្ឋានស្ថាពរ (២.២.២.៣) និងការចេញដីកាដំណោះស្រាយ (២.២.២.៤)។**

[67] មាត្រា ១៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[68] មាត្រា ២០៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

### ២.២.២.១ ការជូនដំណឹងស្តីអំពីការបិទស៊ើបសួរទៅតំណាងអយ្យការ និងជនដែលជាប់ចោទ

កាលណាចៅក្រមស៊ើបសួរយល់ឃើញការស៊ើបសួរបានបញ្ចប់ហើយ ចៅក្រមស៊ើបសួរនឹងមានចំណាត់ការដូចតទៅ។[69] ត្រូវជូនព័ត៌មានពីការបិទការស៊ើបសួរនេះទៅព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី (ដោយចេញជាលិខិតជូនព័ត៌មាន ឬ ជូនដំណឹងស្តីពីការបិទស៊ើបសួរ)។ បន្ទាប់មក ២ ថ្ងៃក្រោយនៃការជូនព័ត៌មានអំពីការបិទការស៊ើបសួរត្រូវចេញនូវដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យទៅព្រះរាជអាជ្ញា។ បន្ទាប់មកក្នុងរយៈពេលនេះ ប្រសិនបើព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី យល់ថាការបិទស៊ើបសួរមិនទាន់បានបំពេញកិច្ចចប់សព្វគ្រប់អាចស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទៅការស្នើសុំបាន ដូច្នេះ ចៅក្រមស៊ើបសួរត្រូវសម្រេចពីបញ្ហានេះ។ ក្នុងករណីការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេនោះ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ហេតុនេះព្រះរាជអាជ្ញាត្រូវចេញដីកាចាត់ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម។[70] មួយវិញទៀត ចំពោះការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី សួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា ១ (មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ តែប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ១ (មួយ) ខែទេ ជនត្រូវចោទ

[69] មាត្រា ២៤៦ និងមាត្រា ២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[70] មាត្រា ១៣២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

អាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[71] ចំណែកឯការស្នើសុំឱ្យបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរឱ្យស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទសួរតទល់គ្នា ឬ ចុះទៅដល់ទីកន្លែង។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធក្នុងចិរវេលា ១ (មួយ) ខែ ក្រោយពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ តែប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ១ (មួយ) ខែទេ ដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។ ក្រោយពីបានស៊ើបសួរបន្ថែមចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានពីការបិទការស៊ើបសួរម្តងទៀត។

### ២.២.២.២ ការបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ

ក្រោយពីបានជូនព័ត៌មានស្តីពីការបិទស៊ើបសួររួចហើយ ប្រសិនបើព្រះរាជអាជ្ញាបានយល់ឃើញថា ការស៊ើបសួរបានបំពេញកិច្ចចប់សព្វគ្រប់ហើយនោះ ២ ថ្ងៃក្រោយពីការជូនព័ត៌មានអំពីការបិទស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវចេញនូវដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យទៅព្រះរាជអាជ្ញាដើម្បីឱ្យព្រះរាជអាជ្ញាចេញនូវដីកាសន្និដ្ឋានស្ថាពរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើចៅក្រមស៊ើបសួរបានឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទ និងរយៈពេល ១ (មួយ) ខែ ក្នុងករណីដែលជនត្រូវចោទនៅក្រៅឃុំ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផងដែរ។ ចំពោះចិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលនូវសំណុំរឿងនេះ។[72]

### ២.២.២.៣ ដីកាសន្និដ្ឋានស្ថាពរ

នៅពេលដែលព្រះរាជអាជ្ញាបានទទួលនូវសំណុំរឿងពីចៅក្រមស៊ើបសួររួចមក ព្រះរាជអាជ្ញាត្រូវពិនិត្យទៅលើសំណុំរឿងទាំងមូលថាបានបញ្ចប់នូវកិច្ចស៊ើបសួររួចហើយ។ នៅពេលនោះ ព្រះរាជអាជ្ញាត្រូវធ្វើនូវដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ ដោយមាននូវអត្តសញ្ញាណរបស់ជនត្រូវចោទ ឈ្មោះ

---

[71] មាត្រា ១៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[72] មាត្រា ២៤៦ កថាខណ្ឌទី៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

បទល្មើសដែលបានចោទប្រកាន់ទៅលើជនត្រូវចោទ អង្គហេតុ និងមានសំអាងហេតុផងដែរ។ ព្រះរាជអាជ្ញាអាចប្តឹងសុំទៅឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬ ក៏លើកលែងការចោទប្រកាន់ទៅលើជនត្រូវចោទ គឺរួមទាំងជនត្រូវចោទនៅក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន និងស្ថិតនៅក្រៅឃុំ ។[73] គួរបញ្ជាក់ផងដែរថា ដីកាសន្និដ្ឋានស្ថាពរ (RD) ចៅក្រមស៊ើបសួរពុំមានការភ្ជាប់ជាកាតព្វកិច្ចរបស់ព្រះរាជអាជ្ញាឡើយ ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចតាមការស្នើសុំរបស់ព្រះរាជអាជ្ញាទេនោះ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរបាន។

### ២.២.២.៤ ការចេញដីកាដំណោះស្រាយ

បន្ទាប់ពីការបានបង្វិលដីកាសន្និដ្ឋានស្ថាពរ(RD)របស់ព្រះរាជអាជ្ញារួចមក ចៅក្រមស៊ើបសួរត្រូវបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ។[74] ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់។ ប្រសិនបើយល់ឃើញថា អំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។ ម៉្យាងវិញទៀត ចៅក្រមស៊ើបសួរចេញដីកាសម្រេចលើកលែងចោទប្រកាន់នៅក្នុងករណីដូចជាអំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ និងករណីដែលបណ្តឹងអាជ្ញារលត់។ ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួររកឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬ ការចូលរួមប្រព្រឹត្តបទល្មើស

[73] មាត្រា ២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[74] មាត្រា ២៤៧ថ្មី ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។

និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

មួយវិញទៀត ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬ ក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធប្រសិនបើមាន។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬ មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

ចំពោះបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬ ដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬ មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ។ បែបបទនិងនីតិវិធីនៃការប្តឹងឧទ្ធរណ៍នេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

កាលណាចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយរួចហើយនោះ ចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងអំពីដីកាដំណោះស្រាយនេះទៅភាគីដែលពាក់ព័ន្ធឱ្យបានដឹងថាតុលាការបានបញ្ជូនសំណុំរឿងទៅជំនុំជម្រះរួចហើយ។ ការជូនដំណឹងនេះត្រូវធ្វើការជូនដំណឹងទាំងជនត្រូវចោទដែលនៅក្រៅឃុំឱ្យបានដឹងនូវកាតព្វកិច្ចដែលតុលាការដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដើម្បីបង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។ រីឯជនត្រូវចោទដែលត្រូវបានចៅក្រមស៊ើបសួរបានឃុំខ្លួនបណ្តោះអាសន្ននោះ ក៏ត្រូវជូនដំណឹងអំពីដីកាដំណោះស្រាយឱ្យគាត់បានដឹងផងដែរ។ ចំពោះជនត្រូវចោទនៅក្នុងឃុំ ចៅក្រមស៊ើបសួរក៏ត្រូវចេញនូវដីកាបង្គាប់ឱ្យរក្សាទុកជនត្រូវចោទនៅក្នុងឃុំបណ្តោះអាសន្ន។ ពីព្រោះថា ដីកាដំណោះស្រាយត្រូវបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះ

អាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌ។[75] សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្តោះអាសន្ន លែងមានអានុភាពក្នុងរយៈពេល ៤ (បួន) ខែ ប្រសិនបើជនត្រូវចោទមិនបានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរយៈពេល ៤ (បួន) ខែនោះទេ ជនត្រូវចោទនេះត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង។[76]

ក្រោយពីបានជូនដំណឹងចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវបញ្ជូនជនត្រូវចោទដើម្បីបើកសវនាការជំនុំជម្រះ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះតាមបញ្ញត្តិ។[77]

[75] មាត្រា ២០៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[76] មាត្រា ២៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[77] មាត្រា ២៥០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

# ជំពូកទី ៣

# បណ្តឹងចំពោះដីកាដំណោះស្រាយ

# ជំពូកទី ៣

# បណ្តឹងចំពោះដីកាដំណោះស្រាយ

ជាក់ស្តែង នៅពេលដែលចៅក្រមស៊ើបសួរបានចេញនូវដីកាដំណោះស្រាយរួចរាល់ហើយនោះ ប្រសិនបើមានភាគីនៃសំណុំរឿងព្រហ្មទណ្ឌមិនសុខចិត្តទៅនឹងដីកាដំណោះស្រាយអាចប្តឹងទៅលើដីកាដំណោះស្រាយបាន។ ក្នុងនោះ **បណ្តឹងចំពោះដីកាដំណោះស្រាយអាចធ្វើឡើងដោយតំណាងអយ្យការ** (៣.១) **និងបណ្តឹងចំពោះដីកាដំណោះស្រាយដោយដើមបណ្តឹងរដ្ឋប្បវេណី** (៣.២)។ ដោយឡែកចំពោះជនត្រូវចោទពុំមានបទប្បញ្ញត្តិមួយណានៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានចែងអំពីសិទ្ធិប្តឹងឧទ្ធរណ៍នោះទេ ដោយហេតុនៅពេលដែលជនត្រូវចោទត្រូវបានបញ្ជូនទៅជំនុំជម្រះ ហើយក្នុងអំឡុងពេលជំនុំជម្រះនោះជនត្រូវចោទមានឱកាសក្នុងការអះអាងការពារខ្លួនមុខចៅក្រមជំនុំជម្រះបាន។

## ៣.១ បណ្តឹងចំពោះដីកាដំណោះស្រាយដោយតំណាងអយ្យការ

បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា បានចែងថា អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន។[78] មានន័យថា តំណាងអយ្យការអាចធ្វើការប្តឹងទៅលើគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន រួមទាំងដីកាដំណោះស្រាយផងដែរ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបាន បើកាលណាយល់ឃើញថា ជនត្រូវចោទមានពិរុទ្ធភាព ហើយចៅក្រមស៊ើបសួរបែរជាចេញដីកាលើកលែងចោទប្រកាន់ ឱ្យជនត្រូវចោទមានសិទ្ធិសេរីភាពវិញ។ បណ្តឹងចំពោះដីកាដំណោះស្រាយដោយតំណាងអយ្យការអាចធ្វើបានតែចំពោះដីកាលើកលែងចោទប្រកាន់តែប៉ុណ្ណោះ។

មូលហេតុដែលតំណាងអយ្យការមិនសុខចិត្ត ហើយប្តឹងទៅលើដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ដោយហេតុតំណាងអយ្យការយល់ឃើញថា ជនត្រូវចោទនោះ មានពិរុទ្ធភាព និងគួរតែបញ្ជូនជននោះទៅជំនុំជម្រះដើម្បីឱ្យចៅក្រមជំនុំជម្រះធ្វើការផ្តន្ទាទោសជននោះបាន។ សូមបញ្ជាក់បន្ថែមថា តំណាងអយ្យការ គឺជាអ្នកការពារផលប្រយោជន៍សាធារណៈ ការចោទប្រកាន់ គឺជាតួនាទីមួយក្នុងចំណោម

---

[78] មាត្រា ២៦៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

តួនាទីដទៃទៀតរបស់តំណាងអយ្យការ។ បន្ថែមពីនេះទៀត នីតិវិធីនៃការចោទប្រកាន់របស់តំណាងអយ្យការក៏មានភាពស្មុគស្មាញផងដែរ។

ម៉្យាងវិញទៀត លក្ខខណ្ឌនៃការចោទប្រកាន់ ក្រោយពីការទទួលបណ្តឹងទាមទារ ឬ បណ្តឹងបរិហារពីជនណាម្នាក់ ឬ ទទួលរបាយការណ៍ពីមន្ត្រីនគរបាលយុត្តិធម៌ក៏ដោយ អយ្យការអាចមិនទាន់ធ្វើការចោទប្រកាន់ ប្រសិនបើយល់ឃើញថា ពុំទាន់មានភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់នៅឡើយ ហើយអយ្យការអាចឱ្យមន្ត្រីនគរបាលយុត្តិធម៌ស្វែងរកបន្ថែម ឬ បើកការស៊ើបអង្កេតបឋមបាន។[79]

- ការពិនិត្យទៅលើលក្ខខណ្ឌនៃការចោទប្រកាន់ មុននឹងធ្វើការចោទប្រកាន់ព្រះរាជអាជ្ញាត្រូវពិនិត្យទៅលើកត្តាច្រើនយ៉ាងដូចជា៖
    - តើអំពើនោះមានធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌគ្រប់គ្រាន់ដែរ ឬ ទេ ជាពិសេសគឺធាតុផ្សំសត្យានុម័តធាតុផ្សំអត្តនោម័ត?
    - ត្រូវធ្វើការវាយតម្លៃកំណត់បទល្មើស ឱ្យសមស្របទៅនឹងអំពើប្រព្រឹត្ត។
    - ត្រូវពិនិត្យថា តើជនសង្ស័យមានអភ័យឯកសិទ្ធិដែរ ឬ ទេ?
    - តើជនល្មើសត្រូវចោទប្រកាន់ក្នុងនាមជាអ្វី ឱ្យសមស្របទៅនឹងអំពើប្រព្រឹត្តរបស់ជននោះ?
    - ត្រូវពិនិត្យថា តើស្ថិតនៅក្នុងសមត្ថកិច្ចដែរ ឬ ទេ? ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចគឺ៖
        - ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស។
        - ព្រះរាជអាជ្ញានៃលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស។
        - ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានគេសង្ស័យថា បានប្រព្រឹត្តបទល្មើស។
    - ត្រូវពិនិត្យថា តើនៅក្នុងករណីនេះ ចាំបាច់ត្រូវមានបណ្តឹងពីជនរងគ្រោះដែរ ឬ ទេ?
    - ត្រូវពិនិត្យថា តើបណ្តឹងអាជ្ញាត្រូវរលត់ហើយឬនៅ? ពាក់ព័ន្ធមូលហេតុដូចជា៖

[79] មាត្រា ៤០ កថាខណ្ឌទី២ វាក្យខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

- មរណភាពរបស់ជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍ច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ
- ការសម្របសម្រួល និងការដកពាក្យបណ្ដឹង។

ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី បានជ្រើសរើសយកគោលការណ៍នៃកាលានុវត្តភាពនៃការចោទប្រកាន់ ពុំមែនគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដូចក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ឡើយ។

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ បទបញ្ញត្តិនេះ ជាបទប្បញ្ញត្តិគោលដែលនាំឱ្យមានការបកស្រាយថា ក្រមនីតិវិធីព្រហ្មទណ្ឌប្រកាន់យកគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។[80]

គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់មានន័យថា ទោះបីជាមានបទល្មើសព្រហ្មទណ្ឌក៏ដោយ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា ការចោទប្រកាន់នឹងមិនមានផលប្រយោជន៍អ្វីឡើយនោះ ព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការបាន។ ផ្ទុយទៅវិញ ប្រសិនបើច្បាប់តម្រូវឱ្យប្រកាន់យកគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់វិញ ព្រះរាជអាជ្ញាដាច់ខាតត្រូវតែធ្វើការចោទប្រកាន់នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌដោយមិនអាចតម្កល់រឿងទុកឥតចាត់ការឡើយ។

- សេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា

ជាគោលការណ៍ ព្រះរាជអាជ្ញាមានសេរីភាពពេញលេញក្នុងការសម្រេចពីការចោទប្រកាន់ ឬ មិនចោទប្រកាន់។ ប៉ុន្តែដោយហេតុថា ព្រះរាជអាជ្ញាស្ថិតក្នុងអង្គដែលមានឋានានុក្រម ដូច្នេះព្រះរាជអាជ្ញាត្រូវធ្វើតាមបង្គាប់របស់ថ្នាក់លើតាមឋានុក្រមរបស់ខ្លួន ដែលបង្គាប់បញ្ជាឱ្យធ្វើការចោទប្រកាន់លើអំពើអ្វីមួយ ទោះបីព្រះរាជអាជ្ញាខ្លួនឯងយល់ថា ពុំត្រូវចោទប្រកាន់ក៏ដោយ។ គួរបញ្ជាក់ថា មានតែបញ្ជាឱ្យចោទប្រកាន់ប៉ុណ្ណោះដែលព្រះរាជអាជ្ញាត្រូវអនុវត្តតាម ប៉ុន្តែប្រសិនបើមានបញ្ជាមិនឱ្យចោទប្រកាន់ តែ

[80] មាត្រា ៤០ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ព្រះរាជអាជ្ញាបានចោទប្រកាន់រួចទៅហើយ គឺព្រះរាជអាជ្ញាពុំអាចដកហូតការចោទប្រកាន់របស់ខ្លួនបានឡើយ។ សេចក្តីសម្រេចរបស់អយ្យការទាក់ទងនឹងការចោទប្រកាន់នូវដីកាតម្កល់ទុកឥតចាត់ការ និងសេចក្តីសម្រេចក្នុងការចោទប្រកាន់។

- ដីកាតម្កល់ទុកឥតចាត់ការ

បើសិនជាព្រះរាជអាជ្ញាយល់ថាមិនមែនជារឿងព្រហ្មទណ្ឌ ឬ គ្មានភស្តុតាងណាមួយគួរឱ្យជឿថាពិតជាមានបទល្មើសកើតឡើងមែននោះ ព្រះរាជអាជ្ញានឹងចេញដីកាតម្កល់រឿងទុកឥតចាត់ការដែលមានសំអាងច្បាប់ និងសំអាងហេតុ។[81] ដីកាតម្កល់រឿងទុកឥតចាត់ការ អាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ គិតពីថ្ងៃទទួលដំណឹងពីដីកានេះ ដោយអ្នកប្តឹងដាក់ពាក្យនៅអង្គការអយ្យការពាក់ព័ន្ធ។ ប្រសិនបើ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា ការតវ៉ាមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាចេញអធិបញ្ញាឱ្យព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់។ ទោះជាយ៉ាងណាក្តី សេចក្តីសម្រេចនេះពុំមានអាជ្ញាអស់ជំនុំទេ ដោយព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ នៅពេលដែលបណ្តឹងអាជ្ញាមិនទាន់រលត់។ ម្យ៉ាងវិញទៀត មូលហេតុនៃការចេញដីកាតម្កល់រឿងទុកឥតចាត់ការអាចមានដូចជា៖

- **អង្គហេតុដែលប្តឹងមិនមែនជាបទល្មើសព្រហ្មទណ្ឌ៖** ឧទាហរណ៍ លោកស្រី ក បានប្តឹងលោក ខ ពីបទរំលោភលើទំនុកចិត្ត ដោយសារតែលោក ខ បានខ្ចីប្រាក់គាត់ហើយ ពុំព្រមសងប្រាក់។ នៅក្នុងករណីនេះ អំពើរបស់លោក ខ មិនមែនជាបទល្មើសទេ។ ហេតុដូច្នេះតំណាងអយ្យការនឹងតម្កល់រឿងទុកឥតចាត់ការ។
- **ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់៖** ឧទាហរណ៍ កញ្ញា គ បានប្តឹងចោទប្រកាន់លើលោក ឃ ថាបានឆបោកប្រាក់រូបនាងចំនួន ១០០០ ដុល្លារអាមេរិក ក៏ប៉ុន្តែពុំមានភស្តុតាងណាបញ្ជាក់ពីការប្រើកលល្បិចដែលជាធាតុផ្សំនៃបទល្មើសឡើយ។
- **មានមូលហេតុនៃការរំលត់បណ្តឹងអាជ្ញា។**
- **ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់៖** ឧទាហរណ៍ កញ្ញា ក បានប្តឹងចោទប្រកាន់លើលោក ខ ថាបានឆបោកប្រាក់រូបនាងចំនួន ១០០០ ដុល្លារអាមេរិក ក៏ប៉ុន្តែពុំមានភស្តុតាងណាបញ្ជាក់ពីការប្រើកលល្បិចដែលជាធាតុផ្សំនៃបទល្មើសឡើយ។

[81] មាត្រា ៤១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

- **បុគ្គលដែលពាក់ព័ន្ធជាជនដែលមានអភ័យឯកសិទ្ធិ៖** ឧទាហរណ៍ លោក ក បានវាយលោក ខ ចំនួន ០២ ដៃ។ លោក ក គឺជាមន្ត្រីទូតរបស់ប្រទេសបារាំងដែលមានអភ័យឯកសិទ្ធិ។ ដូច្នេះ តំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់បានទេ។
- **ការមិនទទួលខុសត្រូវរបស់ជនល្មើស៖** ឧទាហរណ៍ លោក ក បានចាក់លោក ខ ចំនួនមួយកាំបិត ក៏ប៉ុន្តែគេដឹងជាទូទៅថា លោក ក គឺជាជនវិកលចរិត ហើយមានការបញ្ជាក់ពីគ្រូពេទ្យជំនាញផងដែរ។
- **អនិយ័តភាពនៃនីតិវិធី៖** ឧទាហរណ៍ មន្ត្រីនគរបាលយុត្តិធម៌បានធ្វើការឆែកឆេរដោយខុសនីតិវិធី ហើយរកបានភស្តុតាងដែលបញ្ជាក់ថា លោក ក បានលួចយកខ្សែករបស់អ្នកដទៃ ក៏ប៉ុន្តែដោយសារតែការឆែកឆេរធ្វើឡើង ដោយខុសទៅនឹងនីតិវិធីច្បាប់ ដូច្នេះ តំណាងអយ្យការអាចតម្កល់រឿងទុកឥតចាត់ការបាន។
- **ការមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស៖** ឧទាហរណ៍ លោក ក បានប្ដឹងពីជនមិនស្គាល់ដែលបានលួចយកកាបូបប្រាក់របស់គាត់។ ប៉ុន្តែ ទោះបីជាស្វែងរកយ៉ាងណាក៏មិនអាចដឹងបានថា តើនរណាជាអ្នកលួចដែរ។ នៅក្នុងករណីបែបនេះ តំណាងអយ្យការអាចចោទប្រកាន់លើអញ្ញាតជន (ជនមិនស្គាល់) បាន ប៉ុន្តែស្របជាមួយគ្នានេះ តំណាងអយ្យការក៏អាចតម្កល់រឿងទុកឥតចាត់ការបានដែរ។
- **ការចោទប្រកាន់នឹងមិនផ្ដល់ផលប្រយោជន៍អ្វីឡើយ៖** ឧទាហរណ៍ លោក ក បានបើកម៉ូតូកៀរជនរងគ្រោះម្នាក់បណ្ដាលឱ្យរងរបួស។ ប៉ុន្តែ លោក ក បានជួយយកជនរងគ្រោះទៅមន្ទីរពេទ្យបានចេញថ្លៃព្យាបាលជំនួសជនរងគ្រោះ។ ម្យ៉ាងវិញទៀត ជនរងគ្រោះក៏មិនប្ដឹងលោក ក ដែរ។ ដូច្នេះតំណាងអយ្យការអាចតម្កល់រឿងទុកឥតចាត់ការ ពីព្រោះថា លោក ក បានដឹងពីកំហុសរបស់គាត់ទៅហើយ ដូច្នេះពុំចាំបាច់ធ្វើការផ្ដន្ទាទោសរូបគាត់បន្ថែមទេ។
- **ការបង្កព្យសនកម្មតិចតួច៖** ឧទាហរណ៍ លោក ក អាយុ ១៦ ឆ្នាំ បានលួចយកចានមួយរបស់លោកស្រី ខ។

- **សេចក្ដីសម្រេចក្នុងការចោទប្រកាន់**

នៅពេលដែលមានភស្តុតាងធួនល្មមអាចជឿបានថា ជនសង្ស័យអាចនឹងប្រព្រឹត្តអំពើដែលគេប្ដឹងមកនោះមែនព្រះរាជអាជ្ញានឹងចាប់ផ្ដើមធ្វើការចោទប្រកាន់។ ក្នុងករណីដែលមន្ត្រីរាជការណាម្នាក់

ត្រូវបានតុលាការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នេះទៅប្រធានស្ថាប័នសាមី ក្នុងរយៈពេល **៧២** ម៉ោងយ៉ាងយូរ។[82] ការចាប់ផ្តើមចោទប្រកាន់ចំពោះអនីតិជន ត្រូវជូនដំណឹងទៅ អនីតិជនជាប់សង្ស័យ និងឪពុកម្តាយ អាណាព្យាបាលរបស់អនីតិជននោះ។

យ៉ាងវិញទាក់ទងនឹងអនីតិជនដែលជាជនជាប់សង្ស័យសេចក្តីណែនាំអំពីការអនុវត្តគោល ការណ៍នានាច្បាប់ជាតិ និងអន្តរជាតិដែកកំពុងនៅជាធរមានទាក់ទងនឹងយុត្តិធម៌អនីតិជនចេញដោយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៥ បានកំណត់ថា ប្រសិនបើមានភាពមិនច្បាស់លាស់ អំពីអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ ព្រះរាជអាជ្ញាគប្បីធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីស្វែង រកការពិតនៃអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ។

- ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យ តិចជាង ១៣ឆ្នាំ ព្រះរាជអាជ្ញាគប្បីចេញដីកាតម្កល់រឿងទុកឥតចាត់ការ ហើយឱ្យដំណឹង ទៅភាគីដើមបណ្តឹងរដ្ឋប្បវេណី។
- ប្រសិនបើរកមិនឃើញអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបអង្កេតស៊ើបសួរពីបញ្ហាអាយុ។
- ការចាប់ផ្តើមធ្វើការចោទប្រកាន់នេះត្រូវធ្វើតាមនីតិវិធីយោងតាមមាត្រា ៤៣ នៃក្រមនីតិ វិធីព្រហ្មទណ្ឌៈ
    - **បើកបរការស៊ើបសួរៈ** ដោយព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាដីកាដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរឱ្យធ្វើការស៊ើបសួរលើអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាបញ្ជូនរឿងឱ្យស៊ើប សួរត្រូវមាននិទ្ទេសដូចកំណត់ហេតុក្នុងមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពោលគឺៈ
        - **សេចក្តីសង្ខេបនៃអង្គហេតុៈ** ឧទាហរណ៍ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣ លោក សំណាង បានឆក់យកកាបូបរបស់កញ្ញា ម៉ានិត ដែលកំពុងតែជិះម៉ូតូ តាមដងផ្លូវ ប៉ុន្តែភ្លាមៗនោះ ក្រោយពីបានឮសម្រែករបស់កញ្ញា ម៉ានិត អ្នក

[82] មាត្រា ៥១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ធ្វើដំណើរតាមដងផ្លូវនៅក្បែរនោះ ក៏បានធ្វើអន្តរាគមន៍ចាប់ខ្លួនលោក សំណាង និងយកបានកាបូបរបស់កញ្ញា ម៉ានិត ទៅប្រគល់ឱ្យនគរបាលប៉ុស្តិ៍។

- **ការកំណត់ឈ្មោះបទល្មើស៖** ឧទាហរណ៍ អំពើលួច ឃាតកម្មជាដើម។
- **ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសឧទាហរណ៍៖ មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន** បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។ នៅក្នុងករណីមិនអាចកំណត់បាន តំណាងអយ្យការអាចបើកការស៊ើបសួរប្រឆាំងនឹងអញ្ញាតជន ពោលគឺ ជនមិនស្គាល់។
- ចុះកាលបរិច្ឆេទ និងហត្ថលេខា។

- **បញ្ជូនទៅជំនុំជម្រះផ្ទាល់**

ក្នុងករណីនេះ ព្រះរាជអាជ្ញាចេញដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ហើយនឹងចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ ដូច្នេះ សំណុំរឿងនឹងត្រូវបញ្ជូនទៅចៅក្រមជំនុំជម្រះ។ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចធ្វើបានតែចំពោះបទមជ្ឈិម និងបទលហុប៉ុណ្ណោះ។[83]

ចំពោះបទមជ្ឈិមដែលព្រះរាជអាជ្ញាយល់ឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីឱ្យតុលាការធ្វើការជំនុំជម្រះវិនិច្ឆ័យសេចក្តីលើរឿងនេះបាន ព្រះរាជអាជ្ញានឹងប្រើវិធីនៃការចោទប្រកាន់នេះ។ **ឧទាហរណ៍** ៖ លោក សុភាព បានលួចគោរបស់អ្នកជិតខាងចំនួនពីរក្បាល។ ដប់ថ្ងៃក្រោយមក ម្ចាស់គោបានដាក់ពាក្យបណ្តឹងចោទប្រកាន់លោក សុភាព ដោយមានសាក្សីពីរនាក់បានឃើញយ៉ាងច្បាស់លាស់។ លើសពីនេះទៅទៀត នៅពេលដែលតំណាងអយ្យការបានកោះហៅលោក សុភាព មកស្តាប់ចម្លើយលោក សុភាព បានសារភាពថាគាត់ពិតជាបានលួចគោនោះមែន ដោយសារតែម្ចាស់គោបានចងទុកចោល ហើយគាត់ត្រូវការប្រាក់ជាបន្ទាន់ដើម្បីយកទៅព្យាបាលជម្ងឺប្រពន្ធរបស់គាត់។ នៅក្នុងស្ថានភាពបែបនេះ ឃើញថាមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីបទល្មើសដែលព្រះរាជអាជ្ញាមិនចាំបាច់បើកការស៊ើបសួរ (RI) ទៀតនោះទេ គឺព្រះរាជអាជ្ញានឹងបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តង។

[83] មាត្រា ៤៥ និងមាត្រា ៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ចំពោះបទលហុវិញ ព្រះរាជអាជ្ញាត្រូវតែជ្រើសរើសយកវិធីនៃការចោទប្រកាន់នេះ ហើយក៏មិនមានបទប្បញ្ញត្តិណាផ្សេងដែលអនុញ្ញាតឱ្យតំណាងអយ្យការបើកការស៊ើបសួរ ឬ ប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះបទលហុនោះទេ។ **ឧទាហរណ៍ ៖** លោកស្រី បញ្ញា បានប្ដឹងចោទប្រកាន់លើលោកស្រី រស្មី ថាបានដើរនិយាយបរិហារកេរ្តិ៍បគាត់។ នៅក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវតែធ្វើការស៊ើបអង្កេតឱ្យបានច្បាស់លាស់ដើម្បីស្វែងរកភស្តុតាងបញ្ជាក់ ហើយប្រសិនបើត្រូវធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញានឹងបញ្ជូនរឿងនោះ ទៅជំនុំជម្រះផ្ទាល់តែម្តង ដោយមិនអាចប្រើប្រាស់វិធីណាផ្សេងឡើយ។

- **នីតិវិធីនៃការបង្ហាញខ្លួនភ្លាម**

ប្រសិនបើលក្ខខណ្ឌត្រូវបានបំពេញ ព្រះរាជអាជ្ញាអាចប្រើប្រាស់នីតិវិធីនេះបានដោយគ្រាន់តែធ្វើកំណត់ហេតុប៉ុណ្ណោះ ពុំមានចេញជាដីកាសន្និដ្ឋានអ្វីទេ។[84] លក្ខខណ្ឌ គឺបទល្មើសមជ្ឈិមជាក់ស្ដែង និងបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ ឆ្នាំ និងយ៉ាងច្រើន ៥ ឆ្នាំ។ **ឧទាហរណ៍ទី១ ៖** បទលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៦ខែ ទៅ ៣ ឆ្នាំ ដូច្នេះ បទលួច គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៣ ឆ្នាំ ពោល គឺចន្លោះពី ១ឆ្នាំ ទៅ ៥ឆ្នាំ)។[85] ដូច្នេះ ចំពោះបទលួច អាចប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមបាន។

- បទគំរាមកំហែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ ៦ខែ ដូច្នេះ បទគំរាមកំហែង គឺជាបទល្មើសដែលត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារតិចជាង ១ឆ្នាំ។ ដូច្នេះ តំណាងអយ្យការមិនអាចប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមបានទេ។[86]
- ជនជាប់ចោទជានីតិជន។
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន។

នៅក្នុងស្ថានភាពបែបនេះ តំណាងអយ្យការមិនអាចប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមបានទេពីព្រោះថា៖

[84] មាត្រា ៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[85] មាត្រា ៣៥៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[86] មាត្រា ២៣១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

- ○ លោក ដារ៉ា បានប្រព្រឹត្តបទមជ្ឈិម ពោល គឺបទរំលោភលើទំនុកចិត្ត។[87]
- ○ បទល្មើសនេះ គឺជាបទល្មើសជាក់ស្តែងដោយហេតុថា លោក ដារ៉ា ត្រូវបានចាប់ខ្លួននៅពេលដែលកំពុងតែបញ្ចាំម៉ូតូរបស់ជនរងគ្រោះ។
- ○ លោក ដារ៉ា មានអាយុ ២០ ឆ្នាំ ពោលគឺជានីតិជន។
- ○ រឿងក្តីនេះមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន ពីព្រោះថា លោក ដារ៉ា បានសារភាពពីចេតនាទុច្ចរិតរបស់គាត់ រួមជាមួយនឹងវត្ថុតាងជាម៉ូតូដែលលោក ដារ៉ា បានយកទៅបញ្ចាំ ហើយត្រូវបានចាប់ខ្លួនជាក់ស្តែងតែម្តង។

- **សិទ្ធិអំណាចផ្សេងៗរបស់អយ្យការ**
  - ○ ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។
  - ○ ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។
  - ○ ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនោះ។
  - ○ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌។
  - ○ ព្រះរាជអាជ្ញាអាចចូលរួមស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។

ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនេះបានទទួលស្គាល់ឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។[88] ក្នុងន័យនេះ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតផ្សេងៗ (ការស៊ើបអង្កេតករណីជាក់ស្តែង ឬ បឋម) អាចធ្វើការឃាត់ខ្លួនជនជាប់សង្ស័យ។ល។

[87] មាត្រា ៣៩១ និងមាត្រា ៣៩២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[88] មាត្រា ៣៧ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

នៅក្នុងការអនុវត្តជាក់ស្តែង ជនពាក់ព័ន្ធមកស្តាប់ចម្លើយ ព្រះរាជអាជ្ញាច្រើនតែធ្វើការស៊ើបអង្កេតបឋម ដោយកោះហៅ ហើយកម្រឃើញមានការឃាត់ខ្លួនជនជាប់សង្ស័យនោះទេ។

- ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ។[89]
- ក្នុងគោលដៅដើម្បីសម្រួលដល់ចំណាត់ការរឿងក្តីព្រហ្មទណ្ឌ នៅពេលខ្លះនៅក្នុងការអនុវត្តជាក់ស្តែង តំណាងអយ្យការអាចសម្រេចបញ្ចូល ឬ បំបែកសំណុំរឿងព្រហ្មទណ្ឌបាន។ នៅក្នុងករណីបែបនេះ តំណាងអយ្យការចេញដីកាសម្រេចបំបែកសំណុំរឿង ឬ ដីកាសម្រេចបញ្ចូលសំណុំរឿង។

ដូច្នេះហើយ មុននឹងតំណាងអយ្យការសម្រេចធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសុទ្ធតែបានឆ្លងកាន់នូវនីតិវិធីយ៉ាងស្មុគស្មាញដើម្បីស្វែងរកភស្តុតាងក្នុងការដាក់បន្ទុកទៅលើជនដែលបានសង្ស័យថា មានពិរុទ្ធភាព ហេតុដូច្នេះ កាលបើតំណាងអយ្យការទទួលបាននូវដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរដែលលើកលែងចោទប្រកាន់នោះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរបាន។

## ៣.២ បណ្តឹងចំពោះដីកាដំណោះស្រាយដោយដើមបណ្តឹងរដ្ឋប្បវេណី

ជាទូទៅ ក្នុងរឿងព្រហ្មទណ្ឌមានបណ្តឹងចំនួនពីរ គឺបណ្តឹងអាជ្ញាដែលធ្វើឡើងដោយតំណាងអយ្យការ និងបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងតាមដើមបណ្តឹងរដ្ឋប្បវេណី។ ក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា "**បណ្តឹងរដ្ឋប្បវេណី**" មានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។[90] ជាមួយគ្នានេះ ព្យសនកម្មអាចត្រូវបានជួសជុលដោយការបង់ជម្ងឺចិត្តដោយការសងទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬ ដោយការធ្វើឱ្យដូចសភាពដើមវិញនូវទ្រព្យដែលជនត្រូវចោទបានបំផ្លិចបំផ្លាញ ឬ ធ្វើឱ្យខូចខាត។ បន្ថែមពីនេះ សំណងជម្ងឺចិត្តដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលបានក៏ត្រូវតែមានលក្ខណៈធួនល្មមជាមួយនឹងព្យសនកម្មដែលបានទទួលរងដែរ។ បណ្តឹងរដ្ឋប្បវេណីនេះ ក៏អាចប្តឹងទៅតុលាការរដ្ឋប្បវេណីបានដែរ។ ពីព្រោះបណ្តឹងនេះ

---

[89] មាត្រា ២៧ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[90] មាត្រា ២ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

ទាក់ទងទៅនឹងអំពើអនីត្យានុកូល ប៉ុន្តែដោយសារតែមានបណ្តឹងព្រហ្មទណ្ឌផង ដូចនេះ បណ្តឹងរដ្ឋប្បវេណីដែលទាក់ទងនឹងអំពើអនីត្យានុកូលនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចអះអាងពីការទាមទាររបស់ខ្លួននៅចំពោះមុខតុលាការព្រហ្មទណ្ឌ ដើម្បីទាមទារសំណងព្យសនកម្មដែលខ្លួនបានទទួលរង។ ទន្ទឹមនឹងនេះ ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលដំណឹងពីដីកាដំណោះស្រាយដែលលើកលែងការចោទប្រកាន់ទៅលើជនត្រូវចោទនោះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបាត់បង់នូវផលប្រយោជន៍ក្នុងរឿងរដ្ឋប្បវេណីពោល គឺសិទ្ធិក្នុងការទាមទារសំណងព្យសនកម្មនៃសកម្មភាពដែលជនត្រូវចោទបានប្រព្រឹត្តមកលើខ្លួន។ ហេតុនេះ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់សិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការប្តឹងទៅលើដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបាន។ ដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលចំនួន ០៥ថ្ងៃ ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍អំពីដីកាដំណោះស្រាយនេះបន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីបានទទួលដំណឹង។

បញ្ជាក់ផងដែរថា អំពើអនីត្យាកូល គឺជាការធ្វើអំពើបំពានដោយព្យាករណ៍ទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ និងជាការធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬ បទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករណ៍ទុកជាមុនអំពីការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ។[91]

អនុលោមតាមមាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិអំពីលក្ខខណ្ឌ និងការទទួលខុសត្រូវក្នុងបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ បានចែងថា៖

១-បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយ តែមិនបានធ្វើអំពើនោះ។

៣-ចំពោះកំហុសចេតនា ឬ កំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើបំពាន និងការកើតឡើងនៃការខូចខាត និងការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែល

[91] មាត្រា ៧៤២ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដោយព្រះរាជក្រឹត្យលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

ទាមទារសំណងនៃការខូចខាតនោះត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀត។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយលើប្រធានបទស្តីអំពី **ដីកាដំណោះស្រាយ** យ៉ាងស៊ីជម្រៅមក យើងខ្ញុំអាចសន្និដ្ឋានបានថា តាមលំហូរនីតិវិធីនៃដីកាដំណោះស្រាយ គឺមានច្រើនដំណាក់កាលដែលទាមទារឱ្យមានការសិក្សាឱ្យបានស៊ីជម្រៅឱ្យបានច្បាស់លាស់ដើម្បីយល់ច្បាស់អំពីប្រភេទនៃដីកាដំណោះស្រាយ ព្រមទាំងដំណើរការនីតិវិធីនៃការចេញដីកាដំណោះស្រាយ និងបណ្តឹងចំពោះដីកាដំណោះស្រាយឱ្យបានរលូនមានប្រសិទ្ធភាពដើម្បីជាមូលគ្រឹះដ៏សំខាន់នៃការសិក្សាទៅលើមេរៀននីតិវិធីព្រហ្មទណ្ឌនៅក្នុងដំណាក់កាលស៊ើបសួរ។ នៅក្នុងលំហូរនីតិវិធីនៃប្រធានបទ **ដីកាដំណោះស្រាយ** ខាងលើនេះជាការសង្ខេបយ៉ាងខ្លីមកវិញ មានចំនួនបីដំណាក់កាលធំៗដែលយើងនឹងធ្វើការសិក្សាឱ្យបានស៊ីជម្រៅគឺៈ

**ដំណាក់កាលទី១** គឺជាការសិក្សាអំពីប្រភេទនៃដីកាដំណោះស្រាយ ដោយដីកាដំណោះស្រាយនេះអាចជាដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងការចោទប្រកាន់។ នៅក្នុងដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ យើងនឹងអាចយល់អំពីការសម្រេចបញ្ជូនទៅជំនុំជម្រះដែលមានជនត្រូវចោទនៅក្នុងការឃុំបណ្តោះអាសន្ន ការសម្រេចបញ្ជូនទៅជំនុំជម្រះដែលមានជនត្រូវចោទត្រូវបានតុលាការដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ម្យ៉ាងវិញទៀតនោះ គឺជាការចេញដីកាបញ្ជូនឱ្យសម្រេចរឹបអូសវត្ថុតាង។ នៅក្នុងដីកាសម្រេចលើកលែងការចោទប្រកាន់វិញ គឺយើងនឹងយល់ច្បាស់អំពីមូលហេតុនៃការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ដែលមានមូលហេតុដូចជា អំពើដែលប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ មូលហេតុទាក់ទិននឹងជនដែលប្រព្រឹត្តអំពើនោះជាអញ្ញាតជន គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ និងករណីដែលមានបណ្តឹងអាជ្ញារលត់ដោយសារមូលហេតុដូចជា មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ។

**ដំណាក់កាលទី២** គឺយើងនឹងយល់ច្បាស់អំពីការចេញដីកាដំណោះស្រាយដែលនៅក្នុងនេះយើងនឹងបានសិក្សាយល់ដឹងអំពីអ្នកមានសមត្ថកិច្ចចេញដីកាដំណោះស្រាយ បន្ថែមពីនេះទៀត យើងនឹងបានសិក្សាជាលម្អិតលើលំហូរនីតិវិធីនៃការចេញដីកាដំណោះស្រាយដែលនៅក្នុងនោះមានដូចជាការបើកការស៊ើបសួរដែលក្តោបរួមពីរវិធានការធំៗ គឺវិធានការស្រាវជ្រាវ និងវិធានការនិរន្តរាយ។ មួយវិញទៀតយើងនឹងសិក្សាអំពីការបិទការស៊ើបសួរដែលមានដូចជា ការជូនដំណឹងស្តីអំពីការបិទស៊ើបសួរទៅតំណាងអយ្យការ ជនដែលជាប់ទាក់ទិន និងការបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ហើយយើងនឹងស្វែងយល់បន្ថែមទៀតលើដីកាសន្និដ្ឋានស្ថាពរ និងការចេញដីកាដំណោះស្រាយ។

**ដំណាក់កាលទី៣** យើងស្វែងយល់ឱ្យបានច្បាស់លើបណ្ដឹងចំពោះដីកាដំណោះស្រាយដែលបណ្ដឹងចំពោះដីកាដំណោះស្រាយអាចធ្វើឡើងបានដោយតំណាងអយ្យការ និងដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។

សរុបសេចក្ដីមក ដើម្បីជាការបង្ការ ទប់ស្កាត់បទល្មើស ចៅក្រមស៊ើបសួរដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកបុគ្គលដែលប្រព្រឹត្តិបទល្មើសមកធ្វើការដាក់ទោសមិនថាត្រូវប្រើប្រាស់វិធានបែបណាក៏ដោយ ជនប្រព្រឹត្តត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដើម្បីជាប្រយោជន៍ជនដែលពាក់ព័ន្ធអាចទាមទារសំណងការខូចខាតដោយព្យសនកម្មដែលបានទទួលរួមជាកិច្ចនីតិវិធីបានដោយរលូន និងផ្ដល់ឆន្ទានុសិទ្ធិដល់ចៅក្រមស៊ើបសួរក្នុងការប្រើប្រាស់វិធានណាមួយដែលរៀបរាប់ខាងលើ និងការពារប្រយោជន៍សាធារណៈនៃសង្គមជាតិទាំងមូលដោយកុំឱ្យមានការបង្កភាពអានាធិបតេយ្យដល់សង្គមទាំងមូល ថែមទាំងការពារទៅសិទ្ធិ និងផលប្រយោជន៍ក្នុងការរស់នៅរបស់ប្រជាពលរដ្ឋតែម្ដង។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាទៅលើក្រមនីតិវិធីព្រហ្មទណ្ឌរួចមក យើងខ្ញុំបានសិក្សា និងបានសង្កេតយល់ឃើញថានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលបានបញ្ញត្តិអំពីដីកាដំណោះស្រាយនៅក្នុងមាត្រា **២៤៧** នៃក្រមនីតិវិធីព្រហ្មទណ្ឌមានភាពខ្វះចន្លោះនៅឡើយដែលធ្វើឱ្យនីតិវិធីដំណើរការមានភាពខ្វះចន្លោះ ប៉ុន្តែក្រោយពីក្រមនីតិវិធីព្រហ្មទណ្ឌបានវិសោធន៍កម្មនៅត្រង់មាត្រា **២៤៧ ថ្មី** រួចមក យើងខ្ញុំសង្កេតឃើញថាមានការបំពេញចន្លោះខ្វះខាតដែលមុនពេលមិនទាន់បានវិសោធន៍កម្ម។ ការវិសោធន៍កម្មនៅត្រង់មាត្រា **២៤៧ ថ្មី** បានបំពេញចន្លោះខ្វះខាតដូចជា៖

- ពាក់ព័ន្ធនឹងករណីដែលចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ ដោយកាលពីក្រមនីតិវិធីព្រហ្មទណ្ឌមិនទាន់បានធ្វើវិសោធន៍កម្ម មូលហេតុដែលចៅក្រមស៊ើបសួរចេញដីកាលើកលែងការចោទប្រកាន់មានតែបីចំណុចប៉ុណ្ណោះគឺពាក់ព័ន្ធជាមួយនឹង អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ និងគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ប៉ុន្តែក្រោយពីក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើវិសោធន៍កម្មរួចមកក៏បានបន្ថែមនូវចំណុចមួយទៀតគឺ ករណីដែលបណ្តឹងអាជ្ញារលត់ ក៏ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់បានដែរ។
- ពាក់ព័ន្ធនឹងករណីដែលមាត្រា **២៤៧ ថ្មី** បានធ្វើវិសោធន៍រួចបានបន្ថែមនូវចំណុចដូចជា៖

  ១- ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួររកឃើញថាមិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬ ការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន។

  ២- ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវស្គាល់ ឬ ក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឱ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬ ទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថាឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការ

ជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការ និងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬ មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

៣- បុគ្គលដែលមានប្រយោជន៍ពាកព័ន្ធ ឬ ដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល២ (ពីរ) ខែ គិតថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬ មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ។

# ឯកសារយោង

# ឯកសារយោង

## ១-ក្រុមឯកសារច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចូលជាធរមាន ២៤ កញ្ញា ១៩៩៣។
- ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧។
- ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ០៨ ធ្នូ ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណី នស/រកម/០៧០៦/០២១ ០៦ កក្កដា ២០០៦។
- ច្បាប់ស្ដីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។
- ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ លេខ ១៤៩/០០៣/២០១៤ កបធ.ច ០២ កក្កដា ២០១៤។
- ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥។
- ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## ២-ក្រុមឯកសារមេរៀន

- សៀវភៅមេរៀន នីតិវិធីព្រហ្មទណ្ឌរបស់លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** បោះពុម្ពនៅឆ្នាំ២០១៧-២០១៨។
- សៀវភៅមេរៀនសិក្សានីតិព្រហ្មទណ្ឌទូទៅរបស់លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** បោះពុម្ពនៅឆ្នាំ២០២២។
- សារសម្លេងផ្សព្វផ្សាយអំពីច្បាប់របស់ឯកឧត្តម **កើត រិទ្ធិ** រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌។

# ពាក្យគតិយុត្ត

| ពាក្យច្បាប់ | អត្ថន័យ |
|---|---|
| **ការឃុំខ្លួនជាបណ្ដោះអាសន្ន**<br>(Fr. Detention provisoire, Eng. Provisional detention) | វិធានការបង្ខាំងរក្សាជនត្រូវចោទ ឬ ជនជាប់ចោទទុកក្នុងពន្ធនាគារដែលសម្រេចដោយចៅក្រមអាសនៈ (ចៅក្រមស៊ើបសួរ ឬ ចៅក្រមជំនុំជម្រះ) ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមដែលច្បាប់បានកំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១ ឆ្នាំ និងមានមូលហេតុនៃការឃុំខ្លួនជាបណ្ដោះអាសន្ន តាមច្បាប់កំណត់ (មាត្រា ៤៨ មាត្រា ២០៤ និង មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។ |
| **ការដោះបន្ទុក**<br>(Fr. Decharge, Eng. Discharge) | ការធ្វើឱ្យរួចបន្ទុកដែលត្រូវបានចោទប្រកាន់។ |
| **កិច្ចនីតិវិធី**<br>(Fr. Acte de procedure, Eng. Procedural act/Procedural document) | អំពើ ឬ កិច្ចការដែលធ្វើឡើងនៅក្នុងដំណើរការនៃនីតិវិធី។ |
| **កោសលវិច័យ**<br>(Fr. Expertise, Eng. Expertise) | ប្រតិបត្តិការរបស់អ្នកជំនាញ ក្នុងការពិនិត្យពិច័យលើបញ្ហាអង្គហេតុណាមួយដែលចៅក្រមត្រូវការឱ្យបំភ្លឺ។ |
| **ក្រឡាបញ្ជី**<br>(Fr. Greffier, Eng. Clerk of the court) | មន្ត្រីតុលាការទទួលបន្ទុកបំពេញមុខងារ ជាជំនួយដល់ចៅក្រមក្នុងការបំពេញកិច្ចនីតិវិធីផ្សេងៗ មានឧទាហរណ៍ដូចជា កត់ត្រាកំណត់ហេតុក្នុងការពេលសួរចម្លើយជនត្រូវចោទ ឬ ស្ដាប់ចម្លើយសាក្សី ឬ កត់ត្រាកំណត់ហេតុនៅក្នុងពេលសវនាការជាដើម។ សូមកត់សម្គាល់ថា ក្នុងពេលបច្ចុប្បន្ននេះនៅពុំទាន់មានច្បាប់ស្ដីពីលក្ខន្តិកៈរបស់ក្រឡាបញ្ជីនៅឡើយទេ។ |
| **គោលការណ៍នីតិត្យានុកូលភាព**<br>(Fr. Principe de la legalite, Eng. Principle of legality) | គោលការណ៍មួយនៃច្បាប់ព្រហ្មទណ្ឌដែលបានកំណត់ថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្ដន្ទាទោសព្រហ្មទណ្ឌបាន ហើយមានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តតែប៉ុណ្ណោះ ទើបអាចត្រូវប្រកាសដោយតុលាការបាន (មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ) ។ |

| | |
|---|---|
| **ច្បាប់**<br>(Fr. Loi, Eng. Law) | -ក្នុងន័យទូលាយច្បាប់សំដៅទៅលើរាល់លិខិតបទដ្ឋានគតិយុត្ត ដោយរាប់បញ្ចូលទាំងលិខិតបទដ្ឋានគតិយុត្តចេញដោយអង្គការនីតិប្រតិបត្តិផងដែរ។<br>-ក្នុងន័យចង្អៀតច្បាប់សំដៅទៅលើច្បាប់ដែលត្រូវបានអនុម័តដោយអង្គការនីតិបញ្ញត្តិ និងត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ។ |
| **ច្បាប់ជាធរមាន**<br>(Fr. Loi en vigueur, Eng. Law in force) | ច្បាប់ដែលកំពុងមានអានុភាពអនុវត្ត ហើយពុំទាន់ត្រូវបាននិរាករណ៍ (លុបចោល) នៅឡើយ។ |
| **ច្បាប់នីតិវិធី**<br>(Fr. Loi procedurale, Eng. Procedurale Law) | ច្បាប់ដែលកំណត់ពីរបៀបរបបនៃដំណើរការរឿងក្តីណាមួយ។ |
| **ឆន្ទានុសិទ្ធិ**<br>(Fr. Discretion, Eng. Discretion) | សិទ្ធិសម្រេចបានតាមចិត្ត។ |
| **ជនជាប់ចោទ**<br>(Fr. Accuse, Eng. Accused person) | បុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការ ដើម្បីជំនុំជម្រះតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ឬ ក៏ដីកាសន្និដ្ឋានបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា ឬមួយក៏តាមកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាម ដែលធ្វើឡើងដោយព្រះរាជអាជ្ញា (មាត្រា ២៩១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។ |
| **ជនត្រូវចោទ**<br>(Fr. Mis en examen, Eng. Charged person) | បុគ្គលដែលត្រូវបានចោទប្រកាន់ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ |
| **ជនរងគ្រោះ**<br>(Fr. Victime, Eng. Victim) | បុគ្គលដែលបានទទួលរងនូវព្យសនកម្ម (ការខូចខាត) ដោយសារតែបទល្មើសណាមួយ។ |
| **ជនល្មើស**<br>(Fr. Auteur de l’infraction, Eng. Perpetrator) | ជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ពាក្យ "**ជនល្មើស**" ត្រូវបានប្រើប្រាស់ជាទូទៅ សម្គាល់ជនដែលបានប្រព្រឹត្តបទល្មើស ដោយមិនផ្តោតជាពិសេសទៅលើដំណាក់កាលណាមួយនៃនីតិវិធីទេ។ |

| | |
|---|---|
| **ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ**<br>(Fr. Ordonnance d'envoi, Eng. Order forwarding case for trial/Indictment) | ដីកាដំណោះស្រាយមួយប្រភេទដែលក្នុងនោះចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះដោយសារតែយល់ឃើញថា ជននេះពិត ជាបានប្រព្រឹត្តអំពើដែលជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ។ ស្របតាមបញ្ញត្តិនៃមាត្រា ២៤៧ ថ្មី កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដីកានេះត្រូវរៀបរាប់ពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះនៃបទល្មើសតាមច្បាប់។ |
| **ដីកាសម្រេចលើកលែងចោទប្រកាន់**<br>(Fr. Ordonnance de non-lieu, Eng. Non-suit order) | ដីកាដំណោះស្រាយមួយប្រភេទ ដែលក្នុងនោះចៅក្រមស៊ើបសួរសម្រេចលើកលែងចោទប្រកាន់លើជនត្រូវចោទ ក្នុងករណីដែលអំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ឬ ក្នុងករណីដែលជនប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ឬ ក៏ក្នុងករណីដែលគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ឬ មួយក៏ក្នុងករណីដែលបណ្ដឹងអាជ្ញាត្រូវរលត់ (មាត្រា ២៤៧ ថ្មី កថាខណ្ឌទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ |
| **ដើមបណ្ដឹងរដ្ឋប្បវេណី**<br>(Fr. Partie civile, Eng. Civil party) | ភាគីនៅក្នុងរឿងព្រហ្មទណ្ឌ ដែលជាជនរងគ្រោះដោយសារតែបទល្មើសព្រហ្មទណ្ឌណាមួយ ហើយបានធ្វើការប្ដឹងទាមទារសំណង ឬ ជំងឺចិត្តពីជនល្មើសតាមរយៈពាក្យប្ដឹងសាមញ្ញ ឬ តាមពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ការដាក់បណ្ដឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ) (មាត្រា ៥ និងមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ |
| **តុលាការ**<br>(Fr. Tribunal, Eng. Court) | ស្ថាប័នមានអំណាចក្នុងការជំនុំជម្រះសេចក្ដី។ |
| **តំណាងអយ្យការ**<br>(Fr. Représentant du Parquet, Eng. Representative of Prosecution) | ព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញារងអមសាលាជម្រះក្ដីជាន់ទាបដែលទទួលបន្ទុកសំណុំរឿងក្ដីណាមួយ ត្រូវចាត់ទុកជាតំណាងអយ្យការដែលជាអង្គការមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។ |
| **នីតិជន**<br>(Fr. Majeur, Eng. Adult) | ជនដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ។ |
| **នីតិវិធី**<br>(Fr. Procédure, Eng. Procedure) | បណ្ដាវិធានទាំងឡាយដែលដឹកនាំដំណើរការរឿងក្ដី។ |
| **នីតិសម្បទា**<br>(Fr. Habilité, Eng. Entitlement) | ការមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់ បរិបូណ៌ដោយច្បាប់ការដល់ព្រមសមប្រកប។ |

| | |
|---|---|
| **នីតិភាព**<br>(Fr. Majorité, Eng. Majority) | -អាយុដែលកំណត់ដោយច្បាប់ ហើយដែលនៅពេលបានដល់អាយុនោះ បុគ្គលម្នាក់ៗត្រូវបានសន្មតថាមានសមត្ថភាពចំពោះការធ្វើសកម្មភាពផ្សេងៗ។ ជាធម្មតាជនដែលមានអាយុ ១៨ឆ្នាំ ជាជនដែលបានដល់នីតិភាព។<br>-យោងតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី អនីតិជនដែលទទួលបានអត្តាធីនភាពត្រូវចាត់ទុកថាបានដល់នីតិភាព (មាត្រា ២២ នៃក្រមរដ្ឋប្បវេណី)។ |
| **បណ្ដឹង**<br>(Fr. Action, Eng. Lawsuit) | សិទ្ធិរបស់បុគ្គលណាម្នាក់ក្នុងការពាំនាំនូវការប្ដឹងផ្ដល់របស់ខ្លួនមកឱ្យតុលាការជំនុំជម្រះដើម្បីទទួលបាននូវការគោរពសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ |
| **បណ្ដឹងឧទ្ធរណ៍**<br>(Fr. Appel, Eng. Appeal to Appelate Court) | បណ្ដឹងប្រឆាំងនឹងសាលក្រមនៃតុលាការជាន់ដំបូង ឬ នឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ហើយដែលនឹងត្រូវសម្រេចដោយសភាមានសមត្ថកិច្ចនៃសាលាឧទ្ធរណ៍។ |
| **បទប្បញ្ញត្តិ**<br>(Fr. Disposition, Eng. Provision) | -អ្វីដែលត្រូវបានចែង។<br>-សេចក្ដីបង្គាប់ ឬ ខដែលមានចែងនៅក្នុងច្បាប់ ឬ ខសំខាន់ក្នុងលិខិតរបស់តុលាការ។ |
| **បទល្មើស**<br>(Fr. Infraction, Eng. Criminal offense) | អំពើដែលត្រូវផ្ដន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ហើយដែលជាកំហុសរបស់ចារីផ្ទាល់។ តាមមាត្រា ២ នៃក្រមព្រហ្មទណ្ឌកំណត់ថា ច្បាប់បញ្ញត្តថាអំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស។ |
| **ពិរុទ្ធជន**<br>(Fr. Coupable, Eng. Guilty person) | -បុគ្គលដែលត្រូវបានរកឃើញថាមានកំហុស។<br>-បុគ្គលដែលត្រូវបានតុលាការសម្រេចផ្ដន្ទាទោស ដោយសេចក្ដីសម្រេចនោះមិនទាន់បានចូលជាស្ថាពរនៅឡើយ។ |
| **ពិរុទ្ធភាព**<br>(Fr. Culpabilité, Eng. Guilt) | ភាពមានកំហុស។ |

| | |
|---|---|
| **ព្រះរាជអាជ្ញា**<br>(Fr. Procureur, Eng. Prosecutor) | ចៅក្រមអយ្យការដែលមានតួនាទី និងភារកិច្ចដឹកនាំអង្គការអយ្យការអមតុលាការជាន់ទាប។ នៅក្នុងការបំពេញការងាររបស់ខ្លួនព្រះរាជអាជ្ញាទទួលជំនួយពីព្រះរាជអាជ្ញារងម្នាក់ ឬ ច្រើននាក់។ នៅអមសាលាជម្រះក្តីជាន់ខ្ពស់ក៏មានវត្តមានរបស់ព្រះរាជអាជ្ញាដែលធ្វើការក្រោមឋានានុក្រមរបស់អគ្គព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារង។ |
| **ភស្តុតាង**<br>(Fr. Preuve, Eng. Evidence) | -របស់ជាតឹកតាង ជាគ្រឿងសម្គាល់ជាសំអាង។<br>-ការចង្អុលបង្ហាញឱ្យឃើញនូវអត្ថិភាព (មានភាព) ឬ នត្ថិភាព (ភាពគ្មាន) នៃអំពើ ឬ លិខិតគតិយុត្តណាមួយ។ |
| **មេធាវី**<br>(Fr. Avocat, Eng. Attorney at law/Lawyer) | អ្នកជំនួយតុលាការដែលប្រកបវិជ្ជាជីវៈដោយឯករាជ្យហើយមានតួនាទីតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬ ជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធីលើកលែងតែច្បាប់បានបញ្ញត្តផ្ទុយ។ ក្នុងរឿងក្តីព្រហ្មទណ្ឌមេធាវីជួយការពារជនត្រូវចោទ ឬ ជនជាប់ចោទ ហើយមិនអាចតំណាងឱ្យជនត្រូវចោទ ឬ ជនជាប់ចោទបានឡើយ លើកលែងតែក្នុងករណីអនុវត្តបទប្បញ្ញត្តិពិសេសនៃច្បាប់ (មាត្រា ២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី)។ តាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងការជំនុំជម្រះ លើបទឧក្រិដ្ឋជនជាប់ចោទដាច់ខាតត្រូវតែមានមេធាវីការពារក្តីឱ្យខ្លួននៅចំពោះមុខតុលាការ ។ |
| **សភាស៊ើបសួរ**<br>(Fr. Chambre de l'instruction, Eng. Investigation chamber) | សភាមួយនៃសាលាឧទ្ធរណ៍ដែលទទួលបន្ទុកពិនិត្យលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ឬ ចំពោះបណ្តឹងមោឃភាពនៃកិច្ចនីតិវិធី និងចំពោះបណ្តឹងផ្ទាល់ពីចំណាត់ការរបស់ចៅក្រមស៊ើបសួរ។ |
| **សាក្សី**<br>(Fr. Témoin, Eng. Witness) | បុគ្គលដែលបានឃើញ ឬ បានដឹងឮដោយផ្ទាល់ពីអង្គហេតុទាំងឡាយដែលពាក់ព័ន្ធនឹងរឿងក្តីណាមួយ។ ជាធម្មតាមុននឹងឆ្លើយទៅនឹងសំណួររបស់ចៅក្រម សាក្សីម្នាក់ៗត្រូវស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានិយាយតែការពិត (មាត្រា ១៥៤ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ)។ |
| **អនីតិជន**<br>(Fr. Mineur, Eng. Minor) | ជនដែលមានអាយុក្រោម ១៨ ឆ្នាំ។ |

| | |
|---|---|
| **អាជ្ញាយុកាល**<br>(Fr. Prescription, Eng. Statute of limitation) | រយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ បុគ្គលម្នាក់អាចបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬ អាចទាមទារសិទ្ធិណាមួយជាអត្ថប្រយោជន៍ដល់ខ្លួនបាន។ នៅក្នុងរឿងព្រហ្មទណ្ឌ អាជ្ញាយុកាលមានពីរប្រភេទគឺអាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស។ |
| **អាជ្ញាយុកាលនៃទោស**<br>(Fr. Prescription de la peine, Eng. Statute of limitation of penalty) | អាជ្ញាយុកាលដែលនឹងរំលត់ទោសទាំងឡាយណា ដែលត្រូវបានប្រកាសនៅក្នុងសេចក្តីសម្រេចរបស់តុលាការ ហើយដែលរារាំងដល់ការអនុវត្តទោស។ |
| **អាជ្ញាយុកាលនៃបទល្មើស**<br>(Fr. Prescription de l'infraction, Eng. Statute of limitation of ang – 15) | អាជ្ញាយុកាលដែលមានអានុភាពធ្វើឱ្យបណ្តឹងអាជ្ញារលត់បានសេចក្តីថា នៅពេលដែលផុតរយៈពេលនៃអាជ្ញាយុកាលនេះ បណ្តឹងអាជ្ញាពុំអាចត្រូវដាក់ឱ្យដំណើរការបានទៀតទេ ពោលគឺការចោទប្រកាន់ពីបទល្មើសលែងអាចធ្វើបានតទៅទៀតហើយ។ |

# ឧបសម្ព័ន្ធ

# បញ្ជីរាយឧបសម្ព័ន្ធ

| ល.រ | គំរូ ដីកា ឬ លិខិត | ចំនួន |
|---|---|---|
| ឧបសម្ព័ន្ធទី១ | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (RI) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី២ | ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី៣ | ដីកាបង្គាប់ឱ្យឃុំខ្លួន | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី៤ | ដីកាចាត់ឱ្យស៊ើបសួរជំនួស | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី៥ | ដីកាចាត់តាំងអ្នកជំនាញ | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី៦ | ដីកាបង្គាប់ឱ្យចូលខ្លួន | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី៧ | ដីកាបង្គាប់ឱ្យនាំខ្លួន | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី៨ | ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី៩ | លិខិតជូនព័ត៌មានស្ដីពីការបិទការស៊ើបសួរ (ទៅតំណាងអយ្យការ) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១០ | លិខិតជូនព័ត៌មានស្ដីពីការបិទការស៊ើបសួរ (ទៅជនត្រូវចោទ) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១១ | លិខិតជូនព័ត៌មានស្ដីពីការបិទការស៊ើបសួរ (ទៅជនរងគ្រោះ) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១២ | ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១៣ | ដីកាសន្និដ្ឋានស្ថាពរ (RD) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១៤ | ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១៥ | ដីកាដំណោះស្រាយ | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១៦ | លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ (ទៅជនត្រូវចោទនៅក្រៅឃុំ) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១៧ | លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ (ទៅដើមបណ្ដឹងរដ្ឋប្បវេណី) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១៨ | លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ (ទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី១៩ | លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ (ទៅមេធាវីជនត្រូវចោទ) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី២០ | លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ (ទៅជនត្រូវចោទនៅក្នុងឃុំ) | ០១ ច្បាប់ |
| ឧបសម្ព័ន្ធទី២១ | ដីកាបង្គាប់ឱ្យរក្សាទុកជនត្រូវចោទនៅក្នុងឃុំបណ្ដោះអាសន្ន | ០១ ច្បាប់ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**
**សំណុំរឿងព្រហ្មទណ្ឌលេខ.[redacted]**
**ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤**
**លេខ ៖ ...៤២៣........ អ.យ.ច**

# ដីកាសន្និដ្ឋាន
## បញ្ជូនរឿងឱ្យស៊ើបសួរ

**យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ.[redacted] ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤

-បានឃើញ របាយការណ៍សំយោគលេខ.[redacted] រ.ប.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ របស់អធិការនគរបាលខណ្ឌច្បារអំពៅ នៃស្នងការនគរបាលរាជធានីភ្នំពេញ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ៖**

**-យល់ឃើញមានតំរុយសន្នត់ថា**

| | | | |
|---|---|---|---|
| ១/.គោត្តនាម និងនាមខ្លួន | ៖ [redacted] | ភេទប្រុស | អាយុ៣៧ឆ្នាំ ជានីតិជន |
| ជនជាតិ | ៖ ខ្មែរ | សញ្ជាតិ ៖ ខ្មែរ | សាសនា៖ ព្រះពុទ្ធ |
| ទីកន្លែងកំណើត | ៖ ភូមិមាន់ជប់ | ឃុំមានជ័យ | ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម |
| អាស័យដ្ឋានបច្ចុប្បន្ន | ៖ ផ្ទះជួល | ផ្លូវបេតុង | ភូមិដើមស្លែង |
| | សង្កាត់ច្បារអំពៅទី២ | ខណ្ឌច្បារអំពៅ | រាជធានីភ្នំពេញ |
| មុខរបរកស៊ី (អាជីព) | ៖ ជាងសំណង់ | កំរិតវប្បធម៌ ៖ ថ្នាក់ទី១២ (ថ្មី) | |
| ប្រវត្តិនៃការផ្តន្ទាទោស | ៖ ធ្លាប់ជាប់ពន្ធនាគារ ម.១ រយៈពេល០២ឆ្នាំ | | ពីបទ ៖ គ្រឿងញៀន |
| ស្ថានភាពគ្រួសារ | **៖ មានគ្រួសារ** | **(<u>ឃាត់ខ្លួន</u>)** | |
| ប្រពន្ធឈ្មោះ | ៖ [redacted] | **(លែងលះ)** | មានកូនចំនួន ៖ ០១នាក់ |
| ឪពុកឈ្មោះ | ៖ [redacted] (រ) អាយុ៥៧ឆ្នាំ | | ម្ដាយឈ្មោះ: [redacted] (ស) ៕។ |
| ២/.គោត្តនាម និងនាមខ្លួន | ៖ [redacted] ភេទស្រី | អាយុប្រហែល៣៥ឆ្នាំ | ជានីតិជន |
| អាស័យដ្ឋានបច្ចុប្បន្ន | ៖ ធ្លាប់ចេញ-ចូលម្តុំ ផ្លូវ៦០ម៉ែត្រ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ | | |
| ប្រវត្តិនៃការផ្តន្ទាទោស | ៖ គ្មានព័ត៌មាន | **(គេចខ្លួន)៕** | |

**បានប្រព្រឹត្តអំពើដូចតទៅ ៖** កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល០១និង៣០នាទី (រំលងអាធ្រាត្រ) នៅត្រង់ចំណុចមុខផ្ទះគ្មានលេខ លើផ្លូវលំ ស្ថិតក្នុងភូមិដើមចាន់ សង្កាត់ច្បារអំពៅទី.២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានអំពើល្មើសព្រហ្មទណ្ឌមួយករណីកើតឡើង បង្កដោយជនសង្ស័យម្នាក់ឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ បានធ្វើសកម្មភាព លាក់ទុក ដាក់តាមខ្លួន ចរាចរ និងចែកចាយដោយខុសច្បាប់នូវសារធាតុញៀន ហើយត្រូវបានកំលាំងជំនាញមានសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងដកហូតបានវត្ថុតាងមានដូចជា៖ ១/.គ្រឿងញៀន ចំនួន០១ (មួយ) កញ្ចប់ថង់ ប្រភេទក្រាមពណ៌ស ទម្ងន់ស្មើនឹង ២,០២g (ពីរ កណ្តក់សញ្ញា សូន្យពីរ) ក្រាម ២/.ទូរស័ព្ទ ចំនួន០១ (មួយគ្រឿង: ម៉ាក OPPO ពណ៌ផ្ទៃមេឃ)

និង៣/. ម៉ូតូ ចំនួន០១ (មួយគ្រឿង: ម៉ាកស្មាសរី ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ [redacted]) ដែលជារបស់ជនសង្ស័យឈ្មោះ [redacted] ជាក់ស្តែងតែម្តង។ ក្រោយពីបានធ្វើតេស្តស្វែងរកសារជាតុញៀន ក្នុងខ្លួនលើឈ្មោះ [redacted] ជាលទ្ធផលឃើញថា: មានសារជាតុញៀន (វិជ្ជមាន)។ សំគាល់៖ នៅក្នុងអង្គហេតុខាងលើនេះ ក៏មានជាប់ពាក់ព័ន្ធជាមួយ នឹងជនសង្ស័យម្នាក់ផ្សេងទៀតផងដែរ (គឺឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ ធ្លាប់ចេញ-ចូលម្តុំផ្លូវ៦០ម៉ែត្រ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ) ដែលតែងតែជាអ្នកយកថ្នាំញៀនលក់មកឲ្យជនសង្ស័យឈ្មោះ [redacted]។

**អំពើខាងលើជាបទល្មើសព្រហ្មទណ្ឌ ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ឆ្នាំ២០១២) ប្រព្រឹត្តនៅត្រង់ចំណុចមុខផ្ទះគ្មានលេខ លើផ្លូវលំ ស្ថិតក្នុងភូមិដើមចាន់ សង្កាត់ច្បារអំពៅទី.២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ទៅលើជនសង្ស័យឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ។**

**អំពើខាងលើជាបទល្មើសព្រហ្មទណ្ឌ ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ឆ្នាំ២០១២) ប្រព្រឹត្តនៅត្រង់ម្តុំផ្លូវ៦០ម៉ែត្រ ស្ថិតក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ទៅលើជនសង្ស័យឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ។**

បានឃើញ ៖ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បានឃើញ ៖ មាត្រា ២០៣ ២០៥ និងមាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច៖**

**បើកការស៊ើបសួរលើអង្គហេតុខាងលើ និង**

- ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើជនសង្ស័យ
  - ១/.ឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ (**ឃាត់ខ្លួន**)។
  - ២/.ឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ (**គេចខ្លួន**)។
- ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើជនសង្ស័យ
  - ១/.ឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ (ដូចមានសារតាជាតិខាងលើ)។
  - ២/.ឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ (ដូចមានសារតាជាតិខាងលើ)។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤

**តំណាងអយ្យការ**

[redacted]

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**មន្ទីរស៊ើបសួរ "ហ"**

លេខ៖.................."ហ" ដ.ព.ស

## ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា **២០៤** មាត្រា **២០៥** និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** សំណុំរឿងស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤ ដែលទាក់ទងនឹងៈ

នាមត្រកូល-នាមខ្លួន [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រាលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវជាតិលេខ៥ ក្រុម៥ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរកម្មករលើកស្រាបៀ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ២នាក់ កម្រិតវប្បធម៌ថ្នាក់ទី៥ ទោសពីមុនគ្មាន ជានីតិជន។

ជននេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្រុមទី៥ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ តាមមាត្រា **៤០** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

### ១. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១.១ ជនត្រូវចោទឈ្មោះ [redacted] ត្រូវបានចោទប្រកាន់ពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្រុមទី៥ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ តាមមាត្រា **៤០** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

១.២ តំណាងអយ្យការបានស្នើសុំឱ្យឃុំខ្លួនលើជនត្រូវចោទឈ្មោះ [redacted] ដោយសំអាងលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤ ដោយប្ដឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទឈ្មោះ [redacted] តាមបញ្ញត្តិមាត្រា **២០៤** និងមាត្រា **២០៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២. សំអាងហេតុ

២.១ ជនត្រូវចោទឈ្មោះ [redacted] ត្រូវបានចោទប្រកាន់ពីមជ្ឈិម ឬ ឧក្រិដ្ឋ ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ ស្របតាមបញ្ញត្តិមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.២ តំណាងអយ្យការបានប្ដឹងសុំឱ្យឃុំខ្លួនជនត្រូវចោទដូចខាងលើជាបណ្ដោះអាសន្ន ដោយយោងទៅតាមបទប្បញ្ញត្តិមាត្រា ២០៥ នោះចៅក្រមស៊ើបសួរឯកភាពស្របតាមការប្ដឹងសុំនេះ។

២.៣ ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយ ដែលមានលក្ខណៈតឹងរ៉ឹង និងមានប្រសិទ្ធភាពអាចធានាឱ្យមានការបំពេញកិច្ចប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពតម្រូវទាំងអស់នោះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ ក្នុងការសម្រួលដល់នីតិវិធីនៃការស៊ើបសួររបស់តុលាការ។

**ហេតុដូច្នេះសម្រេច**

- ឃុំខ្លួនលើឈ្មោះ [redacted] ជាបណ្តោះអាសន្ន ហើយយើងនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនដើម្បីអនុវត្តការឃុំខ្លួននេះ។

**បានទទួលដំណឹង**

ថ្ងៃ......................រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស២៥៦៧ ថ្ងៃចន្ទ ១២ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី.............ខែមិថុនា ឆ្នាំ២០២៤ រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤

**តំណាងអយ្យការ** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**មន្ទីរស៊ើបសួរ "ហ"**

## ដីកាបង្គាប់ឱ្យឃុំខ្លួន

**លេខ៖...................."ហ" ដ.ឃ.ដ**

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា **២០៦** មាត្រា **២១៩** មាត្រា **២២០** មាត្រា **២២១** មាត្រា **២២២** និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** សំណុំរឿងស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤ ដែលទាក់ទងនឹង៖

នាមត្រកូល-នាមខ្លួន [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រាលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវជាតិលេខ៥ ក្រុម៥ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរកម្មករលើកស្រាបៀ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ២នាក់ កម្រិតវប្បធម៌ថ្នាក់ទី៥ ទោសពីមុនគ្មាន ជានីតិជន។

ជននេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្រុមទី៥ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ តាមមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- **បានឃើញ** ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ...................**"ហ" ដ.ព.ស** ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤។

### បង្គាប់ឱ្យ

១. ភ្នាក់ងារសមត្ថកិច្ចនៃកងកម្លាំងសាធារណៈ ធ្វើការនាំខ្លួនជនត្រូវចោទឈ្មោះ [redacted] ទៅមណ្ឌលអប់រំកែប្រែទី១ **(ម១)** នៃក្រសួងមហាផ្ទៃ ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់។

២. ប្រធានមណ្ឌលអប់រំកែប្រែទី១ **(ម១)** នៃក្រសួងមហាផ្ទៃទទួល និងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មី សម្រេចផ្សេងពីនេះ។

៣. គ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់ សហការអនុវត្តឱ្យបានល្អ នៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃចន្ទ ១២ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី៤**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**មន្ទីរស៊ើបសួរ "ហ"**
**លេខ៖** [redacted]

## ដីកាចាត់ឱ្យស៊ើបសួរជំនួស

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-**បានឃើញ** មាត្រា **១៧៣** មាត្រា **១៧៤** និងមាត្រា **១៧៦** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**យល់ឃើញថា**

-តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២៤ របស់តំណាងអយ្យការបានបើកការស៊ើបសួរលើជនត្រូវចោទបុរសម្នាក់មិនស្គាល់ឈ្មោះ [redacted] ភេទប្រុស អាយុប្រហែល ២៨ឆ្នាំ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្រុមទី៥ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ តាមមាត្រា **៤០** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើម្បីជាប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិត គប្បីបង្គាប់ឱ្យស្រាវជ្រាវរកអត្តសញ្ញាណរបស់បុរសម្នាក់មិនស្គាល់ឈ្មោះ [redacted] ភេទប្រុស អាយុប្រហែល ២៨ឆ្នាំ សម្បុររៀងស សក់រៀងវែង នៅម្តុំឫស្សីកែវ ជាជនត្រូវចោទដែលពុំទាន់មានសាវតាជាតិគ្រប់គ្រាន់នៅឡើយ។

**ហេតុដូច្នេះ សម្រេច**

**១**-ប្រគល់សិទ្ធិជូន **លោក អធិការ នៃអធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ** ដើម្បីធ្វើការស្រាវជ្រាវរកអត្តសញ្ញាណ និងបំពេញសាវតាជាតិរបស់ជនត្រូវចោទជាបុរសម្នាក់មិនស្គាល់ឈ្មោះ [redacted] ភេទប្រុស អាយុប្រហែល ២៨ឆ្នាំ នៅម្តុំឫស្សីកែវ។

**២**-ក្រោយពីបានស្រាវជ្រាវ និងបំពេញសាវតាជាតិចប់សព្វគ្រប់ សូម **លោក អធិការ** គប្បីចាត់បញ្ជូនលទ្ធផលស្រាវជ្រាវសាវតាជាតិ មកសាលាដំបូងរាជធានីភ្នំពេញវិញ យ៉ាងយូរត្រឹម **ថ្ងៃទី..........ខែ..........ឆ្នាំ២០២៤** ដោយអនុគ្រោះ។

ថ្ងៃពុធ ៦ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤
**ចៅក្រមស៊ើបសួរ**

***ភ្ជាប់ជូននូវ៖***
-ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤ ចំនួន ១ច្បាប់ (ថតចម្លង)។
-របាយការណ៍សំយោគលេខ [redacted] ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ ចំនួន ១ច្បាប់ (ថតចម្លង)។

**ឧបសម្ព័ន្ធទី៥**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**មន្ទីរស៊ើបសួរ "ហ"**

លេខ:........................"ហ" ព្រ.ទ

**<u>ដីកាចាត់តាំងអ្នកជំនាញ</u>**

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក [redacted] ជាក្រឡាបញ្ជី។

-**បានឃើញ** មាត្រា ១៦២ មាត្រា ១៦៣ មាត្រា ១៦៥ និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** កំណត់ហេតុធ្វើតេស្តបឋម ថ្លឹង និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤ ដែលទាក់ទងនឹង៖

១-ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រាលគោ សង្កាត់តឹឡម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវជាតិលេខ៥ ក្រុម៥ ភូមិបឹងឈូក សង្កាត់តឹឡម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរកម្មករលើកស្រាបៀ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ២នាក់ កម្រិតវប្បធម៌ថ្នាក់ទី៥ ទោសពីមុនគ្មាន ជានីតិជន។

ជននេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្រុមទី៥ ភូមិបឹងឈូក សង្កាត់តឹឡម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ តាមមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ជនត្រូវចោទបុរសម្នាក់មិនស្គាល់ឈ្មោះ [redacted] ភេទប្រុស អាយុប្រហែល ២៨ឆ្នាំ។

ជននេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្រុមទី៥ ភូមិបឹងឈូក សង្កាត់តឹឡម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ តាមមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**សំអាងហេតុ**

១- វត្ថុចាប់យក មានសំណាកជាប្រភេទក្រាមពណ៌សថ្លា ចំនួន ០,១១ (សូន្យក្បៀសដប់មួយ) ក្រាម ត្រូវបានដកហូតពីឈ្មោះ [redacted] និងត្រូវបានមន្ត្រីជំនាញ នៃការិយាល័យប្រឆាំងគ្រឿងញៀន ដាក់បញ្ចូលក្នុងកញ្ចប់រក្សាវត្ថុតាងក្នុងស្រោមសំបុត្រ ប្រភេទក្រដាស មានភិនភាគពណ៌ស បិទផ្និតដោយស្កុតពណ៌សថ្លា ដើម្បីបញ្ជូនទៅមន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

២-ដោយតុលាការពុំអាចសន្និដ្ឋាន វាយតម្លៃដោយខ្លួនឯងបាន និងដើម្បីជាប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិត គប្បីសម្រេចចាត់តាំងអ្នកជំនាញ ដែលមានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញឱ្យពិនិត្យសន្និដ្ឋាន និងវាយតម្លៃលើវត្ថុចាប់យកឱ្យបានច្បាស់លាស់ជាមុនសិន។

**ហេតុដូច្នេះសម្រេច**

១- ចាត់តាំង៖

ក- លោកជំទាវ វិស្វករគីមី [redacted] អគ្គលេខាធិការរង និងជាប្រធានមន្ទីរពិសោធន៍គ្រឿងញៀន។

ខ- លោក វេជ្ជបណ្ឌិត [redacted] អនុប្រធានមន្ទីរពិសោធន៍គ្រឿងញៀន។

គ- លោក ឱសថការីឧត្តម [redacted] អនុប្រធានមន្ទីរពិសោធន៍គ្រឿងញៀន។

ឃ-លោកវិស្វករគីមី [redacted] ប្រធានការិយាល័យបច្ចេកទេស។

ក- លោក វេជ្ជបណ្ឌិត [redacted] ប្រធានការិយាល័យវិភាគវត្ថុជីវសាស្ត្រ។

ជាអ្នកជំនាញ ដើម្បីធ្វើកោសល្យវិច័យលើវត្ថុចាប់យក មានសំណាកជាគ្រាប់ពណ៌សថ្លា ដែលសង្ស័យថាជាប្រភេទមេតំហ្វេតាមីន ទម្ងន់ ០,១១ (សូន្យក្បៀសដប់មួយ) ក្រាម ជារបស់ឈ្មោះ [redacted] ដាក់ក្នុងកញ្ចប់រក្សាវត្ថុតាង។

២- ក្រោយពីបានអនុវត្តដីកានេះចប់សព្វគ្រប់ អ្នកជំនាញត្រូវបញ្ជូនលទ្ធផលកោសលវិច័យមកសាលាដំបូងរាជធានីភ្នំពេញវិញឱ្យបានឆាប់រហ័ស។

ថ្ងៃចន្ទ ៤ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤
**ចៅក្រមស៊ើបសួរ**

***ជូនភ្ជាប់មកជាមួយនូវ៖***

-កំណត់ហេតុធ្វើតេស្តបឋម ថ្លឹង និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ របស់ការិយាល័យប្រឆាំងគ្រឿងញៀន ចំនួន ០១ ច្បាប់ (ថតចម្លង)។

-កញ្ចប់រក្សាវត្ថុតាង ចំនួន ០១ កញ្ចប់។

**ឧបសម្ព័ន្ធទី៦**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**មន្ទីរស៊ើបសួរ "ហ"**

លេខ៖................"ហ" ព្រ.ទ

# ដីកាបង្គាប់ឱ្យចូលខ្លួន

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលារាជធានីភ្នំពេញ
អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា ១៨៦ និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] **អ.យ.គ** ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** សំណុំរឿងស៊ើបសួរលេខ [redacted] ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ ដែលទាក់ទងនឹង៖

នាមត្រកូល-នាមខ្លួន [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៨២ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ទីកន្លែងកំណើតនៅភូមិបឹងសាងកើត ឃុំសូរគង ស្រុកកងមាស ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៧៥២ ផ្លូវលំ ភូមិទ្រា២ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជានីតិជន។ *(គេចខ្លួន)*

ជននេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **ឆបោក និងរំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២២ តាមមាត្រា **៣៧៧** មាត្រា **៣៧៨** និងមាត្រា **៣៩២** នៃក្រមព្រហ្មទណ្ឌ។

**បង្គាប់ឱ្យ** ឈ្មោះ [redacted] ភេទប្រុស **ចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ** (បន្ទប់ "ហ") **នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ៩ និង ០០ នាទីព្រឹក** ជាកំណត់ ដើម្បីសាកសួរពីដំណើររឿង **ឆបោក និងរំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២២។

សាមីខ្លួនត្រូវយកឯកសារផ្សេងៗដែលទាក់ទងនឹងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ យើងនឹងចេញ **ដីកាបង្គាប់ឱ្យនាំខ្លួន**។

ថ្ងៃចន្ទ ៦ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤
**ចៅក្រមស៊ើបសួរ**

យើង..........................................បានប្រគល់ដីកាបង្គាប់ឱ្យចូលខ្លួននេះឱ្យឈ្មោះ..........................................
មានទីលំនៅបច្ចុប្បន្ននៅភូមិ.............................ឃុំ.សង្កាត់..........................ស្រុក.ខណ្ឌ.ក្រុង.........................
ខេត្ត.រាជធានី....................................នៅថ្ងៃទី...........ខែ..........ឆ្នាំ..................ហើយបានប្រាប់ថា សាមីខ្លួនត្រូវប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលដែល ខ្លួនចូលខ្លួនទៅចំពោះមុខសាលាដំបូងរាជធានីភ្នំពេញ។

| អ្នកទទួល | អ្នកប្រគល់ |
|---|---|
| ហត្ថលេខា ឬស្នាមម្រាមដៃ | ហត្ថលេខា |

**ឧបសម្ព័ន្ធទី៧**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
**មន្ទីរស៊ើបសួរ "ព"**

## ដីកាបង្គាប់ឱ្យនាំខ្លួន

លេខ៖....................

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល
អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា ១៨៩ និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] អ.ក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ដកសស/២២ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។
- **បានឃើញ** សំណុំរឿងស៊ើបសួរលេខ [redacted] ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្ដាល ដែលទាក់ទងនឹង៖

នាមត្រកូល-នាមខ្លួន [redacted] ភេទប្រុស អាយុ ៥៦ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិស្រុកធំ ឃុំដើងកើប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ០៥ ស្ថិតក្នុងភូមិព្រែកឡុក សង្កាត់តាក្ដុល ក្រុងតាខ្មៅ ខេត្តកណ្ដាល មុខរបរពាណិជ្ជករ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] "រស់" មានកូនចំនួន៤នាក់ ទោសពីមុនគ្មាន ជានីតិជន។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិព្រែកឡុង សង្កាត់តាក្ដុល ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ តាមមាត្រា ២៣១ កថាខណ្ឌ៣ចំណុចទី៣ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។

- **បានឃើញ** ដីកាបង្គាប់ឱ្យចូលខ្លួនលេខ [redacted] ដប.ចខ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្ដាល។
- **យល់ឃើញថា** ជនត្រូវចោទពុំបានបង្ហាញខ្លួននៅចំពោះមុខតុលាការទាល់តែសោះ។ ដូច្នេះ ដើម្បីធានាដល់ការស៊ើបសួរឱ្យបានពេញលេញ គប្បីសម្រេចនាំខ្លួនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស មកចំពោះមុខតុលាការ ដើម្បីបង្ហាញឱ្យឃើញការពិតក្នុងរឿងក្ដីនេះ។

### ហេតុដូច្នេះ សម្រេច

១. បង្គាប់ឱ្យនាំខ្លួនឈ្មោះ [redacted] ភេទប្រុស ដែលមានអត្តសញ្ញាណដូចខាងលើនេះ។

២. បញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូនសាលាដំបូងខេត្តកណ្ដាល ឱ្យបានមុនថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីចាត់ការតាមច្បាប់។

ថ្ងៃព្រហស្បតិ៍ ៣ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
ខេត្តកណ្ដាល ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២
**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**មន្ទីរស៊ើបសួរ "ហ"**

**ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន**

លេខ៖......................."ហ" ដ.ព.ស

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា **២០៦** មាត្រា **២០៧** និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] **អ.យ.ង** ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤។
- **បានឃើញ** កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤។
- **បានឃើញ** កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤។

**ដែលទាក់ទងនឹង៖**

នាមត្រកូល-នាមខ្លួន [redacted] ភេទស្រី កើតថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧៨ ជនជាតិខ្មែរ (ឥស្លាម) ទីកន្លែងកំណើតឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម សាសនាឥស្លាម ទីលំនៅបច្ចុប្បន្នស្នាក់នៅខុនដូវិមានកុលាប បន្ទប់លេខ០៥ ជាន់ទីបេ១៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរ អាជីវករ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" មានកូនចំនួន ០៣នាក់ កម្រិតវប្បធម៌ថ្នាក់ទី១០ ទោសពីមុនគ្មាន ជាតិនីតិជន។

ជននេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅផ្ទះលេខN៨៥ វិថីកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីអំឡុងខែមីនា ឆ្នាំ២០២១ តាមមាត្រា **៣៩១** និងមាត្រា **៣៩២** នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច**

- មិនឃុំខ្លួនលើឈ្មោះ [redacted] មានអត្តសញ្ញាណដូចខាងលើ ដោយអនុញ្ញាតឱ្យមានសេរីភាពធម្មតា។

បានទទួលដំណឹង

| | |
|---|---|
| ថ្ងៃ..................កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស២៥៦៨ | ថ្ងៃអាទិត្យ ២ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ |
| រាជធានីភ្នំពេញ ថ្ងៃទី..........ខែកក្កដា ឆ្នាំ២០២៤ | រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៤ |

**តំណាងអយ្យការ** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី៩**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**មន្ទីរស៊ើបសួរ "ហ"**

លេខ៖.......................“ហ” ព្រ.ទ

## លិខិតជូនព័ត៌មាន
## ស្តីពីការបិទការស៊ើបសួរ

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។
អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា **២៤៦** និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ៦៦២៨ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**សូមជម្រាបមក**

☑ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ត្បិតសំណុំរឿងព្រហ្មទណ្ឌខាងលើនេះ យើងបានស៊ើបសួរមូលចប់សព្វគ្រប់អស់ហើយ ហេតុនេះ យើងបានសម្រេចបញ្ចប់ការស៊ើបសួរលើសំណុំរឿងខាងលើ ចាប់ពីពេលនេះតទៅ។

អាស្រ័យហេតុនេះ សូមតំណាងអយ្យការជ្រាបជាព័ត៌មាន។

**បានទទួលដំណឹង**
ថ្ងៃ................កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី...........ខែធ្នូ ឆ្នាំ២០២៣
**តំណាងអយ្យការ**

ថ្ងៃអង្គារ ១៤ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣
**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១០**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**មន្ទីរស៊ើបសួរ "ហ"**

លេខ៖......................"ហ" ព្រ.ទ

## លិខិតជូនព័ត៌មាន
## ស្តីពីការបិទការស៊ើបសួរ

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។
អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា **២៤៦** និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអម សាលាដំបូងរាជធានីភ្នំពេញ។

**ជូនដំណឹងដល់៖**

☑ ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិអូរ ឃុំទួលសាលា ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅមិនពិតប្រាកដ មុខរបរ ជាងដែក ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី១២ ទោសពីមុនគ្មាន ជានីតិជន។

- ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **លួចមានស្ថានទម្ងន់ទោស (គាស់ផ្ទះ)** ប្រព្រឹត្តនៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ភូមិ១២ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។
- ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ [redacted] ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣។

ត្បិតសំណុំរឿងព្រហ្មទណ្ឌខាងលើនេះ យើងបានស៊ើបសួរមូលចប់សព្វគ្រប់អស់ហើយ។
ហេតុនេះ យើងបានសម្រេចបញ្ចប់ការស៊ើបសួរលើសំណុំរឿងខាងលើ ចាប់ពីពេលនេះតទៅ ។

ថ្ងៃអង្គារ ១៤ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣
**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**មន្ទីរស៊ើបសួរ "ហ"**

**លេខ៖....................."ហ" ព្រ.ទ**

## លិខិតជូនព័ត៌មាន
## ស្តីពីការបិទការស៊ើបសួរ

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។
អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា **២៤៦** និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ៦៦២៨ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**ជូនដំណឹងដល់៖**

☑ ជនរងគ្រោះឈ្មោះ [redacted] ភេទប្រុស អាយុ ៣៧ឆ្នាំ មុខរបរអ្នកមើលការខុសត្រូវ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ភូមិ១២ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ត្បិតសំណុំរឿងព្រហ្មទណ្ឌខាងលើនេះ យើងបានស៊ើបសួរមូលចប់សព្វគ្រប់អស់ហើយ។

ហេតុនេះ យើងបានសម្រេចបញ្ចប់ការស៊ើបសួរលើសំណុំរឿងខាងលើ ចាប់ពីពេលនេះតទៅ ។

ថ្ងៃអង្គារ ១៤ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
**មន្ទីរស៊ើបសួរ "ហ"**

លេខ៖......................."ហ" ព្រ.ទ

## ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា **២៤៦** និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** សំណុំរឿងស៊ើបសួរលេខ [redacted] ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលទាក់ទងនឹង៖

ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិអូរ ឃុំទួលសាលា ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅមិនពិតប្រាកដ មុខរបរជាងដែក ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី១២ ទោសពីមុនគ្មាន ជានីតិជន។

ដែលត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **លួចមានស្ថានទម្ងន់ទោស (គាស់ផ្ទះ)** ប្រព្រឹត្តនៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ភូមិ១២ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរនេះទៅតំណាងអយ្យការ ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ផ្តល់យោបល់ ទៅតាមនីតិវិធី។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣

បានទទួលអនុវត្ត
**ក្រឡាបញ្ជី**

**ចៅក្រមស៊ើបសួរ**

# យោបល់របស់តំណាងអយ្យការ

យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
បានឃើញ ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យខាងលើ
បានឃើញ សំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ..........................................................................................

..................................................................................................................................................

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ស្នើសុំ៖

☐..............................................................................................................................................

..................................................................................................................................................

☐ ចោទប្រកាន់បន្ថែម តាមដីកាដែលមានភ្ជាប់ជាមួយ
☐ បន្តការស៊ើបសួរ
☐ បញ្ជូនសំណុំរឿងទៅសភាព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីភ្នំពេញ
☐ លើកលែងការចោទប្រកាន់
☐ រក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្ដោះអាសន្ន
☐ ឱ្យដោះលែងជនត្រូវចោទនៅក្រៅឃុំ។

ថ្ងៃ..................រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី..........ខែធ្នូ ឆ្នាំ២០២៣
**តំណាងអយ្យការ**

**ឧបសម្ព័ន្ធទី១៣**



## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ [redacted]
ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤
លេខ ៖ ១៨៩៥ អ.យ.ច

## ដីកាសន្និដ្ឋានស្ថាពរ

**យើង [redacted] តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ.នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.[redacted] ចុះថ្ងៃទី២៤/មករា/២០២៤។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ.[redacted] (អ.យ.ច) ចុះថ្ងៃទី២៥/មករា/២០២៤។

-បានឃើញសំណុំរឿងស៊ើបសួរលេខ[redacted] ចុះថ្ងៃទី២៥/មករា/២០២៤។

-បានឃើញលិខិតជូនដំណឹងស្តីពីការបិទការស៊ើបសួរលេខ.[redacted] (ខ) ព្រ.ទ ចុះថ្ងៃទី០២/មេសា/២០២៤។

-បានឃើញដីកាបញ្ជូនសំណុំរឿងមូលឱ្យពិនិត្យលេខ[redacted] (ខ) ព្រ.ទ ចុះថ្ងៃទី០៨/មេសា/២០២៤។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា៖**

| | | | |
|---|---|---|---|
| ១/.គោត្តនាម និងនាមខ្លួន | ៖ [redacted] | ភេទប្រុស | អាយុ៣៧ឆ្នាំ ជានីតិជន |
| ជនជាតិ | ៖ ខ្មែរ | សញ្ជាតិ ៖ ខ្មែរ | សាសនា៖ ព្រះពុទ្ធ |
| ទីកន្លែងកំណើត | ៖ ភូមិមាន់ជប់ | ឃុំមានជ័យ | ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម |
| អាស័យដ្ឋានបច្ចុប្បន្ន | ៖ ផ្ទះជួល | ផ្លូវបេតុង | ភូមិដើមស្លែង |
| | សង្កាត់ច្បារអំពៅទី២ | ខណ្ឌច្បារអំពៅ | រាជធានីភ្នំពេញ |
| មុខរបររកស៊ី (អាជីព) | ៖ ជាងសំណង់ | កំរិតវប្បធម៌ ៖ ថ្នាក់ទី១២ (ថ្មី) | |
| ប្រវត្តិនៃការផ្តន្ទាទោស | ៖ ធ្លាប់ជាប់ពន្ធនាគារ ម.១ រយៈពេល០២ឆ្នាំ | ពីបទ ៖ គ្រឿងញៀន | |
| ស្ថានភាពគ្រួសារ | ៖ មានគ្រួសារ | (ឃុំខ្លួន កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤) | |
| ប្រពន្ធឈ្មោះ | ៖ [redacted] (លែងលះ) | | មានកូនចំនួន ៖ ០១នាក់ |
| ឪពុកឈ្មោះ | ៖ [redacted] (រ) អាយុ៥៧ឆ្នាំ | | ម្តាយឈ្មោះ៖ [redacted] (ស) ។ |
| ២/.គោត្តនាម និងនាមខ្លួន | ៖ [redacted] | ភេទស្រី | អាយុប្រហែល២៥ឆ្នាំ ជានីតិជន |
| អាសយដ្ឋានបច្ចុប្បន្ន | ៖ ធ្លាប់ចេញ-ចូលម្តុំ | ផ្លូវ៦០ម៉ែត្រ | សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ |
| | រាជធានីភ្នំពេញ | | |
| ប្រវត្តិនៃការផ្តន្ទាទោស | ៖ គ្មានព័ត៌មាន | (គេចខ្លួន)។ | |

19 ៥

-ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ (និងឃុំខ្លួនបណ្តោះអាសន្ន) អំពីបទល្មើសព្រហ្មទណ្ឌ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** និងបទៈ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ឆ្នាំ២០១២) ប្រព្រឹត្តនៅត្រង់ចំណុចមុខផ្ទះគ្មានលេខ លើផ្លូវលំ ស្ថិតក្នុងភូមិដើមចាន់ សង្កាត់ច្បារអំពៅទី.២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ទៅលើជនសង្ស័យឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ។**

-ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ អំពីបទល្មើសព្រហ្មទណ្ឌ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ឆ្នាំ២០១២) ប្រព្រឹត្តនៅត្រង់ម្តុំផ្លូវ៦០ម៉ែត្រ ស្ថិតក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ទៅលើជនសង្ស័យឈ្មោះ ដា ភេទស្រី អាយុប្រហែល៣៥ឆ្នាំ (ដូចមានសាងតាជាតិខាងលើ)។**

-កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល០១និង៣០នាទី (រំលងអាធ្រាត្រ) នៅត្រង់ចំណុចមុខផ្ទះគ្មានលេខ លើផ្លូវលំ ស្ថិតក្នុងភូមិដើមចាន់ សង្កាត់ច្បារអំពៅទី.២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានអំពើល្មើសព្រហ្មទណ្ឌមួយករណីកើតឡើង បង្កដោយជនសង្ស័យម្នាក់ឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ បានធ្វើសកម្មភាព លាក់ទុក ដាក់តាមខ្លួន ចរាចរ និងចែកចាយ ដោយខុសច្បាប់នូវសារធាតុញៀន ហើយត្រូវបានកំលាំងជំនាញមានសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងដកហូតបានវត្ថុតាងមានដូចជា៖ ១/.គ្រឿងញៀន ចំនួន០១ (មួយ) កញ្ចប់ថង់ ប្រភេទក្រាមពណ៌ស ទម្ងន់ស្មើនឹង២,០២g (ពីរ កណ្តាក់សញ្ញា សូន្យពីរ) ក្រាម ២/.ទូរស័ព្ទ ចំនួន០១ (មួយគ្រឿងៈ ម៉ាក OPPO ពណ៌ផ្ទៃមេឃ) និង៣/.ម៉ូតូ ចំនួន០១ (មួយគ្រឿងៈ ម៉ាកស្កូសវី ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ[redacted]) ដែលជារបស់ជនសង្ស័យឈ្មោះ [redacted] ជាក់ស្តែងតែម្តង។ ក្រោយពីបានធ្វើតេស្តស្វែងរកសារធាតុញៀន ក្នុងខ្លួនលើឈ្មោះ [redacted] ជាលទ្ធផលឃើញថាៈ មានសារធាតុញៀន (វិជ្ជមាន)។ សំគាល់៖ នៅក្នុងអង្គហេតុខាងលើនេះ ក៏មានជាប់ពាក់ព័ន្ធជាមួយ នឹងជនសង្ស័យម្នាក់ផ្សេងទៀតផងដែរ (គឺឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ ធ្លាប់ចេញ-ចូលម្តុំផ្លូវ៦០ម៉ែត្រ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ) ដែលតែងតែជាអ្នកយកថ្នាំញៀនលក់មកឲ្យជនសង្ស័យឈ្មោះ [redacted]។

**<u>បានឃើញ៖</u>**

**ចំណាត់ការនៅជំណាក់កាលនគរបាលយុត្តិធម៌**

-សាវតាជាតិជនសង្ស័យឈ្មោះ [redacted] ភេទប្រុស ថ្ងៃ.ខែ.ឆ្នាំកំណើត១៩៨៧ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ហើយត្រូវចាប់ខ្លួននៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤។ (ឯកសារលេខ.១/១)

-ប្លង់កន្លែងកើតហេតុ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលច្បារអំពៅទី២ នៃអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ ពាក់ព័ន្ធនឹងករណី រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ (ឯកសារលេខ.១/៤)

-កំណត់ហេតុសរុបនៃការឃាត់ខ្លួន ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ពាក់ព័ន្ធនឹងឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ដែលចាប់ផ្តើមឃាត់ខ្លួន នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង១៩និង៣០នាទី។ សរុបម៉ោងឃាត់ខ្លួនប្រើប្រាស់អស់រយៈពេល២៤ (ម្ភៃបួន) ម៉ោងគត់។ (ឯកសារលេខ.១/៥) e

-របាយការណ៍នគរបាលមណ្ឌល ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលច្បារអំពៅទី.២ នៃអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ គោរពជូន: លោកនាយប៉ុស្តិ៍នគរបាលរដ្ឋបាលច្បារអំពៅទី.២ ស្តីពីការស្រាវជ្រាវរកឈ្មោះ [redacted] ដែលជាប់ពាក់ព័ន្ធនឹងករណី: រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ជាលទ្ធផល ឈ្មោះខាងលើ ពុំមានចុះបញ្ជីស្នាក់នៅក្នុងមណ្ឌលនេះទេ។ (ឯកសារលេខ.១/៦)

-កំណត់ហេតុធ្វើតេស្តបឋម ថ្លឹង និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ នៅចំពោះមុខជនសង្ស័យឈ្មោះ [redacted] ភេទប្រុស ឆ្នាំកំណើត.១៩៨៧ បានដកហូតយកសំណាកក្រាម ពណ៌សថ្លា ចំនួន០១ (មួយ) កញ្ចប់ថង់ ទម្ងន់ស្មើនឹង២,០២ (ពីរ កណ្តក់សញ្ញា សូន្យពីរ) ក្រាម ដាក់បញ្ចូលក្នុងស្រោមសំបុត្រ ប្រភេទក្រដាសពណ៌ស បិទផ្សិតដោយស្កុតពណ៌សថ្លា។ (ឯកសារលេខ.១/៩)

-កំណត់ហេតុធ្វើតេស្តពិសោធន៍រកសារធាតុញៀនក្នុងខ្លួន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ លើឈ្មោះ ទូច-តុង ភេទប្រុស ឆ្នាំកំណើត.១៩៨៧ ជាលទ្ធផល៖ វិជ្ជមាន (មានសារធាតុញៀន)។ (ឯកសារលេខ.១/១០)

-កំណត់ហេតុទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ នៅចំពោះមុខឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ មានដូចជា៖ ១/.ក្រាមពណ៌សថ្លា ចំនួន០១កញ្ចប់ថង់ធំល្មម, ២/.ទូរស័ព្ទដៃ ចំនួន០១ (មួយគ្រឿង ម៉ាកអូប៉ូ ពណ៌ផ្ទៃមេឃ ស៊ីមលេខ.[redacted] និងស៊ីមលេខ[redacted]), និង៣/.ម៉ូតូ ចំនួន០១ (មួយគ្រឿង ម៉ាកស្កាស ពណ៌ខ្មៅ ផ្លាកលេខ.ភ្នំពេញ.[redacted] លេខតួ និងលេខម៉ាស៊ីនលប់។ (ឯកសារលេខ.១/១១)

-កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ នៅចំពោះមុខឈ្មោះ ទូច-តុង ភេទប្រុស អាយុ៣៧ឆ្នាំ មានដូចជា៖ ១/.ក្រាមពណ៌សថ្លា ចំនួន០១ (មួយកញ្ចប់) ថង់ធំល្មម, ២/.ទូរស័ព្ទដៃ ចំនួន០១ (មួយគ្រឿង ម៉ាកអូប៉ូ ពណ៌ផ្ទៃមេឃ ស៊ីមលេខ.[redacted] និងស៊ីមលេខ[redacted]), និង៣/.ម៉ូតូ ចំនួន០១ (មួយគ្រឿង ម៉ាកស្កាស ពណ៌ខ្មៅ ផ្លាកលេខ.ភ្នំពេញ.[redacted] លេខតួ និងលេខម៉ាស៊ីនលប់)។ (ឯកសារលេខ.១/១២)

-កំណត់ហេតុឃាត់ខ្លួន និងកំណត់ហេតុស្តាប់ចម្លើយរបស់ជនសង្ស័យឈ្មោះ [redacted] ភេទប្រុស ឆ្នាំកំណើត.១៩៨៧ បានឆ្លើយសារភាពថា៖ គ្រឿងញៀន០១កញ្ចប់ថង់ធំល្មម ដែលសមត្ថកិច្ចចាប់យកជាក់ស្តែងពីខ្ញុំនោះ គឺខ្ញុំបានទិញពីមនុស្សស្រីម្នាក់ឈ្មោះ ដា ភេទស្រី អាយុប្រហែល៣៥ឆ្នាំ នៅផ្លូវ៦០ម៉ែត្រ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង០១និង០០នាទី មុនដំបូងខ្ញុំ និងពួកម៉ាក០២ទៅ០៣នាក់ ចូលលុយគ្នាបាន១៥ម៉ឺនរៀល ដើម្បីទិញគ្រឿងញៀនជក់។ ហើយខ្ញុំបាទតែម្នាក់ឯងបានទៅទិញគ្រឿងញៀន០១កញ្ចប់ថង់ធំល្មមតម្លៃ១៥ម៉ឺនរៀល ពីឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ នៅផ្លូវ៦០ម៉ែត្រ ស្ថិតក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ ទិញគ្រឿងញៀនបានហើយ ក៏ត្រឡប់មកវិញ។ លុះមកដល់វេលាម៉ោង០១និង៣០នាទី នាថ្ងៃខែដដែល ខ្ញុំបានមកអង្គុយចាំពួកម៉ាក នៅមុខផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី.២ ស្រាប់តែមានសមត្ថកិច្ចចុះមកដល់សង្ស័យ ធ្វើការត្រួតពិនិត្យខ្ញុំរកឃើញគ្រឿងញៀន ចំនួន០១ (មួយកញ្ចប់) ថង់ធំល្មម ដែលខ្ញុំលាក់ទុកក្នុងហោប៉ៅខោ ក្រោយចំហៀងខាងឆ្វេង ក៏ធ្វើការឃាត់ខ្លួនខ្ញុំរួម និងដកហូតវត្ថុតាង ទូរស័ព្ទដៃ ចំនួន០១ (មួយគ្រឿង ម៉ាកអូប៉ូ ពណ៌ផ្ទៃមេឃ ស៊ីមលេខ.[redacted] និង

លេខ.[redacted]) ម៉ូតូ ចំនួន០១ (មួយគ្រឿងម៉ាកស្មាស់ ពណ៌ខ្មៅ ផ្លាកលេខ.ភ្នំពេញ[redacted] លេខតួ និងលេខម៉ាស៊ីនរលប់) បញ្ជូនមកទីស្នាក់ការប៉ុស្តិ៍ធ្វើការសាកសួរ។ (ឯកសារលេខ.១/២០ និងលេខ.១/១៦)

-កំណត់ហេតុបើកកញ្ចប់វត្ថុតាង ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ នៃអធិការដ្ឋាននគរបាលរាជធានីភ្នំពេញ បានបើកកញ្ចប់វត្ថុតាងក្នុងស្រោមសំបុត្រពណ៌ស ឃើញមាន៖ ១/.ក្រាមពណ៌ស ថ្លា០១កញ្ចប់ ថង់ធំល្មម។ (ឯកសារលេខ.១/១៧)

-កំណត់ហេតុវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ នៅប៉ុស្តិ៍នគរបាលរដ្ឋបាលច្បារអំពៅទី.២ នៃអធិការដ្ឋាននគរបាលរាជធានីភ្នំពេញ បានដំណើរការវេចខ្ចប់វត្ថុតាងក្នុងស្រោមសំបុត្រពណ៌ស ឃើញមាន៖ ១/. ក្រាមពណ៌ស ថ្លា០១កញ្ចប់ ថង់ធំល្មម។ (ឯកសារលេខ.១/១៨)

-កំណត់ហេតុត្រួតពិនិត្យចាប់យកវត្ថុតាង ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ នៅប៉ុស្តិ៍នគរបាលរដ្ឋបាលច្បារអំពៅទី.២ នៃអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ បានត្រួតពិនិត្យរកឃើញ៖ ១/.ក្រាមពណ៌សថ្លា ចំនួន០១ (មួយកញ្ចប់) ថង់ធំល្មម, ២/.ទូរស័ព្ទដៃ ចំនួន០១ (មួយគ្រឿង ម៉ាកអូរ៉ូ ពណ៌ផ្ទៃមេឃ ស៊ីមលេខ.[redacted] និងស៊ីមលេខ.[redacted]), និង៣/.ម៉ូតូ ចំនួន០១ (មួយគ្រឿង ម៉ាកស្មាស ពណ៌ខ្មៅ ផ្លាកលេខ.ភ្នំពេញ.[redacted] លេខតួ និងលេខម៉ាស៊ីនរលប់)។ (ឯកសារលេខ.១/២១)

-របាយការណ៍លេខ.០០៣/០២៤ រ.ប.ក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលច្បារអំពៅទី.២ នៃអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ។ (ឯកសារលេខ.១/២២)

-របាយការណ៍សរុបលេខ.០១៤/០២៤ រ.ប.ក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដែលមានខ្លឹមសារថា៖ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ម៉ោង០១និង៣០នាទី កម្លាំងសមត្ថកិច្ចនគរបាលប៉ុស្តិ៍ច្បារអំពៅ២ នៃអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ បានល្បាតដល់ចំណុចមុខផ្ទះគ្មានលេខ ផ្លូវលំ ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី.២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក៏ឃើញជនសង្ស័យឈ្មោះ [redacted] កំពុងអង្គុយលើម៉ូតូ ០១គ្រឿងម៉ាកស្មាសវី ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ[redacted] មានការសង្ស័យសមត្ថកិច្ចយើងក៏ឃាត់ធ្វើការត្រួតពិនិត្យរកឃើញ ក្រាមពណ៌សថ្លា ចំនួន០១ (មួយកញ្ចប់) ថង់ធំល្មម ដែលជនសង្ស័យឈ្មោះ [redacted] លាក់ទុកក្នុងហោប៉ៅខោក្រោយខាងឆ្វេង ក៏ឃាត់ខ្លួនជនសង្ស័យរួមទាំងវត្ថុតាង បញ្ជូនមកកាន់ទីស្នាក់ការប៉ុស្តិ៍ធ្វើការសាកសួរតែម្តង។ ផ្អែកតាមការស៊ើបអង្កេត តាមការស្តាប់ចម្លើយសារភាពរបស់ជនសង្ស័យ និងវត្ថុតាងចាប់យកអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ ធ្វើការសន្និដ្ឋានថា៖ ករណីខាងលើ គឺជាករណី រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ ១/.ជនសង្ស័យឈ្មោះ [redacted] (ឃាត់ខ្លួន) ពិតជាបានធ្វើសកម្មភាព រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ខាងលើពិតប្រាកដមែន។ ២/.ជនសង្ស័យឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ (គេចខ្លួន) ពិតជាបានធ្វើសកម្មភាព ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ខាងលើពិតប្រាកដមែន។ (ឯកសារលេខ.១/២៥)

## ចំណាត់ការនៅដំណាក់កាលតំណាងអយ្យការ

-ចំណាររបស់ **ឯកឧត្តម ព្រះរាជអាជ្ញា** ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ (អ.យ.ក) ចាត់តាំងលោក [redacted] ព្រះរាជអាជ្ញារង ជាតំណាងអយ្យការ ដើម្បីចាត់ការសំណុំរឿងព្រហ្មទណ្ឌខាងលើ។

-កំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ.១៩០ រ.វ.ត/២៤ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ របស់លេខាធិការដ្ឋានរដ្ឋបាល នៃសាលាដំបូងរាជធានីភ្នំពេញ មានដូចជា៖ ១/.ស្រោមសំបុត្របិទជិត ចំនួន០១ (មួយ)

ពណ៌ស សរសេរថាៈ ក្រាមពណ៌សថ្លាចេញពណ៌លឿងទុំ សង្ស័យជាសារធាតុញៀន ប្រភេទមេតំហ្វេតាមីនទម្ងន់ ២,០២ក្រាម (សូន្យ កណ្ដក់សញ្ញា សូន្យពីរ) ក្រាម និងសំបកថង់ ចំនួន០១ (មួយ) ដោយមានផ្តិតមេដៃរបស់ជនសង្ស័យឈ្មោះ [redacted] និងមានហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌។ (ឯកសារលេខ.២/១)

-កំណត់ហេតុសួរចម្លើយរបស់ជនសង្ស័យឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ២០២៤ បានសារភាពថា៖ ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានមេធាវីការពារសិទ្ធិឱ្យនោះទេ និងសូមធានាអះអាងថាសាវតាជាតិរបស់ខ្ញុំបាទ ដែលបានឆ្លើយនៅចំពោះមុខ លោកតំណាងអយ្យការ នាពេលនេះ គឺពិតជាត្រឹមត្រូវ។ ខ្ញុំបាទសូមរក្សាចម្លើយរបស់ខ្ញុំបាទ ដែលបានឆ្លើយនៅចំពោះមុខសមត្ថកិច្ចនគរបាលយុត្តិធម៌ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ ២០២៣ ទុកនៅដដែលដោយ ពុំមានអ្វីកែប្រែនោះទេ ពីព្រោះថាវាជាចម្លើយដែលខ្ញុំបាទ បានឆ្លើយដោយឯកឯង និងគ្មានការបង្ខិតបង្ខំនោះទេ។ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ ដោយសារខ្ញុំបាទបានធ្វើសកម្មភាព រក្សាទុក ដាក់តាមខ្លួន ដោយខុសច្បាប់នូវសារធាតុញៀន នៅត្រង់ចំណុចកើតហេតុមុខផ្ទះគ្មានលេខ លើផ្លូវលំ ស្ថិតក្នុងភូមិដើមចាន់ សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង០១និង ៣០នាទី។ គ្រឿងញៀន ខ្ញុំបាទទិញពីឈ្មោះ ដា ភេទស្រី អាយុប្រហែល៣៥ឆ្នាំ ធ្លាប់ចេញ-ចូលម្តុំផ្លូវ៦០ម៉ែត្រ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ គឺបានចាប់យកវត្ថុតាងរួមមាន៖ ១/.ម៉ូតូ ចំនួន០១ (មួយគ្រឿងៈ ម៉ាកស្មាស់ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ.[redacted]) ២/.ទូរស័ព្ទដៃ ចំនួន០១ (មួយគ្រឿងៈ ម៉ាកអូប៉ូ ពណ៌ផ្ទៃមេឃ) និង៣/.គ្រឿងញៀន ចំនួន០១កញ្ចប់។ ខ្ញុំបាទសូមសំណូមពរ លោកតំណាងអយ្យការ មេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្ញុំបាទផង ពីព្រោះថាៈ ខ្ញុំបាទបានដឹងកំហុសហើយ។ តាមការបញ្ជាក់របស់ឈ្មោះ **ខុច-តុង** បាននិយាយថាខ្លួនចេះប្រើប្រាស់ថ្នាំញៀន តាំងពីឆ្នាំ២០១៨។ (ឯកសារលេខ.៣/១)

## ចំណាត់ការនៅដំណាក់កាលចៅក្រមស៊ើបសួរ

-កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ និងកំណត់ហេតុស្តីពីការសួរចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ បានសារភាពថា៖ ខ្ញុំបាទរក្សាចម្លើយ ដែលខ្ញុំបានឆ្លើយនៅចំពោះមន្ត្រីនគរបាលយុត្តិធម៌ និងតំណាងអយ្យការទុកជាបានដដែល។ ខ្ញុំបាទបានធ្វើសកម្មភាព រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន នៅត្រង់ចំណុចកើតហេតុមុខផ្ទះគ្មានលេខ លើផ្លូវលំ ស្ថិតក្នុងភូមិដើមចាន់ សង្កាត់ច្បារអំពៅ.២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង០១និង៣០នាទី។ ខ្ញុំទិញគ្រឿងញៀនពីឈ្មោះ[redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ ធ្លាប់ចេញ-ចូលផ្តុំផ្លូវ៦០ម៉ែត្រ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ ដកហូតវត្ថុតាងរួមមាន៖ ម៉ូតូ ចំនួន០១ (មួយគ្រឿង ម៉ាកស្មាស់ ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ[redacted]), ទូរស័ព្ទដៃ ចំនួន០១ (មួយគ្រឿងៈ ម៉ាកOPPO ពណ៌ផ្ទៃមេឃ) និងគ្រឿងញៀន ចំនួន០១កញ្ចប់ទម្ងន់ ២,០២ក្រាម សង្ស័យជាគ្រឿងញៀន ប្រភេទមេតំហ្វេតាមីន។ ខ្ញុំចេះប្រើប្រាស់គ្រឿងញៀន រយៈពេល២ឆ្នាំ មកហើយ។ ខ្ញុំបាទសូមសំណូមពរតុលាការ មេត្តាបន្ធូរបន្ថយទោសដល់រូបខ្ញុំផង។ (ឯកសារលេខ.៦/៥, លេខ.៦/៧ និងលេខ.៦/២)

-ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ.៦៤៧ (ខ) ដ.ព.ស ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ ដែលលោកតំណាងអយ្យការ បានចុះហត្ថលេខារួច នាថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ និងដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ.៩០២ (ខ) ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ ពាកព័ន្ធនឹងឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ

a

ជាប់ចោទពីបទៈ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ លើផ្លូវលំ ស្ថិតក្នុងភូមិដើមចាន់ សង្កាត់ច្បារអំពៅទី.២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤។ (ឯកសារលេខ.៧/២ និងលេខ.៨/១)

-ដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ.៦២ (ខ) ព្រ.ទ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ <u>សម្រេច៖</u> ប្រគល់សិទ្ធិជូនលោកអធិការ នៃអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ ដើម្បីបំពេញកិច្ចស៊ើបសួរស្រាវជ្រាវរកអត្តសញ្ញាណជនត្រូវចោទឈ្មោះ **ដា កេទស្រី អាយុប្រហែល៣៥ឆ្នាំ (គេចខ្លួន)** ដែលជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ឆ្នាំ២០១២) ប្រព្រឹត្តនៅចំណុចត្រង់មុំផ្លូវ៦០ម៉ែត្រ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤។ (ឯកសារលេខ.៩/២)

-លិខិតលេខ.០១៤ រ.ប.ក/២៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ របស់ផ្នែកការងារប្រឆាំងគ្រឿងញៀន នៃអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ <u>សូមគោរពជូនៈ</u> ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ <u>កម្មវត្ថុៈ</u> របាយការណ៍ឆ្លើយតបស្តីពីលទ្ធផល ដីកាបញ្ជូលឲ្យស្រាវជ្រាវជនសង្ស័យឈ្មោះ ដា កេទស្រី អាយុប្រហែល៣៥ឆ្នាំ ត្រូវបាបដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន <u>យោងៈ</u> តាមដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ.៦២ (ខ) ព្រ.ទ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ និងចេញដោយលោក ថន-ប៉ាហៀក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ <u>ជាលទ្ធផលៈ</u> ឈ្មោះ **ដា** កេទស្រី អាយុប្រហែល៣៥ឆ្នាំ នោះពុំស្នាក់នៅក្នុងមូលដ្ឋានឡើយ ដោយមូលហេតុ ពុំមានអត្តសញ្ញាណច្បាស់លាស់ បច្ចុប្បន្នសមត្ថកិច្ចយើងកំពុងស្រាវជ្រាវបន្ត។ (ឯកសារលេខ.១០/១១)

-ដីកាអម (គ្មានលេខ) ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ របស់ផ្នែកការងារប្រឆាំងគ្រឿងញៀន នៃអធិការនគរបាលខណ្ឌច្បារអំពៅ <u>គោរពផ្ញើជូនៈ</u> លោក ថន-ប៉ាហៀក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ស្តីពី (រាយឈ្មោះលិខិត)៖ ១/.របាយការណ៍ឆ្លើយតបលេខ.០១៤/២៤ រ.ប.ក របស់នគរបាលខណ្ឌច្បារអំពៅ។ ២/.របាយការណ៍ប៉ុស្តិ៍នគរបាលរដ្ឋបាលច្បារអំពៅទី.២ លេខ.០១៧/២០២៤ និង៣/.ដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ.៦២(ខ) ព្រ.ទ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤។ (ឯកសារលេខ.១០/១២)

-ដីកាបញ្ជូនលេខ.២៤៤៤ ដ.ប/០២៤ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ <u>គោរពជូនៈ</u> ឯកឧត្តម អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៃក្រសួងមហាផ្ទៃ។ <u>ស្តីពី៖ (រាយឈ្មោះលិខិត)</u> ១/.ដីកាចាត់តាំងអ្នកជំនាញលេខ.៨១ (ខ) ព្រ.ទ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។ ២/.កំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។ និង៣/.កំណត់ហេតុទទួលវត្ថុចាប់យកលេខ.១៩០ រ.វ.ត/២៤ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ របស់ឃ្លាំងទទួលវត្ថុចាប់យកសាលាដំបូងរាជធានីភ្នំពេញ។ (ឯកសារលេខ.១២/១ និងលេខ.១១/២)

-ដីកាបញ្ជូនលេខ.៣៥៥១ ដ.ប/២៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ <u>គោរពជូនៈ</u> ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្តីពី៖(រាយឈ្មោះលិខិត)៖ ១/.លិខិតលេខ.១១២៩ (ខ) រ.ប/២៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ <u>កម្មវត្ថុៈ</u> សំណើរសុំលទ្ធផលកោសលវិច័យគ្រឿងញៀន ដែលចៅក្រមស៊ើបសួរបាន

ចេញដីកាចាត់តាំងអ្នកជំនាញ ដើម្បីធ្វើកោសលវិច័យលើវត្ថុចាប់យកក្នុងស្រោមសំបុត្រពណ៌សបិតជិត ដែលមានចុះហត្ថលេខាសមាសភាពចូលរួម និងស្នាមមេដៃជនត្រូវចោទ ប៉ុន្តែរហូតមកដល់នេះសាលាដំបូងមិនទាន់បានទទួលលទ្ធផលកោសលវិច័យនៅឡើយ។ ២/.ដីកាចាត់តាំងអ្នកជំនាញលេខ.៨១ (ខ) ព្រ.ទ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។ ៣/.ដីកាបញ្ជូនលេខ.២៤៤៤ ដ.ប/២៤ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ។ (ឯកសារលេខ.១៤/១ និងលេខ.១៣/១)

-លិខិតលេខ.៤៦៥៨១/២៤ ម.ព.អ.ជ.ប.គ.ញ (លទ្ធផលកោសលវិច័យគ្រឿងញៀន) ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ របស់មន្ទីរពិសោធន៍ នៃអគ្គេខាធិការដ្ឋាន កម្មវត្ថុ៖ ការផ្តល់លទ្ធផលកោសលវិច័យលើសំណាក ដែលសង្ស័យថាជាគ្រឿងញៀន យោង៖ ដីកាចាត់តាំងអ្នកជំនាញលេខ.៨១ (ខ) ព្រ.ទ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ។ ភិនភាគសំណាក៖ សំណាកនៅក្នុងស្រោមសំបុត្រពណ៌សបិទជិតមានហត្ថលេខាគណៈកម្មការ និងស្នាមមេដៃឈ្មោះ [redacted]។ សំណាកជាប្រភេទក្រាមម្សៅថ្លា ពណ៌ស ទម្ងន់ ២,០០១ក្រាម (សូន្យ កណ្តក់សញ្ញា សូន្យរយសូន្យមួយក្រាម), បរិមាណសំណាកនៅសល់ពីកោសលវិច័យទម្ងន់ ០,៨០៤ក្រាម (សូន្យ កណ្តក់សញ្ញា ប្រាំបីរយបួន ក្រាម)។ លទ្ធផល: វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វាតាមីន (Metamfetamine)។ បរិមាណសារធាតុមេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់ គឺ៖ ៧៤,២៥% (ចិតសិបបួន កណ្តក់សញ្ញា ម្ភៃប្រាំ ភាគរយ)។ ការសន្និដ្ឋាន: សំណាកជាគ្រឿងញៀន ប្រភេទក្រាមម្សៅថ្លា ឈ្មោះ មេតំហ្វេតាមីន, ដែលមានកម្រិតភាពសុទ្ធ៧៤.២៥% នៃទម្ងន់សរុប។ (ឯកសារលេខ.១៥/១)

-លិខិតលេខ.៩៥៧ ធ.ត.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ របស់អគ្គលេខាធិការដ្ឋាន នៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ កម្មវត្ថុ ៖ ការបញ្ជូនលទ្ធផលកោសលវិច័យលើសំណាករបស់សំណុំរឿងព្រហ្មទណ្ឌលេខ.៥៣៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤។ (ឯកសារលេខ.១៥/២)

-ឯកសារលិខិតស្នាម និងភស្តុតាងផ្សេងៗទៀត ដែលមានជាប់ទាក់ទិននៅក្នុងសំណុំរឿង..........។

**យល់ឃើញថា៖**

-កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វេលាម៉ោងប្រហែល០១និង៣០នាទី (រំលងអាធ្រាត្រ) នៅត្រង់ចំណុចមុខផ្ទះគ្មានលេខ លើផ្លូវលំ ស្ថិតក្នុងភូមិដើមចាន់ សង្កាត់ច្បារអំពៅទី.២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ពិតជាមានអំពើល្មើសព្រហ្មទណ្ឌមួយករណីកើតឡើង ដែលបង្កដោយជនត្រូវចោទម្នាក់ឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ បានធ្វើសកម្មភាព លាក់ទុក ដាក់តាមខ្លួន ចរាចរ និងចែកចាយ ដោយខុសច្បាប់នូវសារធាតុញៀន ហើយត្រូវបានកំលាំងជំនាញមានសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងដកហូតបានវត្ថុតាងមានដូចជា៖ ១/.គ្រឿងញៀនចំនួន០១ (មួយ) កញ្ចប់ថង់ ប្រភេទក្រាមពណ៌ស ទម្ងន់ស្មើនឹង ២,០២g (ពីរ កណ្តក់សញ្ញា សូន្យពីរ) ក្រាម ២/. ទូរស័ព្ទ ចំនួន០១ (មួយគ្រឿង: ម៉ាក OPPO ពណ៌ផ្ទៃមេឃ) និង៣/. ម៉ូតូ ចំនួន០១ (មួយគ្រឿង: ម៉ាកស្កាសរីពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ1BE-7150) ដែលជារបស់ ជនត្រូវចោទឈ្មោះ ទូច-តុង ដាក់ស្តែងប្រាកដមែន។ ក្រោយពីបានធ្វើតេស្តស្វែងរកសារធាតុញៀន ក្នុងខ្លួនលើឈ្មោះ ទូច-តុង ជាលទ្ធផលឃើញថា: មានសារធាតុញៀន (វិជ្ជមាន)។

-ផ្អែកតាមលិខិតលេខ.០១៤ រ.ប.ក/២៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ របស់ផ្នែកការងារប្រឆាំងគ្រឿងញៀន នៃអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ សូមគោរពជូន: ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ កម្មវត្ថុ: របាយការណ៍ឆ្លើយតបស្តីពីលទ្ធផល ដីកាបញ្ជូលឲ្យស្រាវជ្រាវជនសង្ស័យឈ្មោះ [redacted] ភេទស្រី អាយុ

ប្រហែល៣៥ឆ្នាំ ត្រូវបាបដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន <u>យោង:</u> <u>តាមដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ.៦២ (ខ) ព្រ.ទ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ និងចេញដោយ</u> លោក [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ <u>ជាលទ្ធផល:</u> ឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ នោះពុំស្នាក់នៅក្នុងមូលដ្ឋានឡើយ ដោយមូលហេតុ ពុំមានអត្តសញ្ញាណច្បាស់លាស់ បច្ចុប្បន្នសមត្ថកិច្ចយើងកំពុងស្រាវជ្រាវបន្ត។ ក្នុងន័យនេះអាចសន្និដ្ឋានបានថា: ជនដែលប្រព្រឹត្តអំពើនេះ នៅតែគេមិនស្គាល់ [redacted]នេះគប្បីស្នើសុំចៅក្រមស៊ើបសួរ ចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ទៅលើជនត្រូវចោទឈ្មោះ [redacted] **ភេទស្រី អាយុប្រហែល៣៥ឆ្នាំ** តាមបញ្ញត្តិមាត្រា ២៤៧ (ថ្មី) នៃច្បាប់ស្តីពីវិសោធន៍កម្មមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ២០០៧) តាមវិធាន និងតាមនីតិវិធីច្បាប់ជាធរមាន។

-ផ្អែកតាមចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ និងផ្អែកតាមលទ្ធផលនៃការស៊ើបអង្កេតស្រាវជ្រាវរបស់អាជ្ញាធរជំនាញ មានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ទាក់ទងទៅនឹងអង្គហេតុខាងលើនេះគឺមានភាពស៊ីសង្វាក់ប្រទាក់ក្រឡាគ្នាយ៉ាងជាក់លាក់ទៅនឹងសកម្មភាព ក៏ដូចជាចម្លើយពោលអះអាង (ចម្លើយបំភ្លឺ) ព្រមទាំងការសារភាពរបស់ភាគីនៅគ្រប់ដំណាក់កាលទាំងអស់ (ក៏ដូចជាអង្គហេតុទាំងមូលផងដែរ)។ សក្ខីកម្មនេះ អាចឱ្យតំណាងអយ្យការ ជឿជាក់បានថា៖ ពិតជាមានអំពើល្មើស និងព្យសនៈកម្មកើតឡើង ដែលបង្កដោយជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ បានប្រព្រឹត្តនូវអំពើល្មើសព្រហ្មទណ្ឌ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ ២០២៤ ជាក់ស្តែងប្រាកដមែន។

-ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ជានីតិជនមានស្មារតីទទួលខុសត្រូវនូវទង្វើរបស់ពួកខ្លួន ដែលជាអំពើល្មើស និងរំលោភបំពានលើច្បាប់ជាធរមាន ហើយបើពិនិត្យទៅលើសកម្មភាព ជាក់ស្តែងបង្ហាញឱ្យឃើញនូវចេតនាទុច្ចរិតរបស់ពួកជនទាំងនេះ ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាពរីករាលក្នុងសង្គម សេចក្តីសុខសាន្តរបស់អ្នកដទៃ ក៏ដូចជាសុវត្ថិភាពភូមិ/ឃុំ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ គប្បីទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធិភាព។ គ្មានសញ្ញាណ ក៏ដូចជាឯកសារណាមកបញ្ជាក់ អំពីភាពវិបលាសស្មារតី ឬភាពមិនប្រក្រតីរបស់ពួកជនត្រូវចោទទាំងនេះ ដើម្បីឱ្យពួកគេបានរួចផុតអំពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ។

-មានភស្តុតាង (ក៏ដូចជាសាក្សី) និងពិរុទ្ធភាពដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ ថាពិតជាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចត្រង់មុំផ្លូវ៦០ម៉ែត្រ សង្កាត់ចាតក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ជាក់ស្តែងប្រាកដមែន។

-ឯកសារ លិខិតស្នាម និងភស្តុតាងផ្សេងៗទៀត ដែលមានជាប់ទាក់ទិននៅក្នុងសំណុំរឿង គឺសុទ្ធតែបានរៀបចំ និងកសាងឡើងសមស្របតាមនីតិវិធី ដើម្បីជាមូលដ្ឋានផ្តល់ជូនអាជ្ញាធរតុលាការ ធ្វើការពិនិត្យពិចារណាវិនិច្ឆ័យ និងសេចក្តីសម្រេចប្រកបដោយតម្លាភាព និងយុត្តិធម៌។

## <u>ហេតុដូច្នេះសម្រេច៖</u>

ប្តឹងសុំទៅក្រមស៊ើបសួរ

១/.លែកលែងចោទប្រកាន់លើ

ឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៣៥ឆ្នាំ (គេចខ្លួន!!)

អំពីបទល្មើសព្រហ្មទណ្ឌ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ឆ្នាំ២០១២) ប្រព្រឹត្តនៅត្រង់ម្តុំផ្លូវ៦០ម៉ែត្រ ស្ថិតក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤។**

ដោយមូលហេតុ៖ **គ្មានសាចតាជាតិគ្រប់គ្រាន់**។

២/.ចោទប្រកាន់លើជនត្រូវចោទ

ឈ្មោះ [redacted] ភេទប្រុស អាយុ៣៧ឆ្នាំ (ឃុំខ្លួន កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤)

អំពីបទល្មើសព្រហ្មទណ្ឌ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** និងបទ: **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** (ឆ្នាំ២០១២) **ប្រព្រឹត្តនៅត្រង់ចំណុចមុខផ្ទះគ្មានលេខ លើផ្លូវលំ ស្ថិតក្នុងភូមិដើមចាន់ សង្កាត់ច្បារអំពៅទី.២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤។**

៣/.បញ្ជូនជនត្រូវចោទឈ្មោះ [redacted] (ដូចមានសាវតាជាតិ) ទៅជំនុំជម្រះ។

៤.បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ.[redacted] ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ (រួមទាំងវត្ថុតាង) ទៅចៅក្រមស៊ើបសួរ ដើម្បីចាត់ការតាមវិធាន និងនីតិវិធីច្បាប់ជាធរមាន។

ថ្ងៃសុក្រ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០២៤

**តំណាងអយ្យការ**

[redacted]

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធទី១៤**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**បន្ទប់ស៊ើបសួរ "ហ"**

លេខ ............... "ហ" ដដ

# ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក [redacted] ជាក្រឡាបញ្ជី ។

**-បានឃើញ** មាត្រា **២៤៧** មាត្រា **២៥០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**-បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] **អ.យ.ខ** ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ពាពរលេខ [redacted] **អ.យ.ខ** ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់លើជនត្រូវចោទ៖

**១**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៦ សញ្ជាតិសិង្ហបុរី កាន់លិខិតឆ្លងដែនលេខ [redacted], លេខ [redacted] និងលេខ [redacted] ទីកន្លែងកំណើតប្រទេស SINGAPORE អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ភូមិ១ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជានីតិជន ។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ [redacted] **"ហ" ដចន** ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ។

**២**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៦ សញ្ជាតិម៉ាឡេស៊ី កាន់លិខិតឆ្លងដែនសញ្ជាតិម៉ាឡេស៊ីលេខ [redacted] និងលេខ [redacted] កន្លែងកំណើតរដ្ឋ SABAH ប្រទេស ម៉ាឡេស៊ី អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ភូមិ១ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជានីតិជន ។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ [redacted] **"ហ" ដចន** ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ។

**៣**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៤ សញ្ជាតិសិង្ហបុរី មុខរបរ គ្មាន កាន់លិខិតឆ្លងដែនលេខ [redacted] និងលេខ [redacted] ទីកន្លែងកំណើតប្រទេស SINGAPORE អាសយដ្ឋានបច្ចុប្បន្ននៅអគារលេខ [redacted] ជាន់ទី [redacted] បន្ទប់លេខ០១ ផ្លូវលេខ [redacted] សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ពោះម៉ាយ ជានីតិជន ។ (ក្រៅឃុំ)

-ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ **គ្មាន** ។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ [redacted] **“ហ” ៨៥៨** ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ។

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **ឆបោក និងធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាបណ្ណ** ប្រព្រឹត្ត នៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ តាមមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ និង មាត្រា **៥២** នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ។

## អង្គហេតុដើមនៃរឿងនេះមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០១៥ ក្រុមហ៊ុន [redacted] បានបង្កើតឡើងក្រោមការណែនាំរបស់ជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលបានបបួលលោកស្រី [redacted] និងលោកស្រី [redacted] បង្កើតក្រុមហ៊ុនឈ្មួញជើងសាឧបករណ៍និស្សន្ទ ដោយសន្យាថាខ្លួននឹងរ៉ាប់រងលើការវិនិយោគ និងប្រតិបត្តិការនៅក្នុងក្រុមហ៊ុនទាំងមូល រីឯម្ចាស់ភាគហ៊ុនគ្រាន់តែឈរឈ្មោះនៅក្នុងលក្ខន្តិកៈ និងអាជ្ញាបណ្ណនៅតាមក្រសួងស្ថាប័នពាក់ព័ន្ធតែប៉ុណ្ណោះ ។ ក្រុមហ៊ុននេះមានលោកស្រី [redacted] ជា ប្រធានក្រុមប្រឹក្សាភិបាល លោកស្រី [redacted] ជាអភិបាល លោក [redacted] ជាអភិបាល និងលោក [redacted] អភិបាលក្រុមហ៊ុន [redacted] ទទួលបានអាជ្ញាបណ្ណជាឈ្មួញជើងសាឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុន [redacted] ដែលជាក្រុមហ៊ុនសមភាគីកណ្តាលពីនិយ័តករមូលបត្រកម្ពុជានៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ ។ ផ្អែកលើអាជ្ញាបណ្ណនេះក្រុមហ៊ុន [redacted] ក្នុងនាមជាឈ្មួញជើងសាឧបករណ៍និស្សន្ទរបស់ក្រុមហ៊ុន [redacted] មានសិទ្ធិត្រឹមតែផ្តល់នូវការប្រឹក្សាយោបល់ និងបង្កើតនូវគណនីសម្រាប់ឱ្យអតិថិជនធ្វើការជួញដូរឧបករណ៍និស្សន្ទដោយខ្លួនឯង (Self- Trade) តែប៉ុណ្ណោះ ។ នៅក្នុងឆ្នាំ២០១៦ ដដែលនោះ ជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានបន្ថែមនូវជម្រើសមួយទៀត ជូនដល់អតិថិជន គឺការស្នើសុំឱ្យតតិយជនធ្វើការជួញដូរឧបករណ៍និស្សន្ទជំនួសអតិថិជនដោយតម្រូវឱ្យអតិថិជនចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិ (Power of Attorney) ហើយក្រុមហ៊ុន [redacted] បានឱ្យក្រុមហ៊ុន [redacted] ដែលជាក្រុមហ៊ុនដៃគូបរទេសនៃក្រុមហ៊ុន [redacted] ធ្វើជាតតិយជនដើម្បីជួញដូរឧបករណ៍និស្សន្ទជំនួសអតិថិជន ប៉ុន្តែការពង្រីកនៃវិសាលភាពនៃអាជីវកម្មនេះ មិនបានសុំនូវអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជាឡើយ ។ នៅក្នុងប្រតិបត្តិការជាក់ស្តែង ការគ្រប់គ្រង និងដឹកនាំប្រតិបត្តិការក្រុមហ៊ុនទាំងមូល គឺស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ដោយមានឈ្មោះ [redacted] ជាអ្នកបច្ចេកទេសក្នុងការសម្របសម្រួលដោយផ្ទាល់លើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ ។ រីឯការគ្រប់គ្រងលើការជួញដូរ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺស្ថិតក្រោមការសម្រេចរបស់ជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ក្រោយពីបន្ថែមនូវជម្រើសនៃការជួញដូរឧបករណ៍និស្សន្ទនៅឆ្នាំ២០១៦ ឈ្មោះ [redacted] និងឈ្មោះ [redacted] បានផ្តួចផ្តើមគំនិតក្នុងការបង្កើតក្រុមហ៊ុនបន្ថែមថ្មីមួយឈ្មោះ [redacted] ដែលត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់ប្រតិបត្តិការជួញដូរថ្មីរបស់ក្រុមហ៊ុន [redacted] ដែលអនុញ្ញាតឱ្យតតិយជនធ្វើការជួញដូរឧបករណ៍និស្សន្ទជំនួសអតិថិជនទាំងដែលខ្លួនមិនមានអាជ្ញាបណ្ណក្នុងការធ្វើ

ប្រតិបត្តិការប្រភេទនេះ ។ ក្រុមហ៊ុន [redacted] មានឈ្មោះ [redacted] ជាអ្នកឈរឈ្មោះជាម្ចាស់ក្រុមហ៊ុន ប៉ុន្តែក្នុងប្រតិបត្តិការជាក់ស្តែង ការគ្រប់គ្រង និងដឹកនាំប្រតិបត្តិការក្រុមហ៊ុន គឺស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ដោយមានឈ្មោះ [redacted] ជាអ្នកបច្ចេកទេសក្នុងការសម្របសម្រួល ។ បន្ថែមពីនេះជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានប្រើប្រាស់ឈ្មោះក្រុមហ៊ុន [redacted] ដែលជាក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណស្របច្បាប់ពីនិយ័តករមូលបត្រកម្ពុជា ព្រមទាំងលុយដែលអតិថិជនជាច្រើនបានយកមកដាក់ ដើម្បីឱ្យតតិយជនធ្វើការជួញដូរឧបករណ៍និស្សន្ទ ជំនួស ។ ការបង្កើតឱ្យមាននូវជម្រើសនៃការជួញដូរនៅក្នុងក្រុមហ៊ុន [redacted] និងការបើកក្រុមហ៊ុន [redacted] គឺធ្វើឡើងដោយគំនិតផ្ទាល់ខ្លួនរបស់ជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន ។ បន្ទាប់ពីទទួលបានប្រាក់ជាច្រើនពីអតិថិជនជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានប្រមូលប្រាក់ទាំងនោះ និងប្រាក់មួយចំនួនរបស់ក្រុមហ៊ុន ហើយគេចខ្លួនទៅបរទេស ដោយគេចវេសមិនចូលមកដោះស្រាយជាមួយក្រុមហ៊ុន [redacted] ឡើយ ។ លុះនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ទើបក្រុមហ៊ុន [redacted] ដឹងថាមានការបាត់បង់សាច់ប្រាក់ប្រមាណជាង ២០.០០០.០០០ (ម្ភៃលាន) ដុល្លារសហរដ្ឋអាមេរិច ពីប្រព័ន្ធ [redacted] របស់ក្រុមហ៊ុន ។

## សំអាងហេតុ

-តាមចម្លើយរបស់ជនត្រូវចោទ, ដើមបណ្តឹងរដ្ឋប្បវេណី, សាក្សី និងឯកសារនានាដែលមាននៅក្នុងសំណុំរឿង អាចសន្និដ្ឋានបានថា៖ ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៦, ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៦ និងឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៤ ពិតជាបានប្រព្រឹត្តបទ **ឆបោក និងធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាបណ្ណ** ប្រាកដមែន ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនត្រូវចោទ

**១**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៦ សញ្ជាតិសិង្ហបុរី

**២**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៦ សញ្ជាតិម៉ាឡេស៊ី

**៣**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៤ សញ្ជាតិសិង្ហបុរី

ពីបទ៖ **ឆបោក និងធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាបណ្ណ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ តាមមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៥២** នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ។

## ហេតុដូច្នេះសម្រេច

-បញ្ជូនជនត្រូវចោទ៖

**១**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៦ សញ្ជាតិសិង្ហបុរី

ប្រតិបត្តិការប្រភេទនេះ ។ ក្រុមហ៊ុន [redacted] មានឈ្មោះ [redacted] ជាអ្នកឈរឈ្មោះជាម្ចាស់ក្រុមហ៊ុន ប៉ុន្តែក្នុងប្រតិបត្តិការជាក់ស្តែង ការគ្រប់គ្រង និងដឹកនាំប្រតិបត្តិការក្រុមហ៊ុន គឺស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ដោយមានឈ្មោះ [redacted] ជាអ្នកបច្ចេកទេសក្នុងការសម្របសម្រួល ។ បន្ថែមពីនេះជនត្រូវចោទឈ្មោះ [redacted] និង ឈ្មោះ [redacted] បានប្រើប្រាស់ឈ្មោះក្រុមហ៊ុន [redacted] ដែលជាក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណស្របច្បាប់ពីនិយ័តករមូលបត្រកម្ពុជា ព្រមទាំងលុយដែលអតិថិជនជាច្រើនបានយកមកដាក់ ដើម្បីឱ្យតតិយជនធ្វើការជួញដូរឧបករណ៍និស្សន្ទ ជំនួស ។ ការបង្កើតឱ្យមាននូវជម្រើសនៃការជួញដូរនៅក្នុងក្រុមហ៊ុន [redacted] និងការបើកក្រុមហ៊ុន [redacted] គឺធ្វើឡើងដោយគំនិតផ្ទាល់ខ្លួនរបស់ជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន ។ បន្ទាប់ពីទទួលបានប្រាក់ជាច្រើនពីអតិថិជនជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានប្រមូលប្រាក់ទាំងនោះ និងប្រាក់មួយចំនួនរបស់ក្រុមហ៊ុន ហើយគេចខ្លួនទៅបរទេស ដោយគេចវេសមិនចូលមកដោះស្រាយជាមួយក្រុមហ៊ុន [redacted] ឡើយ ។ លុះនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ទើបក្រុមហ៊ុន [redacted] ដឹងថាមានការបាត់បង់សាច់ប្រាក់ប្រមាណជាង ២០.០០០.០០០ (ម្ភៃលាន) ដុល្លារសហរដ្ឋអាមេរិច ពីប្រព័ន្ធ [redacted] របស់ក្រុមហ៊ុន ។

## សំអាងហេតុ

-តាមចម្លើយរបស់ជនត្រូវចោទ, ដើមបណ្តឹងរដ្ឋប្បវេណី, សាក្សី និងឯកសារនានាដែលមាននៅក្នុងសំណុំរឿង អាចសន្និដ្ឋានបានថា៖ ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៦, ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៦ និងឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៤ ពិតជាបានប្រព្រឹត្តបទ **ឆបោក និងធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាបណ្ណ** ប្រាកដមែន ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនត្រូវចោទ

**១**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៦ សញ្ជាតិសិង្ហបុរី

**២**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៦ សញ្ជាតិម៉ាឡេស៊ី

**៣**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៤ សញ្ជាតិសិង្ហបុរី

ពីបទ៖ **ឆបោក និងធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាបណ្ណ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ តាមមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៥២** នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ។

## ហេតុដូច្នេះសម្រេច

-បញ្ជូនជនត្រូវចោទ៖

**១**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៦ សញ្ជាតិសិង្ហបុរី

**២**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៦ សញ្ជាតិម៉ាឡេស៊ី

**៣**-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៦៤ សញ្ជាតិសិង្ហបុរី

ពីបទ៖ **ឆបោក និងធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាបណ្ណ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ តាមមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ និងមាត្រា **៥២** នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះតាមច្បាប់ ។

**បានទទួលដំណឹង**

ថ្ងៃ.........................ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.......ខែកញ្ញា ឆ្នាំ២០២៣

**តំណាងអយ្យការ**

**ក្រឡាបញ្ជី**

ថ្ងៃ.......................ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.......ខែកញ្ញា ឆ្នាំ២០២៣

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១៥**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**បន្ទប់ស៊ើបសួរ "ហ"**

លេខ ............... "ហ" ដដ

## ដីកាសម្រេចលើកលែងចោទប្រកាន់

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក [redacted] ជាក្រឡាបញ្ជី ។

-**បានឃើញ** មាត្រា **២៤៧** ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា **២៤៧**, **៣៦៨**, **៣៧២** និងមាត្រា **៣៨២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] **អ.យ.ន** ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ [redacted] **អ.យ.ន** ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានអង្កេតស្រាវជ្រាវ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់ហើយ

### សំអាងហេតុ

[redacted] មានជាប់ពាក់ព័ន្ធនឹងអំពើល្មើស **បើកកន្លែងលេងល្បែងស៊ីសង** ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ក្រុមទី១ ផ្លូវបេតុង ភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៥** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ។

-ក្រោយពីចៅក្រមស៊ើបសួរបានស្រាវជ្រាវរកសាវតាជាតិរបស់ជនត្រូវចោទខាងលើ តាមដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ [redacted] **"ហ" ព្រ.ទ** ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ ព្រមទាំងបានរំលឹកតាមលិខិតស្នើសុំរបាយការណ៍ស្តីពីដីកាចាត់ឱ្យស៊ើបសួរជំនួស លេខ [redacted] **រប/២៣** ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ប៉ុន្តែរហូតមកដល់ពេលនេះនៅតែពុំមានរបាយការណ៍ឆ្លើយតបរបស់មន្ត្រីនគរបាលយុត្តិធម៌អំពីសាវតាជាតិរបស់ [redacted] នៅឡើយ ។

-ដីកាសន្និដ្ឋានស្ថាពរលេខ [redacted] **អ.យ.ន** ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចលើកលែងចោទលើ [redacted] គប្បីសម្រេចលើកលែងចោទប្រកាន់តាមបញ្ញត្តិមាត្រា **២៤៧** ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា **២៤៧**, មាត្រា **៣៦៨**, មាត្រា **៣៧២** និងមាត្រា **៣៨២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-ដីកាសម្រេចលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរពុំមានអាជ្ញាអស់ជំនុំឡើយ បើទោះបីជាដីកានេះចូលជាស្ថាពរ ប្រសិនបើមានលេចឡើងបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញបានតាមការផ្តើមគំនិតរបស់តំណាងអយ្យការ តាមមាត្រា **២៥១** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**សម្រេច**

លើកលែងចោទប្រកាន់លើ [redacted] ពីបទ **បើកកន្លែងលេងល្បែងស៊ីសង** ប្រព្រឹត្តនៅចំណុចមុខផ្ទះគ្មានលេខ ក្រុមទី១ ផ្លូវបេតុង ភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៥** នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ។

លេខ....................**អ.យ.ន**

**បានទទួលដំណឹង**

ថ្ងៃ.......................ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី........ខែសីហា ឆ្នាំ២០២៣

**តំណាងអយ្យការ**

ថ្ងៃ............................ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី.......ខែសីហា ឆ្នាំ២០២៣

**ចៅក្រមស៊ើបសួរ**

**ក្រឡាបញ្ជី**

**ឧបសម្ព័ន្ធទី១៥**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
មន្ទីរស៊ើបសួរ "ហ"

លេខ៖.....................''ហ'' ជជ

## ដីកាដំណោះស្រាយ

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោក [redacted] ជាក្រឡាបញ្ជី។

- **បានឃើញ** មាត្រា **២៤៧ថ្មី** មាត្រា **២៤៩** និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] អ.យ.ឈ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** សំណុំរឿងស៊ើបសួរលេខ [redacted] ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។
- **បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

*ក្រោយពីបានស៊ើបសួរលើអង្គហេតុចប់សព្វគ្រប់ហើយ ឃើញថា៖*

នាមត្រកូល-នាមខ្លួន [redacted] ភេទប្រុស កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ជនជាតិអ៊ីរ៉ង់ សញ្ជាតិខ្មែរ មុខរបរពេទ្យធ្មេញ (ឯកទេសពត់ធ្មេញ) ទីកន្លែងកំណើតនៅក្រុងរ៉ាស់ សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ សាសនាអ៊ីស្លាម មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះ [redacted] សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] "រស់" គ្មានកូន ជានីតិជន។ *(ក្រៅឃុំ)*

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **ប្រកបវិជ្ជាជីវៈសុខាភិបាលដោយគ្មានអាជ្ញាបណ្ណ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ មាត្រា **២៨** នៃច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល។

### អង្គហេតុដែលបានប្រព្រឹត្ត

ឈ្មោះ [redacted] ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិអ៊ីរ៉ង់ បានចូលមកប្រទេសកម្ពុជាក្នុងខែមីនា ឆ្នាំ២០១៥ ដោយប្រកបរបរជាគ្រូពេទ្យធ្មេញនៅមន្ទីរពេទ្យធ្មេញ [redacted] រហូតដល់បច្ចុប្បន្ន ដោយបានចុះបញ្ជីការនៅគណៈទន្តពេទ្យកម្ពុជារួចរាល់។ ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលត្រូវបានអនុម័ត កាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៦ ដោយច្បាប់នេះតម្រូវឱ្យបុគ្គលទាំងឡាយដែលមានបំណងប្រកបវិជ្ជាជីវៈសុខាភិបាល ត្រូវមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ដោយអ្នកវិជ្ជាជីវៈសុខាភិបាលមានរយៈពេល១២ខែយ៉ាងយូរ ដើម្បីដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល។ ឈ្មោះ [redacted] ទោះបីជាបានប្រកបវិជ្ជាជីវៈសុខាភិបាលនៅកម្ពុជាចាប់តាំងពីឆ្នាំ២០១៥ មកតែជនត្រូវចោទទើបតែបានអាជ្ញាបណ្ណវិជ្ជាជីវៈទន្តពេទ្យសាស្ត្រ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយមានសុពលភាពចាប់ពីថ្ងៃទី

០១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ពោល គឺក្រោយពីមានពាក្យបណ្ដឹង ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៣ របស់ឈ្មោះ [redacted] ភេទស្រី អាយុ ៤០ឆ្នាំ ប្ដឹងថាជនត្រូវចោទ បានបង្ករបួសដោយអចេតនាបណ្ដាល មកពីការពត់ធ្មេញ កាលពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ នៅមន្ទីរព្យាបាលធ្មេញបច្ចឹម។

## សំអាងហេតុ

១- តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨៣ បាន ឆ្លើយថា៖ ក្នុងអំឡុងឆ្នាំ២០០៦ ខ្លួនធ្លាប់បានទៅទទួលសេវាព្យាបាលធ្មេញ [redacted] ដោយដកធ្មេញថ្គាមទាល់ចំនួន៣។ ដោយខ្លួនយល់ថា ធ្លាប់បានទៅទទួលសេវាព្យាបាលធ្មេញនៅមន្ទីរព្យាបាលធ្មេញបច្ចឹមកន្លងមក ទើបនៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៥ ខ្លួនបានទៅមន្ទីរព្យាបាលធ្មេញ [redacted] ក្នុងបំណងពិគ្រោះយោបល់ លើការពត់ធ្មេញ។ ការពិគ្រោះយោបល់នោះ មន្ទីរព្យាបាលធ្មេញបច្ចឹមបានចាត់តាំងទន្តពេទ្យឈ្មោះ [redacted] ដើម្បីពិគ្រោះយោបល់ និងពិភាក្សា។ ហើយពេលនោះខ្លួនបានប្រាប់គាត់ថា ធ្លាប់មានជំងឺសន្លាក់ឆ្អឹងថ្គាម (TMJ) ក្នុងអំឡុងឆ្នាំ២០០០ ក្រោយពីបានពិគ្រោះយោបល់ និងពិភាក្សាគ្នារួចមក ទន្តពេទ្យឈ្មោះ [redacted] បានថតរូបទម្រង់ធ្មេញ រួចមកបានចេញព័ត៌មានអ្នកជំងឺ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ដែលចុះ ហត្ថលេខារបស់ជំនួយការគាត់ឈ្មោះ [redacted] និងខ្លួន ហើយបានណាត់ទៅរយៈពេលពី១ ឬ ២សប្ដាហ៍ទៀត។ នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ មានការបង់ប្រាក់ថ្លៃពិគ្រោះ ចំនួន ៥០ (ហាសិប) ដុល្លារអាមេរិក ហើយបាន កំណត់ថ្លៃព្យាបាលចំនួន ២៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក។ រយៈពេលពី១ ឬ ២សប្ដាហ៍ ក្រោយមកខ្លួន បានទៅមន្ទីរព្យាបាលធ្មេញបច្ចឹមតាមការណាត់ជួប។ ពេលនោះទន្តពេទ្យឈ្មោះ [redacted] បាន យករូបថតទម្រង់ធ្មេញមកពន្យល់ថា ធ្មេញខ្លួនមានបញ្ហា ពយ ពេលសើចចេញអញ្ចាញខាងលើ ហើយក្រោយ តម្រង់ធ្មេញរួចហើយ នឹងលែងមានបញ្ហាឈឺសន្លាក់នាពេលអនាគត និងបញ្ជាក់ពីវិធីព្យាបាលថា មិនមានការ ដកធ្មេញទេ ដាក់បង្គោលដើម្បីទាញធ្មេញឡើងលើឱ្យខ្លី ហើយកាត់អញ្ចាញដើម្បីឱ្យធ្មេញសមល្មម និងការទាញ ធ្មេញខាងលើឱ្យត្រូវងាំធ្មេញខាងក្រោម ហើយទន្តពេទ្យឈ្មោះ [redacted] និយាយបន្ថែមថា រយៈ ពេលព្យាបាល ដោយមិនដកធ្មេញ និងមានរយៈពេលព្យាបាល ២ឆ្នាំ ហើយនៅថ្ងៃនេះមិនមានការបង់ប្រាក់ទេ។ ក្រោយពីបានពិចារណា និងការស្វែងយល់អំពីព័ត៌មានរួចមក ខ្លួនប្រើប្រាស់ពេលប្រហែល ៨ខែ រហូតដល់ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៦ ខ្លួនបានទៅមន្ទីរព្យាបាលធ្មេញបច្ចឹមសាខាផ្លូវនរោត្តម ក្នុងបំណងបញ្ជាក់អំពីជំងឺសន្លាក់ ឆ្អឹងថ្គាម (TMJ) ឱ្យកាន់តែច្បាស់ តែទន្តពេទ្យឈ្មោះ [redacted] បានឱ្យខ្លួនឡើងលើគ្រែពេទ្យ ធ្មេញ ហើយចាប់ផ្ដើមពត់ធ្មេញ ដោយភ្ជាប់ឧបករណ៍សម្រាប់ពត់ធ្មេញនៅតាមធ្មេញលើទាំងអស់ ហើយបានបន្ត ការព្យាបាល និងការបង់ប្រាក់ជាបន្តបន្ទាប់។ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ បានកំណត់ឡើងថ្លៃខុសពី និយាយ គ្នាលើកមុន គឺថ្លៃព្យាបាលមានចំនួន ២៩៧០ (ពីរពាន់ប្រាំបួនរយចិតសិប) ដុល្លារអាមេរិក ហើយនៅ ថ្ងៃនោះខ្លួនបានបង់ប្រាក់លើកទី១ ចំនួន ១២០០ (មួយពាន់ពីររយ) ដុល្លារអាមេរិក។ ការព្យាបាលតាមការណាត់ ជាបន្តបន្ទាប់ ហើយខ្លួនបានបង់ប្រាក់លើកទី២ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ចំនួន ៣០០ (បីរយ) ដុល្លារអាមេរិក និងលើកទី៣ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ចំនួនសរុប ១៤៧០ (មួយពាន់បួនរយចិតសិប) ដុល្លារអាមេរិក សរុប ការបង់ប្រាក់ទាំងបីលើកមានចំនួន ២៩៧០ (ពីរពាន់ប្រាំបួនរយចិតសិប) ដុល្លារអាមេរិក។ បន្ទាប់ពីការបង់ប្រាក់ គ្រប់ចំនួនឱ្យមន្ទីរព្យាបាលធ្មេញបច្ចឹម ទន្តពេទ្យឈ្មោះ [redacted] បានព្យាបាលជាបន្តបន្ទាប់ មិនដែលមានបញ្ហាអ្វីទេ រហូតដល់ចុងខែមេសា ឆ្នាំ២០២០ ខ្លួនបានប្រាប់ទៅទន្តពេទ្យឈ្មោះ [redacted] ថាខ្លួនបានឈឺសន្លាក់ថ្គាមតាមតេឡេក្រាម ហើយគាត់ប្រាប់ថាឱ្យទ្រាំសិនរង់ចាំជួបគ្នាថ្ងៃណាត់ពេទ្យ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។ ថ្ងៃណាត់ជួបនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ទន្តពេទ្យឈ្មោះ [redacted] បានដាក់ឧបករណ៍ទប់ធ្មេញលើក្រោម តែមិនមានបសិទ្ធិភាពទាល់តែសោះ ហើយខ្លួនបានផ្ដល់ព័ត៌មាន អំពីការមិនសះជានេះច្រើនដង និងសុំអង្វរឱ្យរកវិធីព្យាបាលផ្សេងៗ តែទន្តពេទ្យឈ្មោះ [redacted]

ហាក់ដូចជាពងើយកន្តើយ។ កាលបរិច្ឆេទព្យាបាលខ្លួនចុងក្រោយនៅចុងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ដោយមានមូលហេតុថា ខ្លួនកំណត់ពេលវេលាពិគ្រោះយោបល់ក៏មិនបាន និងសុំជួបក៏មិនបាន ទើបខ្លួនដាក់សំណើតាមតេឡេក្រាមទៅមន្ទីរព្យាបាលធ្មេញបច្ចឹមសាខាផ្លូវនរោត្តម ទន្តពេទ្យ ឈ្មោះ [redacted] ឱ្យទទួលខុសត្រូវ និងត្រូវសងសំណងដល់ខ្លួន។ ដោយអស់ជម្រើស នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ខ្លួនបានជ្រើសរើសការព្យាបាល នៅកន្លែងផ្សេង គឺមន្ទីរពេទ្យ[redacted]។ ចំពោះបញ្ហាដែលខ្លួនឈប់ព្យាបាលនៅពេទ្យនេះ គឺជាបញ្ហារបស់ពេទ្យដោយសារតែគាត់តែងតែប្រាប់ថាគាត់ជាប់រវល់ ហើយពេលខ្លះខ្លួនបានទាក់ទងទៅគាត់ហើយគាត់បានចូលមើលហើយមិនឆ្លើយតបដូចមិនយកចិត្តទុកដាក់ចំពោះការងារមួយនេះ។ នៅពេលដែលខ្លួនបានទាក់ទងទៅគាត់ដើម្បីពិភាក្សាអំពីជំងឺនេះជាមួយ គាត់គ្រាន់តែឆ្លើយតបវិញដោយផ្ញើសារជាគេហទំព័រក្នុងហ្វេសប៊ុកដើម្បីឱ្យខ្លួនសិក្សាដោយខ្លួនឯង ដោយគាត់មិនបានព្យាយាមសិក្សាពីជំងឺនេះឱ្យខ្លួនឡើយ។ ម្យ៉ាងវិញទៀតក្រោយពេលដែលខ្លួនបានប្រាប់គាត់ថាខ្លួនកើតជំងឺបាក់ទឹកចិត្តដោយសារតែការព្យាបាលនេះ គាត់ក៏បានផ្តាច់ទំនាក់ទំនង និងឈប់ឆ្លើយតបសារតែម្តង។ ក្នុងអំឡុងពេលដែលខ្លួនកំពុងទទួលការព្យាបាលជាមួយឈ្មោះ [redacted] នេះ ជំងឺនេះឈឺកាន់តែខ្លាំងមិនមានការធូរស្បើយអ្វីឡើយ បណ្តាលឱ្យខ្លួនមិនអាចធ្វើការបានអស់រយៈពេលយ៉ាងយូរប្រហែលជាង ៥ ទៅ ៦ ខែ។ លើសពីនេះទៅទៀតក្នុងអំឡុងពេលដែលខ្លួនទៅព្យាបាលនៅមន្ទីរពេទ្យ[redacted]ជាមួយឈ្មោះ [redacted] គឺគាត់មិនមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលក្នុងប្រទេសក្នុងប្រទេសកម្ពុជាទេ។

២- ចម្លើយបដិសេធរបស់ជនត្រូវចោទឈ្មោះ [redacted]) ភេទប្រុស កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ដែលថា៖ ខ្លួនបានចូលបម្រើការជាទន្តពេទ្យនៅមន្ទីរព្យាបាលធ្មេញ[redacted] នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥ ហើយក្នុងឆ្នាំ២០១៥ ដដែលនេះខ្លួនរៀបចំចុះបញ្ជីការក្នុងបញ្ជីគណៈទន្តពេទ្យកម្ពុជា ហើយបានចេញអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រលេខ [redacted] ចុះថ្ងៃទី[redacted] ខែ[redacted] ឆ្នាំ [redacted] ឱ្យខ្លួនមានសម្បទានក្នុងការប្រកបវិជ្ជាជីវៈទន្តពេទ្យ។ ចាប់ពីពេលដែលខ្លួនបានចុះបញ្ជីការនៅគណៈទន្តពេទ្យកម្ពុជា ខ្លួនបានបង់ប្រាក់ជាប្រចាំ ហើយរហូតមកដល់ពេលនេះ ខ្លួនមិនធ្លាប់ត្រូវបានជាប់ទណ្ឌកម្មខាងវិន័យ ការផ្អាកអាជ្ញាបណ្ណ ឬ លុបឈ្មោះចេញពីបញ្ជីគណៈទណ្ឌពេទ្យឡើយ។ កាលពីឆ្នាំ២០១៥ អតិថិជនឈ្មោះ [redacted] បានចូលមកប្រឹក្សាការពត់ធ្មេញ និងតម្រង់ធ្មេញជាមួយខ្លួន ប៉ុន្តែនៅអំឡុងខែឧសភា ឆ្នាំ២០១៦ ទើបអតិថិជនឈ្មោះ [redacted] ព្រមទទួលការពត់ធ្មេញ និងតម្រង់ធ្មេញជាមួយនឹងខ្លួន។ ខ្លួនចាប់ផ្តើមពត់ធ្មេញ និងតម្រង់ធ្មេញឱ្យអតិថិជនឈ្មោះ [redacted] នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ រហូតដល់ថ្ងៃចុងក្រោយនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០។ ខ្លួនបានបញ្ជាក់ថា មុនការព្យាបាលពត់ធ្មេញ និងតម្រង់ធ្មេញអតិថិជនឈ្មោះ [redacted] បានផ្តល់ព័ត៌មានថា គាត់មានបញ្ហាសន្លាក់ឆ្អឹងថ្គាម (TMJ) ដូចមានក្នុងលិខិតព័ត៌មានអ្នកជំងឺ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ បន្ទាប់មកខ្លួនបានធ្វើឯកសារកំណត់ត្រាព្យាបាលឱ្យឈ្មោះ [redacted] ពេលនោះថាមានប្រវត្តិជំងឺសន្លាក់ឆ្អឹងថ្គាម (TMJ) ហើយខ្លួនបានពន្យល់អំពីបទបង្ហាញទៅឈ្មោះ [redacted] អំពីជំងឺសន្លាក់ឆ្អឹងថ្គាម (TMJ) ខ្លួនបានធ្វើបទបង្ហាញអំពីហានីភ័យដែលអាចនឹងកើតឡើង ហើយអ្នកជំងឺនៅតែទទួលយកការព្យាបាលនេះ។ អតិថិជនឈ្មោះ ហេង ណារី បានបង់ប្រាក់ថ្លៃពត់ធ្មេញ និងតម្រង់ធ្មេញគ្រប់ចំនួនរួចហើយ។ ការពត់ធ្មេញ និងតម្រង់ធ្មេញឱ្យអតិថិជនឈ្មោះ ហេង ណារី មិនទាន់បានបញ្ចប់ទេ តែឈ្មោះ [redacted] បានបដិសេធបន្តការព្យាបាល ហើយសុំឱ្យមន្ទីរព្យាបាលធ្មេញបច្ចឹមសងប្រាក់វិញ ហើយខាងមន្ទីរព្យាបាលធ្មេញ[redacted]បញ្ជាក់ថាខ្លួនមិនមានកំហុសទេ ហើយឈ្មោះ [redacted] ក៏មិនបានចូលមកព្យាបាលតាមការកំណត់លើកក្រោយៗរបស់មន្ទីរព្យាបាលធ្មេញ[redacted]ដែរ។ អំពីស្ថានភាពរបស់អតិថិជនឈ្មោះ [redacted] មុនពេលគាត់ទៅពេទ្យផ្សេង ដោយឈប់ពត់ធ្មេញ និងតម្រង់ធ្មេញនៅមន្ទីរព្យាបាលធ្មេញ[redacted] គឺមានឈ្មោះ [redacted] សភាពធម្មតា។ បន្ទាប់ពីមានការកោះហៅរបស់គណៈទន្តពេទ្យ ខ្លួនបានផ្តល់ឯកសារកំណត់ត្រាព្យាបាល និងឯកសារផ្សេងៗទៀត។ ចំពោះការដោះស្រាយក្នុងរឿងនេះក៏មានក្រុមប្រឹក្សាវិន័យថ្នាក់ជាតិ និងអ្នកជំនាញពត់ធ្មេញចូលរួមដែរ។ ខ្លួនបានប្រតិបត្តិស្របតាមបច្ចេកទេសពត់តម្រង់ធ្មេញ ប៉ុន្តែចំពោះការ

ព្យាបាលមិនទាន់បញ្ចប់ពេញលេញនៅឡើយទេ ដោយសារអ្នកជំងឺខ្លួនឯងឈប់មកទទួលការព្យាបាលបន្ត និងទៅពត់ធ្មេញនៅកន្លែងផ្សេង គឺមិនមែនកំហុសរបស់ខ្លួនទេ។

៣- ជនត្រូវចោទមាននីតិសម្បទាគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌលើអំពើរបស់ខ្លួន ហើយអំពើរបស់ជនត្រូវចោទបានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម និងប៉ះពាល់ដល់បុគ្គលភាព សុខភាពបុគ្គល ដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស។

៤- លទ្ធផលកោសល្យវិច័យលើការពិនិត្យព្យាបាលជំងឺមាត់ធ្មេញរបស់អ្នកជំងឺឈ្មោះ [redacted] លេខ [redacted] ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ គណៈទន្តពេទ្យកម្ពុជា បញ្ជាក់ថា៖ ក្រុមប្រឹក្សាវិន័យថ្នាក់ជាតិរបស់គណៈទន្តពេទ្យកម្ពុជាបានធ្វើការសិក្សាលើករណីអ្នកជំងឺឈ្មោះ [redacted] ភេទស្រី អាយុ៤០ឆ្នាំ ដែលបានប្តឹង ទន្តពេទ្យឈ្មោះ [redacted] ភេទប្រុស ដែលបម្រើការងារនៅមន្ទីរព្យាបាលធ្មេញ [redacted] ពីបទបង្ករបួសស្នាមដោយចេតនាដោយកំហុសវិជ្ជាជីវៈ។ ក្រោយពីបានពិនិត្យ ក្រុមប្រឹក្សាវិន័យថ្នាក់ជាតិឃើញថា ទន្តពេទ្យឈ្មោះ [redacted] ជាជនជាតិអ៊ីរ៉ង់ បានចុះបញ្ជីនៅគណៈទន្តពេទ្យកម្ពុជាក្នុងនាមជាទន្តឡបរទេសចាប់តាំងពីឆ្នាំ២០១៥ មក។ ទន្តពេទ្យឈ្មោះ [redacted] បានទទួលការអនុញ្ញាតឱ្យចុះបញ្ជីការនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ និងអាជ្ញាបណ្ណវិជ្ជាជីវៈទន្តសាស្ត្រ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ក្នុងនាមជាទន្តពេទ្យជាតិ។ ឈ្មោះ [redacted] ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិអ៊ីរ៉ង់ បានចូលមកប្រទេសកម្ពុជាក្នុងខែមីនា ឆ្នាំ២០១៥ ដោយប្រកបរបរជាគ្រូពេទ្យធ្មេញនៅមន្ទីពេទ្យធ្មេញ [redacted] រហូតដល់បច្ចុប្បន្ន ដោយបានចុះបញ្ជីការនៅគណៈទន្តពេទ្យកម្ពុជារួចរាល់។ ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ត្រូវបានអនុម័តកាលពីថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០១៦ ដោយច្បាប់នេះតម្រូវឱ្យបុគ្គលទាំងឡាយដែលមានបំណងប្រកបវិជ្ជាជីវៈសុខាភិបាល ត្រូវមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ដោយអ្នកវិជ្ជាជីវៈសុខាភិបាលមានរយៈពេល ១២ខែយ៉ាងយូរ ដើម្បីដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល។ ឈ្មោះ [redacted] ទោះបីជាបានប្រកបវិជ្ជាជីវៈសុខាភិបាលនៅកម្ពុជាចាប់តាំងពីឆ្នាំ២០១៥មក តែជននេះទើបតែបានអាជ្ញាបណ្ណវិជ្ជាជីវៈទន្តពេទ្យសាស្ត្រ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយមានសុពលភាពចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ពោលគឺក្រោយពី មានពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ភេទស្រី អាយុ ៤០ឆ្នាំ ប្តឹងថាឈ្មោះ [redacted] បានបង្ករបួសដោយអចេតនាបណ្តាលមកពីការពត់ធ្មេញ កាលពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ នៅមន្ទីរព្យាបាលធ្មេញ [redacted]។

៥- តំណាងអយ្យការបានប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ទៅជំនុំជម្រះពីបទ៖ **ប្រកបវិជ្ជាជីវៈសុខាភិបាលដោយគ្មានអាជ្ញាបណ្ណ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ មាត្រា **២៨** នៃច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល តាមដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣។

៦- មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ពីបទ៖ **ប្រកបវិជ្ជាជីវៈសុខាភិបាលដោយគ្មានអាជ្ញាបណ្ណ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ មាត្រា **២៨** នៃច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល។

៧- នៅក្នុងដំណាក់កាលស៊ើបសួរ ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយដីកាសម្រេច

លេខ [redacted] ដើម្បីជានាវត្តមានជនត្រូវចោទនៅចំពោះមុខតុលាការ តម្បីរក្សាជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ស្របតាមមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>**ហេតុដូច្នេះ សម្រេច**</u>

១- ចោទប្រកាន់ និងបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ **ទៅជំនុំជម្រះ** ពីបទ៖ **ប្រកបវិជ្ជាជីវៈសុខាភិបាលដោយគ្មានអាជ្ញាបណ្ណ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ មាត្រា **២៨** នៃច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល។

២- រក្សាជនត្រូវចោទឈ្មោះ [redacted] ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នូវកាតព្វកិច្ចដូចខាងក្រោម៖

ក-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រម។

ខ-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រម។

គ-ត្រូវបង្ហាញខ្លួននៅសប្តាហ៍ទី១ ជារៀងរាល់ខែនៅចំពោះមុខចៅក្រម។

បានទទួលដំណឹងរួចហើយ

ថ្ងៃ.................កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ថ្ងៃ.................កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី...........ខែធ្នូ ឆ្នាំ២០២៣ រាជធានីភ្នំពេញ ថ្ងៃទី...........ខែធ្នូ ឆ្នាំ២០២៣

**តំណាងអយ្យការ** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី១៦**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

## លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ

[redacted]

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** មាត្រា ២៤៧ថ្មី និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**-បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ [redacted] ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣។

ជូនដំណឹងដល់ ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ជនជាតិអ៊ីរ៉ង សញ្ជាតិខ្មែរ មុខរបរពេទ្យធ្មេញ (ឯកទេសពត់ធ្មេញ) សាសនាអ៊ិស្លាម មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះ [redacted] សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ***ជនត្រូវចោទ***។

ត្បិតសំណុំរឿងព្រហ្មទណ្ឌខាងលើនេះ យើងបានសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះតាមដីកាដំណោះស្រាយខាងលើនេះរួចហើយ ដោយមានខ្លឹមសារដូចខាងក្រោម៖

### ហេតុដូច្នេះ សម្រេច

១- ចោទប្រកាន់ និងបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ **ទៅជំនុំជម្រះ** ពីបទ៖ **ប្រកបវិជ្ជាជីវៈសុខាភិបាលដោយគ្មានអាជ្ញាបណ្ណ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ មាត្រា **២៨** នៃច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល។

២- រក្សាជនត្រូវចោទឈ្មោះ [redacted] ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនូវកាតព្វកិច្ចដូចខាងក្រោម៖

ក-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រម។
ខ-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រម។
គ-ត្រូវបង្ហាញខ្លួននៅសប្តាហ៍ទី១ ជារៀងរាល់ខែនៅចំពោះមុខចៅក្រម។

ថ្ងៃព្រហស្បតិ៍ ២ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣
**ចៅក្រមស៊ើបសួរ**

យើង.............................................បានប្រគល់លិខិតជូនដំណឹង
នេះដល់ឈ្មោះ...........................................ទីលំនៅបច្ចុប្បន្នភូមិ
...............................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ
...............................ខេត្ត/រាជធានី.........................................។
ធ្វើនៅថ្ងៃទី............ខែ..............ឆ្នាំ២០២...

**អ្នកទទួល** **អ្នកប្រគល់**

**ឧបសម្ព័ន្ធទី១៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ [redacted]

**លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ**

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** មាត្រា ២៤៧ថ្មី និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**-បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ [redacted] ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣។

ជូនដំណឹងដល់ ឈ្មោះ [redacted] ភេទស្រី កើតនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] សង្កាត់ដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ***ដើមបណ្តឹងរដ្ឋប្បវេណី***។

ត្បិតសំណុំរឿងព្រហ្មទណ្ឌខាងលើនេះ យើងបានសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះតាមដីកាដំណោះស្រាយខាងលើនេះរួចហើយ។

ថ្ងៃព្រហស្បតិ៍ ២ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣

**ចៅក្រមស៊ើបសួរ**

យើង..............................................បានប្រគល់លិខិតជូនដំណឹង

នេះដល់ឈ្មោះ...........................................ទីលំនៅបច្ចុប្បន្នភូមិ

...................................ឃុំ/សង្កាត់...............................ស្រុក/ខណ្ឌ

...................................ខេត្ត/រាជធានី.........................................។

ធ្វើនៅថ្ងៃទី.............ខែ..............ឆ្នាំ២០២...

**អ្នកទទួល** **អ្នកប្រគល់**

**ឧបសម្ព័ន្ធទី១៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

[redacted]

## លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** មាត្រា ២៤៧ថ្មី និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**-បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ [redacted] ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣។

ជូនដំណឹងដល់ លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើម្បីរដ្ឋប្បវេណីឈ្មោះ [redacted] មានការិយាល័យស្ថិតនៅអគារ [redacted] មហាវិថីសម្តេចប៉ែននុត សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ឱ្យបានជ្រាបថា ត្បិតសំណុំរឿងព្រហ្មទណ្ឌខាងលើនេះ យើងបានសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះតាមដីកាដំណោះស្រាយខាងលើនេះរួចហើយ។

ថ្ងៃព្រហស្បតិ៍ ២ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣
**ចៅក្រមស៊ើបសួរ**

យើង..........................................បានប្រគល់លិខិតជូនដំណឹង
នេះដល់ឈ្មោះ..........................................ទីលំនៅបច្ចុប្បន្នភូមិ
..................................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ
..................................ខេត្ត/រាជធានី..........................................។
ធ្វើនៅថ្ងៃទី.............ខែ..............ឆ្នាំ២០២...

**អ្នកទទួល** **អ្នកប្រគល់**

**ឧបសម្ព័ន្ធទី១៩**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

[redacted]

## លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** មាត្រា ២៤៧ថ្មី និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**-បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ [redacted] ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣។

ជូនដំណឹងដល់ លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] មានការិយាល័យស្ថិតនៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] កែងនឹងផ្លូវលេខ២០៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ ០១៥ ៣៣១ ៥៧៧

ឱ្យបានជ្រាបថា ត្បិតសំណុំរឿងព្រហ្មទណ្ឌខាងលើនេះ យើងបានសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះតាមដីកាដំណោះស្រាយខាងលើនេះរួចហើយ។

ថ្ងៃព្រហស្បតិ៍ ២ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣
**ចៅក្រមស៊ើបសួរ**

យើង..............................................បានប្រគល់លិខិតជូនដំណឹង
នេះដល់ឈ្មោះ............................................ទីលំនៅបច្ចុប្បន្នភូមិ
...............................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ
...............................ខេត្ត/រាជធានី.......................................។
ធ្វើនៅថ្ងៃទី............ខែ.............ឆ្នាំ២០២...

**អ្នកទទួល** **អ្នកប្រគល់**

**ឧបសម្ព័ន្ធទី២០**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ.................. "ហ" ព្រ.ទ

## លិខិតជូនដំណឹងអំពី ដីកាដំណោះស្រាយ

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-**បានឃើញ** មាត្រា **២៤៧ថ្មី** និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ......................**"ហ" ដ.ដ** ចុះថ្ងៃទី...........ខែមករា ឆ្នាំ២០២៤។

ជូនដំណឹងដល់ ឈ្មោះ [redacted] ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងដែក សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នជាប់ឃុំខ្លួននៅ**មណ្ឌលអប់រំកែប្រែទី១ (ម១) ជនត្រូវចោទ**។

ត្បិតសំណុំរឿងព្រហ្មទណ្ឌខាងលើនេះ យើងបានសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះតាមដីកាដំណោះស្រាយខាងលើនេះរួចហើយ។

ថ្ងៃ....................កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី.............ខែមករា ឆ្នាំ២០២៤
**ចៅក្រមស៊ើបសួរ**

យើង..............................................បានប្រគល់លិខិតជូនដំណឹង
នេះដល់ឈ្មោះ...........................................ទីលំនៅបច្ចុប្បន្នភូមិ
.................................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ
.................................ខេត្ត/រាជធានី........................................។
ធ្វើនៅថ្ងៃទី............ខែ.............ឆ្នាំ២០២...

**អ្នកទទួល** **អ្នកប្រគល់**

**ឧបសម្ព័ន្ធទី២១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ......................."ហា" ជ.ឃ.ជ

## ដីកាបង្គាប់
## ឱ្យរក្សាទុកជនត្រូវចោទនៅក្នុងឃុំបណ្ដោះអាសន្ន

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

-**បានឃើញ** មាត្រា **២០៥** មាត្រា **២៤៧ថ្មី** និងមាត្រា **២៤៩** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ [redacted] ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤។

-**បានឃើញ** ដីកាដំណោះស្រាយលេខ......................**"ហា" ជ.ជ** ចុះថ្ងៃទី..............ខែមករា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ សម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិអូរ ឃុំទួលសាលា ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នជាប់ឃុំខ្លួននៅ**មណ្ឌលអប់រំកែប្រែទី១ (ម១)** មុខរបរជាងដែក ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី១២ ទោសពីមុនគ្មាន ជានីតិជន។ *(ក្នុងឃុំ)*

ទៅជំនុំជម្រះពីបទ៖ **លួចមានស្ថានទម្ងន់ទោស (គាស់ផ្ទះ)** ប្រព្រឹត្តនៅផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ភូមិ១២ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

*ដើម្បីធានាថាជនត្រូវចោទមកបង្ហាញខ្លួននៅចំពោះមុខតុលាការ នាពេលសវនាការ។*

### ហេតុដូច្នេះ សម្រេច

១-បង្គាប់ឱ្យលោកប្រធានពន្ធនាគារ រាជធានីភ្នំពេញ រក្សាការឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៨ឆ្នាំ បន្តទៀត រហូតដល់ថ្ងៃចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។

២-បង្គាប់ឱ្យប្រធានពន្ធនាគាររាជធានីភ្នំពេញ រក្សាទុកជនត្រូវចោទខាងលើនេះ បន្តទៀតតាមច្បាប់។

ថ្ងៃ....................កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី.............ខែមករា ឆ្នាំ២០២៤

**ចៅក្រមស៊ើបសួរ**